សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de droit et des Sciences Economoiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការជម្រះក្តីលើកទី១

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ៖
និស្សិតឈ្មោះ **ហួត ដាណាថប**

សាស្ត្រាចារ្យណែនាំ៖
លោក **ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហួត ដារណាថប** ជានិស្សិតផ្នែកនីតិសាស្ត្រ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា២០១៦-២០២០ ជំនាន់ទី២០

**សូមថ្លែងអំណរគុណ និង សម្តែងនូវកត្តញ្ញូតាធម៌ ដ៏ធំធេងបំផុតជូនចំពោះ ៖**

**លោកឪពុក ហេង ហួត** និង **អ្នកម្តាយ ឈួន ច័ន្ទរស្មី** រួមទាំង**អ្នកម្តាយធំ ឈួន បុប្ផា** ជាទីគោរពរបស់កូន ដែលលោកអ្នកមានគុណ បានផ្តល់កំណើតដល់រូបកូន និង បានចិញ្ចឹមបីបាច់ថែរក្សារូបកូនបានយ៉ាងល្អប្រសើរតាំងពីពេលចាប់កំណើត រហូតមកដល់ពេលបច្ចុប្បន្ននេះ។ លើសពីនេះទៅទៀត លោកអ្នកមានគុណ បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងខ្លា អស់ពីកម្លាំងកាយ និង កម្លាំងចិត្ត ហើយលះបង់នូវពេលវេលាជាច្រើន ដើម្បីផ្គត់ផ្គង់ដល់ជីវភាពរស់នៅរបស់កូន និង ឧបត្ថម្ភដល់រូបកូនគ្រប់សព្វបែបយ៉ាង ឱ្យរូបកូនបានសិក្សា និង មានសម្ភារៈសិក្សាគ្រប់គ្រាន់ សម្រាប់ក្រេបជញ្ជក់យកចំណេះវិជ្ជាតាំងពីកុមារភាព រហូតដល់ពេលបច្ចុប្បន្ននេះ ដោយមិនគិតពីការនឿយហត់អ្វីសោះឡើយ។ ជាពិសេស លោកអ្នកមានគុណ តែងតែផ្តល់នូវកម្លាំងចិត្ត ការអប់រំ និង ទូន្មានប្រៀនប្រដៅ ដល់រូបកូនប្រកបដោយគុណធម៌ និង ទឹកចិត្តស្រលាញ់ចង់ឲ្យកូនល្អ ដើម្បីឲ្យកូនបានសិក្សារៀនសូត្រមានចំណេះវិជ្ជាតាំងពីកុមារភាព រហូតដល់រូបកូនបានបញ្ចប់ការសិក្សាកម្រិតថ្នាក់បរិញ្ញាបត្រ និង កំពុងអភិវឌ្ឍខ្លួនឱ្យក្លាយទៅជាធនធានមនុស្សដ៏សំខាន់ម្នាក់ដែលសង្គមជាតិត្រូវការ ដើម្បីអភិវឌ្ឍប្រទេសជាតិយើង។

**ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ និង លោក លោកស្រី សាស្ត្រាចារ្យ** ដែលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីផ្តល់នូវការអប់រំ ចំណេះដឹង បទពិសោធន៍ សីលធម៌រស់នៅ និង ដំបូន្មានដ៏ល្អជាច្រើន រួមទាំងការជួយពន្យល់ណែនាំ បង្ហាត់បង្រៀន អំពីមេរៀននៃមុខវិជ្ជានីមួយៗ ដល់រូបខ្ញុំបាទ យ៉ាងយកចិត្តទុកដាក់បំផុត ដើម្បីឱ្យខ្ញុំបាទបានបញ្ចប់ការសិក្សាប្រកបដោយភាពជោគជ័យ។

**លោកសាស្ត្រាចារ្យ ហេង ម៉ូរ៉ា** ដែលជាសាស្ត្រាចារ្យណែនាំរបស់រូបខ្ញុំបាទផ្ទាល់លើកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ដោយលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក ដើម្បីដឹកនាំ ពន្យល់ណែនាំ និង កែតម្រូវនូវរាល់ចំណុចខ្វះខាតយ៉ាងច្រើនលើកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ តាំងពីពេលចាប់ផ្តើម រហូតមកដល់ពេលដែលខ្ញុំបាទបានបញ្ចប់ និង សម្រេចបាននូវកិច្ចការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ទទួលបាននូវលទ្ធផលដ៏សមប្រកបជាស្ថាពរ។

**ឯកឧត្តម ចេង ប៉េងហាប់** ជាប្រធានក្រុមមេធាវីនៃ**ក្រុមមេធាវី ស៊ី ភី អេច និង សហការី** (CPH & ASSOCIATES LAW GROUP) និង **លោក លោកស្រីមេធាវី** ជាមេធាវីនៃ **ក្រុមមេធាវី ស៊ី ភី អេច និង សហការី**(CPH & ASSOCIATES LAW GROUP) ដែលបានផ្តល់ឱកាស ទីតាំង និង

អនុញ្ញាតឱ្យរូបខ្ញុំបាទបានចុះស្រាវជ្រាវនូវឯកសារមួយចំនួន និង ទទួលបានការបង្ហាត់បង្រៀន ពន្យល់ណែនាំ ព្រមទាំងទទួលបាននូវមតិយោបល់ល្អៗជាច្រើនដែលពាក់ព័ន្ធនឹងខ្លឹមសារនៃសារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទ។

**ឯកឧត្តម លី សុវណ្ណបញ្ញា** ជាមេធាវីនៃ**ក្រុមមេធាវី ស៊ី ភី អេច និង សហការី**(CPH & ASSOCIATES LAW GROUP) និង ជាមេធាវីប្រចាំ**ក្រុមមេធាវី ស៊ី ភី អេច និង សហការី( សាខាខេត្តព្រះសីហនុ** )(CPH & ASSOCIATES LAW GROUP(PREAH SIHANOUK BRANCH)) ដែលបានផ្តល់នូវឯកសារគំរូមួយចំនួន ដើម្បីឱ្យខ្ញុំបាទបានយកឯកសារនោះ មកធ្វើជាឯកសារគំរូនៅក្នុងឧបសម្ព័ន្ធនៃសារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទ។

ជាកិច្ចតបស្នង និង ការដឹងគុណ ខ្ញុំបាទមានតែសូមជូនពរដល់ លោកអ្នកមានគុណ ឯកឧត្តម លោក លោកស្រី និង សាស្ត្រាចារ្យទាំងអស់ ឱ្យជួបតែសំណាងល្អ ជោគជ័យគ្រប់ភារកិច្ច និង សូមប្រសិទ្ធិពរជ័យ សេរីមង្គល បវរមហាប្រសើរ សូមឱ្យជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

✍🕮✍

## អារម្ភកថា

ដោយហេតុថា ខ្ញុំបាទជានិស្សិតមួយរូបដែលជាប់ចំណាត់ថ្នាក់ត្រូវតម្រូវឱ្យសរសេរសារណាដើម្បីបញ្ចប់ការសិក្សា និង ត្រូវបានកំណត់ឱ្យបញ្ចប់ការសិក្សាដោយការសរសេរសារណាបញ្ចប់ការសិក្សា។ ហេតុនេះខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយដែលមានចំណងជើងថា "**នីតិវិធីនៃការជម្រះក្តីលើកទី១**" ដើម្បីបំពេញកិច្ចក្នុងការសរសេរសៀវភៅសារណា ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ២០ នៅ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**។

មូលហេតុចម្បង ដែលខ្ញុំបាទសម្រេចចិត្តជ្រើសរើសប្រធានបទមួយនេះ ដើម្បីយកមករៀបរៀងជាសៀវភៅសារណាដើម្បីបញ្ចប់ការសិក្សានោះ គឺខ្ញុំបាទយល់ឃើញថា នីតិវិធីជម្រះក្តីនៅសាលាជម្រះក្តីជាន់ទាបក្នុងរឿងរដ្ឋប្បវេណី គឺជានីតិវិធីមួយដ៏សំខាន់ ដែលអ្នកវិជ្ជាជីវៈ អ្នកសិក្សា និង ប្រជាពលរដ្ឋគ្រប់រូបត្រូវតែយល់ដឹងឱ្យបានច្បាស់អំពីលំហូរនៃនីតិវិធីរឿងក្តីរដ្ឋប្បវេណីនៅសាលាជម្រះក្តីជាន់ទាបនេះ។ ដូច្នេះហើយចំណងជើងនៃប្រធានបទនេះ គឺសម្តៅទៅលើលំហូរនីតិវិធីនៃការជម្រះក្តីនៅសាលាជម្រះក្តីជាន់ទាប ឬ គ្រប់សាលាដំបូងរាជធានី ឬ ខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា។

ដូច្នេះហើយ ខ្ញុំបាទបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការស្រាវជ្រាវលើឯកសារដែលពាក់ព័ន្ធជាច្រើន ដើម្បីរៀបចំនូវសៀវភៅសារណាមួយនេះឱ្យមានគុណភាព និង ប្រសិទ្ធភាព ដែលអាចយកមកធ្វើជាមូលដ្ឋានក្នុងការសិក្សាបាន ខ្ញុំបាទបានព្យាយាមយ៉ាងសកម្មក្នុងការស្រាវជ្រាវឯកសារដែលមានខ្លឹមសារពាក់ព័ន្ធនឹងប្រធានបទមួយនេះតាមរយៈ ច្បាប់ដែលចូលជាធរមាន សៀវភៅ ឯកសារមួយចំនួនទៀតដែលរៀបរៀងដោយក្រសួងយុត្តិធម៌ យោបល់របស់អ្នកវិជ្ជាជីវៈផ្នែកច្បាប់ដែលធ្លាប់អនុវត្តកន្លងមក និង អ៊ីនធើណេត ឬ វេបសាយជាច្រើនទៀត ដែលសុទ្ធសឹងតែជាឯកសារដែលអាចយកមកធ្វើជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវបាន។

ជាពិសេស ចំពោះលទ្ធផលនៃសារណាបញ្ចប់ការសិក្សាមួយនេះ ខ្ញុំសង្ឃឹមថា ស្នាដៃរបស់ខ្ញុំនឹងអាចក្លាយជាឯកសារមួយដ៏សំខាន់សម្រាប់ទុកជាឯកសារជំនួយស្មារតីដល់អ្នកសិក្សា អ្នកអាន សិស្សច្បង សិស្សប្អូន និង សិស្សនិស្សិតផ្នែកនីតិសាស្ត្រជំនាន់ក្រោយទាំងអស់ រួមទាំងប្រជាពលរដ្ឋទូទាំងប្រទេសផងដែរដោយអាចជួយសម្រួលដល់ការសិក្សាស្រាវជ្រាវលើប្រធានបទ ឬ បញ្ហាផ្សេងៗដែលមានខ្លឹមសារពាក់ព័ន្ធនឹងលំហូរនីតិវិធីនៃការជម្រះក្តីលើកទី១ ដូចមានសរសេរនៅក្នុងសៀវភៅសារណាមួយនេះ។

យ៉ាងណាមិញ បើទោះជាខ្ញុំបាទបានយកចិត្តទុកដាក់ និង ខិតខំប្រឹងប្រែងខ្លាំងខ្លាយ៉ាងណាក៏ដោយ ក៏សៀវភៅសារណាមួយនេះគង់តែមាននៅចំណុចខ្វះខាត ឬ ចន្លោះប្រហោងពុំខានឡើយ ពោលគឺកំហុសលើផ្នែកអក្ខរាវិរុទ្ធ និង ផ្នែកអក្ខរាវិរុទ្ធដោយអចេតនាជាក់ជាពុំខាន ដូចពាក្យចាស់ពោលថា "ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច"។ ហេតុនេះហើយ ខ្ញុំបាទសូមមេត្តាខន្តីអភ័យទោសទុកជាមុននូវរាល់កំហុសខុស

ឆ្គងដែលកើតមានឡើងដោយអចេតនា ហើយខ្ញុំបាទសង្ឃឹម និង រង់ចាំទទួលនូវរាល់ការរិះគន់ដើម្បីស្ថាបនាទាំងឡាយពីសំណាក់ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ អ្នកសិក្សា អ្នកអាន និង សិស្សនិស្សិតទាំងអស់។

ជាចុងក្រោយ ខ្ញុំបាទសូមជូនពរដល់ ឯកឧត្តម លោក លោកស្រី សាស្ត្រាចារ្យ អ្នកសិក្សា អ្នកអាន និង សិស្សនិស្សិតទាំងអស់ ឱ្យជួបតែសំណាងល្អ និង ទទួលជោគជ័យគ្រប់ភារកិច្ចក្នុងជីវិត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**.......................................................................................................១

**ជំពូកទី១**

**នីតិវិធីនៃការចាប់ផ្តើមបណ្តឹង**

**ផ្នែកទី១៖ ការដាក់ពាក្យបណ្តឹង**........................................................................................៤

កថាខណ្ឌទី១៖ ប្រភេទនៃបណ្តឹង.......................................................................................៤

វាក្យខណ្ឌទី១៖ បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក.........................................................៤

វាក្យខណ្ឌទី២៖ បណ្តឹងទាមទារឱ្យបញ្ជាក់.....................................................................៦

វាក្យខណ្ឌទី៣៖ បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត..................................៦

កថាខណ្ឌទី២៖ ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង.....................................................៦

កថាខណ្ឌទី៣៖ ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹង.....................................................៩

**ផ្នែកទី២៖ ការទទួលពាក្យបណ្តឹង**..................................................................................១២

**ផ្នែកទី៣៖ ការបែងចែករឿងក្តី**.......................................................................................១៦

**ផ្នែកទី៤៖ ការពិនិត្យពាក្យបណ្តឹង**..................................................................................១៧

**ផ្នែកទី៥៖ ការពិនិត្យលក្ខខណ្ឌបណ្តឹង**...........................................................................១៨

**ផ្នែកទី៦៖ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលលើកដំបូង**១៩

**ផ្នែកទី៧៖ ការបញ្ជូនពាក្យបណ្តឹង**..................................................................................២០

**ជំពូកទី២**

**នីតិវិធីនៃការជំនុំជម្រះក្តី**

**ផ្នែកទី១៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល**.............................................................២២

កថាខណ្ឌទី១៖ គោលការណ៍ចំពោះមុខ និងគោលការណ៍បើកជាសាធារណៈ...............................២៣

កថាខណ្ឌទី២៖ សកម្មភាពបណ្តឹងដែលអាចធ្វើនៅក្នុងនីតិវិធី.................................................២៣

កថាខណ្ឌទី៣៖ កំណត់ហេតុនៃនីតិវិធី...............................................................................២៦

កថាខណ្ឌទី៤៖ ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង.......................២៧

កថាខណ្ឌទី៥៖ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ........ ៣២
កថាខណ្ឌទី៦៖ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........ ៣៥
**ផ្នែកទី២៖ ការទាញហេតុផលដោយផ្ទាល់មាត់** ........ ៣៥
កថាខណ្ឌទី១៖ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី១ ........ ៣៦
វាក្យខណ្ឌទី១៖ ការធ្វើសេចក្តីថ្លែងការណ៍ ........ ៣៦
វាក្យខណ្ឌទី២៖ សកម្មភាពដែលអាចធ្វើនៅក្នុងនីតិវិធី ........ ៣៧
វាក្យខណ្ឌទី៣៖ ការពិនិត្យភស្តុតាងដោយសម្ភូហវិធី ........ ៣៨
កថាខណ្ឌទី២៖ កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ ........ ៤៥
កថាខណ្ឌទី៣៖ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ........ ៤៧
**ផ្នែកទី៣៖ នីតិវិធីនៃការបញ្ចប់បណ្តឹង** ........ ៤៨
កថាខណ្ឌទី១៖ ការសះជាតាមផ្លូវបណ្តឹង ........ ៤៨
កថាខណ្ឌទី២៖ ការចេញសាលក្រម ........ ៥២
វាក្យខណ្ឌទី១៖ លិខិតសាលក្រម ........ ៥៣
វាក្យខណ្ឌទី២៖ សាលក្រមកំបាំងមុខ ........ ៥៥

## ជំពូកទី៣
## បញ្ហាប្រឈម និង ដំណោះស្រាយ

**ផ្នែកទី១៖ បញ្ហាប្រឈម** ........ ៦២
កថាខណ្ឌទី១៖ ការសរសេរ និង ការដាក់ពាក្យបណ្តឹង ........ ៦២
វាក្យខណ្ឌទី១៖ ការសរសេរពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ........ ៦២
វាក្យខណ្ឌទី២៖ ការយកពាក្យបណ្តឹងទៅដាក់នៅស្ថាប័នតុលាការ ........ ៦២
វាក្យខណ្ឌទី៣៖ ការគណនាពន្ធដាក់ពាក្យសុំ ........ ៦៣
វាក្យខណ្ឌទី៤៖ ការធ្វើចំណាត់ការលើពាក្យបណ្តឹង ........ ៦៤
កថាខណ្ឌទី២៖ ការបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........ ៦៤
កថាខណ្ឌទី៣៖ ពេលវេលាដំណើរការនីតិវិធីនៃការជំនុំជម្រះ ........ ៦៤
វាក្យខណ្ឌទី១៖ នីតិវិធីនៃការជំនុំជម្រះលឿនពេក ........ ៦៥

វាក្យខណ្ឌទី២៖ នីតិវិធីនៃការជំនុំជម្រះយូរពេក ........ ៦៥
កថាខណ្ឌទី៤៖ សមត្ថភាពរបស់ចៅក្រម ........ ៦៦
កថាខណ្ឌទី៥៖ សកម្មភាពរបស់តុលាការ ........ ៦៦
កថាខណ្ឌទី៦៖ ការផ្តល់សិទ្ធិឱ្យភាគីនៅក្នុងដំណើរការនីតិវិធីជម្រះក្តី ........ ៦៧
វាក្យខណ្ឌទី១៖ ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន ........ ៦៧
វាក្យខណ្ឌទី២៖ ការធ្វើសេចក្តីថ្លែងការណ៍ ........ ៦៨
វាក្យខណ្ឌទី៣៖ ការស្នើសុំពន្យារពេលនីតិវិធី ........ ៧០
កថាខណ្ឌទី៧៖ ការអនុវត្តនីតិវិធី ........ ៧០
កថាខណ្ឌទី៨៖ ការកំណត់ចំណុចវិវាទ ........ ៧០
កថាខណ្ឌទី៩៖ ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ ........ ៧១
**ផ្នែកទី២៖ ដំណោះស្រាយ** ........ ៧១
កថាខណ្ឌទី១៖ ការសរសេរ និង ការដាក់ពាក្យបណ្តឹង ........ ៧១
វាក្យខណ្ឌទី១៖ ការសរសេរពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ........ ៧២
វាក្យខណ្ឌទី២៖ ការយកពាក្យបណ្តឹងទៅដាក់នៅស្ថាប័នតុលាការ ........ ៧២
វាក្យខណ្ឌទី៣៖ ការគណនាពន្ធដាក់ពាក្យសុំ ........ ៧២
វាក្យខណ្ឌទី៤៖ ការធ្វើចំណាត់ការលើពាក្យបណ្តឹង ........ ៧៣
កថាខណ្ឌទី២៖ ការបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........ ៧៣
កថាខណ្ឌទី៣៖ ពេលវេលាដំណើរការនីតិវិធីនៃការជំនុំជម្រះ ........ ៧៣
វាក្យខណ្ឌទី១៖ នីតិវិធីនៃការជំនុំជម្រះលឿនពេក ........ ៧៣
វាក្យខណ្ឌទី២៖ នីតិវិធីនៃការជំនុំជម្រះយូរពេក ........ ៧៤
កថាខណ្ឌទី៤៖ សមត្ថភាពរបស់ចៅក្រម ........ ៧៤
កថាខណ្ឌទី៥៖ សកម្មភាពរបស់តុលាការ ........ ៧៥
កថាខណ្ឌទី៦៖ ការផ្តល់សិទ្ធិឱ្យភាគីនៅក្នុងដំណើរការនីតិវិធីជម្រះក្តី ........ ៧៥
វាក្យខណ្ឌទី១៖ ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន ........ ៧៥
វាក្យខណ្ឌទី២៖ ការធ្វើសេចក្តីថ្លែងការណ៍ ........ ៧៥

វាក្យខណ្ឌទី៣៖ ការស្នើសុំពន្យារពេលនីតិវិធី ....................................................................................៧៦
កថាខណ្ឌទី៧៖ ការអនុវត្តនីតិវិធី.......................................................................................................... ៧៧
កថាខណ្ឌទី៨៖ ការកំណត់ចំណុចវិវាទ.................................................................................................... ៧៧
កថាខណ្ឌទី៩៖ ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ ......................................................................... ៧៧
**សេចក្តីសន្និដ្ឋាន**.......................................................................................................................................៧៨
**អនុសាសន៍**.............................................................................................................................................. ៨១
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ជាទូទៅ ចំពោះរដ្ឋទាំងអស់ ដែលមានវត្តមាននៅក្នុងពិភពលោកយើងនេះ រមែងតែងមាននូវប្រជាពលរដ្ឋរស់នៅជាច្រើននៅតាមបណ្តារដ្ឋនីមួយៗ ដោយរដ្ឋទាំងអស់នោះ គឺមានទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា និងការគ្រប់គ្រងផ្សេងៗពីគ្នា ឬ ប្រហាក់ប្រហែលគ្នា។ យ៉ាងណាមិញ អ្វីដែលជាចំណុចចាប់អារម្មណ៍ និង ជាចំណុចដែលរដ្ឋនីមួយៗអាចនឹងមានភាពខុសគ្នាខ្លាំងនោះគឺ របបនៃការគ្រប់គ្រង ដោយរដ្ឋមួយចំនួនគ្រប់គ្រងរដ្ឋដោយប្រកាន់នូវរបបកុម្មុយនីស្ត និង រដ្ឋមួយចំនួនទៀតគ្រប់គ្រងរដ្ឋដោយប្រកាន់នូវរបបលទ្ធិប្រជាធិបតេយ្យ និង រដ្ឋខ្លះគ្រប់គ្រងរដ្ឋដោយប្រកាន់នូវរបបផ្សេងៗទៀតទៅតាមការជ្រើសរើសរបស់រដ្ឋទាំងនោះ។ ផ្ទុយមកវិញ រាល់ការការគ្រប់គ្រងរបស់រដ្ឋទាំងអស់នោះ គឺត្រូវគ្រប់គ្រងរដ្ឋឱ្យមានប្រសិទ្ធភាព និរន្តភាព និង អំណាច ដោយការបង្កើតច្បាប់ដើម្បីគ្រប់គ្រង ឬ ដើម្បីអនុវត្តប្រតិបត្តិការផ្សេងៗ ដូចជាដោះស្រាយវិវាទរបស់ប្រជាពលរដ្ឋ គ្រប់គ្រងសន្តិសុខក្នុងរដ្ឋ និង ផ្តន្ទាទោសដល់ជនល្មើសដែលបានប្រព្រឹត្តបទល្មើស ដើម្បីស្វែងរកយុត្តិធម៌ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងរដ្ឋនោះ។ ទន្ទឹមនឹងនេះ ដើម្បីឱ្យច្បាប់ដែលបានបង្កើតនោះ អាចអនុវត្តបាន គឺត្រូវមានស្ថាប័នជាច្រើនដើម្បីចូលរួមអនុវត្ត ដោយក្នុងនោះមាននូវស្ថាប័នដែលសំខាន់មួយដែលធានាឱ្យមានការអនុវត្តត្រឹមត្រូវតាមច្បាប់ និង ស្វែងរកនូវយុត្តិធម៌ជូនសង្គមជាតិនោះ គឺស្ថាប័នតុលាការ។

ជាក់ស្តែង ដូចជានៅព្រះរាជាណាចក្រកម្ពុជាយើងផ្ទាល់ គឺយើងមាននូវស្ថាប័នតុលាការ ដែលជាស្ថាប័នឯករាជ្យមួយ និង មានអំណាចដាច់ដោយឡែក ក្នុងការអនុវត្តច្បាប់នានា ដែលបានចូលជាធរមាន ដោយបានអនុម័តដោយរដ្ឋសភា និង ត្រួតពិនិត្យដោយព្រឹទ្ធសភា ហើយត្រូវបានព្រះមហាក្សត្រប្រកាសឱ្យប្រើជាសាធារណៈទូទាំងប្រទេស។ ជាការពិតណាស់ ច្បាប់ដ៏សំខាន់មួយចំនួនដែលព្រះរាជាណាចក្រកម្ពុជា កំពុងតែអនុវត្តសព្វថ្ងៃនេះ និង មានទំនាក់ទំនងសំខាន់បំផុតសម្រាប់ការរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងការប្រាស្រ័យទាក់ទងគ្នា ធ្វើអាជីវកម្ម ពាណិជ្ជកម្ម និង ការធ្វើសកម្មភាព ឬ ទំនាក់ទំនងគតិយុត្តផ្សេងៗ គឺមានដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និង ច្បាប់ផ្សេងៗទៀត។ល។ ក្រមរដ្ឋប្បវេណី គឺជាក្រម ដែលបានបញ្ញត្តិនូវទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី។ ម៉្យាងទៀតរាល់វិវាទផ្សេងៗដែលកើតមានឡើង ហើយមានចែងនៅក្នុងក្រមរដ្ឋប្បវេណី គឺត្រូវយកក្រមនេះមកអនុវត្ត លើកលែងតែមានការកំណត់ផ្សេងនៅក្នុងច្បាប់ពិសេស ហើយចំពោះការអនុវត្តវិញ គឺត្រូវអនុលោមតាមបញ្ញត្តិដែលមានចែងនៅក្នុង ក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាលំហូរនីតិវិធីក្នុងការជំនុំជម្រះរឿងក្តីរដ្ឋប្បវេណី និង នីតិវិធីអនុវត្តផ្សេងៗនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ ដូចសព្វថ្ងៃនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺមានសាលាជម្រះក្តីចំនួន៣ថ្នាក់ ដូចជា សាលាដំបូងនៅតាមបណ្តារាជធានី ឬ ខេត្ត សាលាឧទ្ធរណ៍នៅតាមតំបន់ និងតុលាការកំពូល។

ដោយហេតុថាប្រធានបទរបស់យើង គឺផ្តោតសំខាន់ទៅលើនីតិវិធីនៃការជម្រះក្តីលើកទី១ ពោលគឺនីតិវិធីជម្រះក្តីនៅសាលាដំបូងរាជធានី ឬ ខេត្ត ដោយមិនសម្តៅទៅលើនីតិវិធីជម្រះក្តីនៅសាលាឧទ្ធរណ៍នៅតាមតំបន់ និង តុលាការកំពូលឡើយ រួមទាំងនីតិវិធីអនុវត្តផ្សេងៗនៅសាលាដំបូងរាជធានី ឬ ខេត្តផងដែរ។ ហេតុនេះហើយ នីតិវិធីជម្រះក្តីលើកទី១នេះ អាចនឹងប្រតិបត្តិការទៅបាន ដោយសារតែវិវាទ ហើយវិវាទនោះ គឺកើតឡើងពីជម្លោះរបស់ប្រជាពលរដ្ឋ ឬ បុគ្គលដែលច្បាប់បានកំណត់ ដោយហេតុនៃការប្រាស្រ័យទាក់ទងគ្នានៅក្នុងសង្គម ដែលត្រូវកំណត់ថាជាភាគីនៃវិវាទ។ ប៉ុន្តែភាគីនៃវិវាទក៏អាចបង្ហាញឆន្ទៈក្នុងការជ្រើសរើសយកវិធីនៃការដោះស្រាយវិវាទបានដែរ ដោយផ្អែកតាមឆន្ទៈរបស់ខ្លួន ឬ ដោយផ្អែកតាមគោលការណ៍ស្វ័យភាពឆន្ទៈរបស់បុគ្គល។ ភាគីនៃវិវាទអាចជ្រើសរើសយកវិធីដោះស្រាយតាមមធ្យោបាយជាច្រើនដូចជា កិច្ចសន្យាសះជា ដោយភាគីនៃវិវាទសុខចិត្តស្រុះស្រួលគ្នា ក្នុងការលះបង់ឱ្យគ្នាទៅវិញទៅមកដើម្បីទទួលបាននូវចំណុចត្រូវរ៉ូវគ្នា។ ម្យ៉ាងទៀតប្រសិនបើភាគីនៃវិវាទមិនចង់ដោះស្រាយវិវាទតាមរយៈកិច្ចសន្យាសះជានេះទេ គឺភាគីនៃវិវាទអាចជ្រើសរើសយកយន្តការដោះស្រាយវិវាទតាមប្រព័ន្ធមជ្ឈត្តកម្ម ដែលមានមជ្ឈត្តករជាអ្នកដឹកនាំការដោះស្រាយវិវាទនោះ ហើយប្រព័ន្ធនេះ ច្រើនតែឃើញគេអនុវត្តចំពោះវិវាទទាក់ទងនឹងរឿងជួញដូរ ឬ ពាណិជ្ជកម្ម ជាពិសេសគឺចំពោះទំនាក់ទំនងនៃរឿងជួញដូរ ឬ ពាណិជ្ជកម្មអន្តរជាតិ។ យ៉ាងណាមិញ នៅក្នុងរឿងក្តីរដ្ឋប្បវេណី ប្រសិនបើភាគីនៃវិវាទនៅតែមិនអាចដោះស្រាយវិវាទបានដោយស្ម័គ្រទេ ឬភាគីនៃវិវាទ មិនអាចជ្រើសរើសយកមធ្យោបាយណាមួយដើម្បីដោះស្រាយវិវាទ ឬ ក៏មិនមានជម្រើសណាផ្សេងទៀត ក្នុងការដោះស្រាយវិវាទនេះទេ ភាគីនៃវិវាទ អាចដាក់ពាក្យបណ្តឹង ប្តឹងទៅតុលាការបាន ដើម្បីឱ្យតុលាការដែលជាអំណាចរដ្ឋជួយដោះស្រាយនូវវិវាទតាមនីតិវិធីបង្ខំ ដែលជាយន្តការរបស់រដ្ឋដែលបង្កើតឡើងដើម្បីធានារកយុត្តិធម៌ដល់ប្រជាពលរដ្ឋ តាមរយៈនីតិវិធីរដ្ឋប្បវេណី។ ហេតុនេះហើយនីតិវិធីជម្រះក្តីរបស់តុលាការនឹងត្រូវចាប់ផ្តើម នៅពេលដែលភាគីបានដាក់ពាក្យបណ្តឹង ហើយពាក្យបណ្តឹងដែលចាត់ទុកថាបានដាក់ គឺនៅពេលដែលដើមចោទបានដាក់ពាក្យបណ្តឹងនោះទៅតុលាការ ហើយក្រឡាបញ្ជីបានបោះត្រាចូលថាបានទទួល[1]។ ដោយហេតុដូច្នេះហើយ ទើបមាននូវការលើកឡើងមួយថា តើនីតិវិធីនៃការជម្រះក្តីលើកទី១នឹងដំណើរការទៅដោយរបៀបណា? ដើម្បីឆ្លើយតបទៅនឹងការលើកឡើងនេះ ដូចនេះយើងនឹងចាប់ផ្តើមធ្វើការអត្ថាធិប្បាយ ដោយផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណី និង ឯកសារផ្សេងៗជាច្រើនទៀតដែលបានស្រាវជ្រាវ។ ការអត្ថាធិប្បាយ នឹងប្រព្រឹត្តទៅដោយដំបូងយើងនឹងបកស្រាយតាមលំដាប់លំដោយដូចជា ជំពូកទី១ គឺនីតិវិធីនៃការចាប់ផ្តើមបណ្តឹង, ជំពូកទី២ គឺនីតិវិធីនៃការជំនុំជម្រះក្តី និង ជំពូកទី៣ គឺបញ្ហាប្រឈម និងដំណោះស្រាយ។ ហេតុដូច្នេះហើយ យើងនឹងចាប់ផ្តើមធ្វើការអត្ថាធិប្បាយដូចតទៅ៖

[1] សៀវភៅ ស្តីពី ការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី១ ដែលបានបោះពុម្ពលើកទី២ នៅខែវិច្ឆិកា ឆ្នាំ២០០៩។

# ជំពូកទី១
# នីតិវិធីនៃការចាប់ផ្ដើមបណ្ដឹង

នីតិវិធីនៃបណ្ដឹង ត្រូវបានចាប់ផ្ដើមអនុវត្ត នៅពេលដែលបានដាក់ពាក្យបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ច ហើយពាក្យបណ្ដឹងដែលចាត់ទុកថាបានដាក់ គឺជាពាក្យបណ្ដឹងដែលក្រឡាបញ្ជីបានបោះត្រាចូលថាបានទទួលតាមទម្រង់បែបបទរដ្ឋបាលរបស់តុលាការនោះ។ ប៉ុន្ដែពាក្យបណ្ដឹងដែលអាចចាត់ទុកថាបានធ្វើឡើងត្រឹមត្រូវស្របតាមច្បាប់កំណត់ គឺជាបណ្ដឹងដែលមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង និងអាចដោះស្រាយបានដោយសាលក្រម[2] ព្រោះជាគោលការណ៍ បណ្ដឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទផ្នែករដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដូចនេះដើម្បីឱ្យតុលាការអាចដោះស្រាយតាមគោលបំណងនេះបាន លុះត្រាតែការប្ដឹងទាមទារនោះមានកម្មវត្ថុជាវិវាទទាក់ទងនឹងសិទ្ធិរបស់បុគ្គលឯកជន[3]។

បណ្ដឹង គឺជាសកម្មភាពទាមទារមួយ ដែលដើមចោទបានធ្វើឡើងចំពោះចុងចម្លើយ ទៅតុលាការដែលមានសមត្ថកិច្ចនៅក្នុងការបន្ទុកជំនុំជម្រះ។ ឧទាហរណ៍៖ ដើមចោទ បានដាក់ពាក្យបណ្ដឹង ដោយអះអាងអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលមានកម្មវត្ថុជាវិវាទដែលអនុលោមតាមបញ្ញត្តិនៃមាត្រា ៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី អាចយកមកធ្វើជាមូលដ្ឋានក្នុងការទាមទារឱ្យតុលាការចេញសាលក្រមបាន។ ហេតុដូចនេះហើយ បណ្ដឹង គឺជាសកម្មភាពទាមទារឱ្យតុលាការចេញសាលក្រម តាមខ្លឹមសារដែលបានស្នើសុំតាមពាក្យបណ្ដឹងរបស់ដើមចោទ ហើយតុលាការអាចចេញសាលក្រមតាមចំណុចដែលដើមចោទបានសុំត្រឹមតែកម្រិតដែលបានសរសេរក្នុងពាក្យបណ្ដឹងតែប៉ុណ្ណោះ ពោលគឺតុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ[4] ប៉ុន្ដែតុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ[5]។

ដោយឡែកក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់នូវបញ្ញត្តិមួយចំនួន ដែលពាក់ព័ន្ធនឹងនីតិវិធីនៃការចាប់ផ្ដើមបណ្ដឹងនេះ ដែលមានដូចជា ការដាក់ពាក្យបណ្ដឹង ការទទួលពាក្យបណ្ដឹង ការបែងចែករឿងក្ដី ការពិនិត្យពាក្យបណ្ដឹង ការពិនិត្យលក្ខខណ្ឌបណ្ដឹង ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលលើកដំបូង និង ការបញ្ជូនពាក្យបណ្ដឹង។

---

[2] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រ ឆ្នាំ២០០៦ មាត្រា៧៤

[3] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា៧៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១

[4] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨២ កថាខណ្ឌទី១

[5] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨២ កថាខណ្ឌទី២

## ផ្នែកទី១៖ ការដាក់ពាក្យបណ្ដឹង

ការប្ដឹង ត្រូវធ្វើឡើងដោយការដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរ ទៅតុលាការ[6] លើកលែងតែមានបញ្ញត្តិផ្សេងដែលច្បាប់អនុញ្ញាតឱ្យធ្វើដោយផ្ទាល់មាត់។ ឧទាហរណ៍៖ មាត្រា២២៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា បានចែងថា ការដាក់ពាក្យបណ្ដឹងនៃរឿងក្ដីចំនួនទឹកប្រាក់តិច អាចធ្វើដោយផ្ទាល់មាត់បាន។ នៅក្នុងបញ្ញត្តិនៃមាត្រានេះ បានអនុញ្ញាតឱ្យធ្វើបណ្ដឹងដោយផ្ទាល់មាត់បាន ក្នុងករណីដែលរឿងក្ដីនោះ ជារឿងក្ដីចំនួនទឹកប្រាក់តិច ប៉ុន្តែនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មិនមានចែងថា តើចំនួនទឹកប្រាក់ប៉ុន្មានដែលត្រូវបានកំណត់ថាជាចំនួនទឹកប្រាក់តិច? និងពុំមានចែងអំពីរឿងក្ដីដែលមានទំហំទឹកប្រាក់ប៉ុន្មាន ដែលត្រូវបានកំណត់ថាជារឿងក្ដីចំនួនទឹកប្រាក់តិចនោះទេ។

ហេតុដូច្នេះហើយ មុននឹងធ្វើការដាក់ពាក្យបណ្ដឹង គេត្រូវសិក្សាពីប្រភេទនៃបណ្ដឹង ថាតើពាក្យបណ្ដឹងនោះជាបណ្ដឹងប្រភេទអ្វី សិក្សាពីអង្គហេតុ និងអង្គច្បាប់ឱ្យបានច្បាស់លាស់ជាមុនសិន ទើបអាចបង្កលក្ខណៈងាយស្រួលនៅក្នុងការសរសេរពាក្យបណ្ដឹងនោះឱ្យត្រឹមត្រូវតាមទម្រង់ដែលស្របទៅតាមបញ្ញត្តិនៃមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា។

### កថាខណ្ឌទី១៖ ប្រភេទនៃបណ្ដឹង

ប្រភេទនៃបណ្ដឹងអាចបែងចែកចេញជាច្រើនប្រភេទ ដោយផ្អែកតាមស្ថានភាពនៃអង្គហេតុដែលបានកើតឡើង ឬ ទៅតាមបទដ្ឋាននីមួយៗ ដែលជាមូលហេតុធ្វើឱ្យមានការលំបាកនៅក្នុងការកំណត់។ ដូច្នេះហើយ ទើបគេកំណត់បែងចែកប្រភេទនៃបណ្ដឹង ចេញជា៣ប្រភេទ ដែលមានដូចជា៖

- បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក
- បណ្ដឹងទាមទារឱ្យបញ្ជាក់ និង
- បណ្ដឹងទាមទារឱ្យបង្កើត ប្ដូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត។

#### វាក្យខណ្ឌទី១៖ បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក

បណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក គឺជាបណ្ដឹងមួយដែលទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយផ្ដល់តាវកាលិកកំណត់មួយ ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទារឱ្យផ្ដល់តាវកាលិកតាមផ្លូវច្បាប់សារធាតុដែលបានកំណត់នៅក្នុងការទាមទារតាមផ្លូវបណ្ដឹង។ រីឯខ្លឹមសារនៃតាវកាលិកវិញ តាមធម្មតា ក្រៅពីការបង់ប្រាក់កំណត់មួយ ដូចការទាមទាររបស់ដើមចោទ អាចមានករណីច្រើនដូចជា ការទាមទារឱ្យប្រគល់អចលនវត្ថុ ការទាមទារឱ្យប្រគល់ចលនវត្ថុ និងការទាមទារឱ្យធ្វើសកម្មភាពណាមួយ ឬការទាមទារ

[6] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៧៥ កថាខណ្ឌទី១

មិនឱ្យធ្វើសកម្មភាពណាមួយ។ ឧទាហរណ៍៖ **លោក ក** ជាម្ចាស់បំណុល និង **លោក ខ** ជាកូនបំណុល បានបង្កើតកិច្ចសន្យាខ្ចីប្រាក់ជាមួយគ្នា ហើយនៅពេលកាលកំណត់នៃថ្ងៃសងប្រាក់បានមកដល់ ប៉ុន្តែ **លោក ខ** មិនព្រមសងប្រាក់នោះមកឱ្យ **លោក ក** វិញឡើយ។ ដូចនេះ **លោក ក** ក៏បានដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីទាមទារប្រាក់កម្ចីពី **លោក ខ** ត្រឡប់មកវិញ ដោយក្នុងពាក្យបណ្តឹង **លោក ក** បានសរសេរទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ **លោក ខ** ដែលជាកូនបំណុលបង់ប្រាក់ដើម និងការប្រាក់ដែលច្បាប់បានកំណត់មកឱ្យខ្លួន។ ក្នុងករណីដែល **លោក ក** បានដាក់ពាក្យបណ្តឹងទៅតុលាការទាមទារឱ្យ **លោក ខ** បង់ប្រាក់ដើម និងការប្រាក់ដែលច្បាប់បានកំណត់នេះ គឺជាបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក។

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិក ត្រូវបានបែងចែកចេញជា២ប្រភេទទៀត គឺបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន និង បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត។

បណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលបច្ចុប្បន្ន គឺជាបណ្តឹង ដែលដើមចោទ បានដាក់ឡើងដោយមានការអះអាងអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកមួយ ដែលពេលកំណត់ត្រូវអនុវត្តនោះ បានមកដល់ហើយ។ ឧទាហរណ៍៖ **លោក ក** ដែលជាដើមចោទបានអះអាងអំពីសិទ្ធិលើបំណុល ដែលមានកម្មវត្ថុជាប្រាក់ ទៅតុលាការ ដោយកាលបរិច្ឆេទនៃការកំណត់សងប្រាក់កម្ចីត្រូវបានមកដល់ ប៉ុន្តែចុងចម្លើយ មិនព្រមបង់ប្រាក់សង ដូចនេះ **លោក ក** អាចដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់កម្ចីមកឱ្យខ្លួនបានតាមការសុំរបស់ខ្លួនបាន។

រីឯបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកនាពេលអនាគត គឺជាបណ្តឹង ដែលដើមចោទ បានដាក់ឡើង ដោយមានការអះអាងអំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកមួយ ដែលពេលកំណត់ត្រូវអនុវត្តនោះមិនទាន់មកដល់នៅឡើយ។ ពាក្យបណ្តឹងនេះ អាចធ្វើឡើងបាន លុះត្រាតែមានភាពចាំបាច់តម្រូវឱ្យធ្វើការទាមទារនោះជាមុនតែប៉ុណ្ណោះ[7]។ ឧទាហរណ៍៖ **លោក ក** ដែលជាដើមចោទបានអះអាងអំពីសិទ្ធិលើបំណុល ដែលមានកម្មវត្ថុជាប្រាក់ទៅតុលាការ ដោយកាលបរិច្ឆេទនៃការកំណត់សងប្រាក់កម្ចីមិនទាន់ដល់នៅឡើយទេ ប៉ុន្តែ **លោក ក** មានការបារម្ភជាខ្លាំង និងគិតថាចុងចម្លើយអាចនឹងគ្មានលទ្ធភាពសងប្រាក់នៅពេលដែលបានកំណត់ ដោយមូលហេតុចាំបាច់បណ្តាលមកពីចុងចម្លើយកំពុងតែប្រឈមមុខនឹងបញ្ហាធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច ដែលអាចនឹងត្រូវប្រកាសឱ្យក្ស័យធនដោយតុលាការ ដូចនេះ **លោក ក** អាចដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់កម្ចី ដែលជាតាវកាលិកនាពេលអនាគត មកឱ្យខ្លួនបានតាមការសុំរបស់ខ្លួនបាន ដោយផ្អែកតាមភាពចាំបាច់ ដែលជាផលប្រយោជន៍ពិសេសនៃបណ្តឹង។

[7] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៦

**វាក្យខណ្ឌទី២៖ បណ្តឹងទាមទារឱ្យបញ្ជាក់**

បណ្តឹងទាមទារឱ្យបញ្ជាក់ គឺជាបណ្តឹងដែលទាមទារឱ្យតុលាការចេញសាលក្រមបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដោយផ្អែកលើការអះអាងរបស់ដើមចោទ នូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង។ ក្នុងចំណោមនោះ បណ្តឹងដែលអះអាងនូវអត្ថិភាពនៃសិទ្ធិជាអាទិ៍ គេហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់ដោយសកម្ម ហើយបណ្តឹងដែលអះអាងនូវនត្ថិភាពនៃសិទ្ធិនោះ គេហៅថា បណ្តឹងទាមទារឱ្យបញ្ជាក់អសកម្ម។

ជាគោលការណ៍ កម្មវត្ថុនៃបណ្តឹងទាមទារឱ្យបញ្ជាក់ ត្រូវតែជាការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តជាក់ស្តែង។ ឧទាហរណ៍៖ បណ្តឹងទាមទារឱ្យទទួលស្គាល់បុត្តភាព ជាដើម។ល។

ការទាមទារនៃបណ្តឹងនេះ ជាបឋម ត្រូវធ្វើការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត និង ជាគោលការណ៍ គឺមិនអនុញ្ញាតឱ្យធ្វើការទាមទារឱ្យបញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុឡើយ។

**វាក្យខណ្ឌទី៣៖ បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត**

បណ្តឹងទាមទារឱ្យបង្កើត ប្តូរ ឬ រំលត់ទំនាក់ទំនងគតិយុត្ត គឺជាបណ្តឹងដែលទាមទារឱ្យតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនូវទំនាក់ទំនងគតិយុត្ត(ការបង្កើត ការប្តូរ ឬ ការរំលត់) ដោយផ្អែកលើការអះអាងអំពីអត្ថិភាពនៃសិទ្ធិបង្កើត ឬ អំពីមូលហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង។ ឧទាហរណ៍ដូចជា៖ បណ្តឹងលែងលះ ដែលជាបណ្តឹងទាមទារឱ្យរំលត់នូវទំនាក់ទំនងរវាងសហព័ទ្ធ ហើយក៏ជាបណ្តឹងទាមទារឱ្យបង្កើតនូវទំនាក់ទំនងគតិយុត្តផងដែរ ពោលគឺសម្តៅទៅលើការបែងចែកទ្រព្យសម្បត្តិ និង ការកំណត់អំណាចមេបាលើកូន ប្រសិនបើមាន។ បណ្តឹងសុំរំលាយកិច្ចសន្យា គឺជាបណ្តឹងទាមទារឱ្យរំលត់នូវទំនាក់ទំនងគតិយុត្ត ឬ កាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យា។ បណ្តឹងសុំឱ្យរំលាយកិច្ចសន្យាដែលមានវិការៈ និង សុំឱ្យទទួលស្គាល់កិច្ចសន្យាដែលគ្មានវិការៈវិញ គឺជាបណ្តឹងទាមទារឱ្យប្តូរនូវទំនាក់ទំនងគតិយុត្ត។

**កថាខណ្ឌទី២៖ ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង**

ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង គឺជាចំណុចដែលចាំបាច់តម្រូវឱ្យសរសេរដើម្បីឱ្យពាក្យបណ្តឹងមានសុពលភាព ស្របតាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៧៥ កថាខណ្ឌទី២។

ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាបានចែងអំពីចំណុចដែលត្រូវសរសេរបញ្ជាក់នៅក្នុងលិខិតនៃពាក្យបណ្តឹង មានដូចខាងក្រោម៖

➢ត្រូវសរសេរបញ្ជាក់អំពី ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់[8]។ ការសរសេរបញ្ជាក់អំពី ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគីឱ្យបានច្បាស់លាស់ គឺជាការចាំបាច់សម្រាប់ភាគី ដើម្បីបង្កភាពងាយស្រួលដល់តុលាការ សម្រាប់ធ្វើការបញ្ជូន និង ផ្ញើពាក្យបណ្ដឹង និង ឯកសារផ្សេងៗ ទៅកាន់ភាគីទាំងសងខាង។ ម៉្យាងទៀត ប្រសិនបើភាគីមានអ្នកតំណាងដែលច្បាប់កំណត់នោះ ពាក្យបណ្ដឹង ត្រូវសរសេរបញ្ជាក់អំពី ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងគោលបំណងបង្កភាពងាយស្រួលដល់តុលាការក្នុងការបញ្ជូន និង ផ្ញើពាក្យបណ្ដឹង និង ឯកសារផ្សេងៗដូចជា ដីកាកោះ(សម្រាប់ភាគីនៃវិវាទ, អ្នកតំណាងជាអាណាព្យាបាល ឬ អ្នកតំណាងឱ្យនីតិបុគ្គល) ឬ លិខិតអញ្ជើញ(សម្រាប់អ្នកតំណាងដោយអាណត្តិរបស់ភាគីនៃវិវាទជាមេធាវី) ហេតុដូចនេះ ក៏ព្រោះតែនៅក្នុងករណីខ្លះ ដែលភាគីម្ខាងជាអ្នកអសមត្ថភាពក្នុងបណ្ដឹង ឬ ជានីតិបុគ្គល ដែលគប្បីគួរតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអ្នកដែលធ្វើសកម្មភាពនៃបណ្ដឹងផ្ទាល់។ ឧទាហរណ៍៖ **លោក ក** ជាដើមចោទ បានប្ដឹង **លោក ខ** ពាក់ព័ន្ធនឹងការរំលោភបំពានលើកិច្ចសន្យា ដូចនេះ **លោក ក** ត្រូវសរសេរពាក្យបណ្ដឹងដោយបញ្ជាក់អំពី ឈ្មោះ និង អាសយដ្ឋានរបស់ខ្លួនឯង និង **លោក ខ** ឱ្យបានច្បាស់លាស់ ហើយប្រសិនបើ **លោក ក** និង **លោក ខ** មានអ្នកតំណាងដែលច្បាប់បានកំណត់ ដូចនេះ នៅក្នុងពាក្យបណ្ដឹង ត្រូវតែសរសេរបញ្ជាក់បន្ថែមអំពី ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងនោះឱ្យបានច្បាស់លាស់។ ដោយឡែក នៅក្នុងករណីដែលពាក្យបណ្ដឹង ដើមចោទមិនបានសរសេរលម្អិតអំពីអាសយដ្ឋានរបស់ចុងចម្លើយ ប៉ុន្តែអាសយដ្ឋានដែលដើមចោទបានសរសេរនោះមានចំណុចជាក់លាក់មួយដែលតុលាការអាចធ្វើការបញ្ជូនទៅចុងចម្លើយបានដោយងាយស្រួលនោះ ដូចនេះពាក្យបណ្ដឹងនោះនៅតែអាចទទួលយកបានដែរ។ ឧទាហរណ៍៖ នៅក្នុងពាក្យបណ្ដឹង ដើមចោទ បានសរសេរអាសយដ្ឋានរបស់ចុងចម្លើយ គឺនៅផ្ទះលេខ៤៤ ផ្លូវនរោត្តម ដោយមិនបានបញ្ជាក់អំពីឈ្មោះរបស់ ភូមិ សង្កាត់ ខណ្ឌ ណាមួយទេ ឬ រាជធានីភ្នំពេញឡើយ ប៉ុន្តែអាសយដ្ឋាននេះ ក៏នៅតែអាចឱ្យតុលាការធ្វើការបញ្ជូនឯកសារផ្សេងៗដល់ចុងចម្លើយបានដដែរ ហេតុនេះហើយ ពាក្យបណ្ដឹងដែលមិនបានសរសេរលម្អិតអំពីអាសយដ្ឋានរបស់ចុងចម្លើយច្បាស់លាស់របៀបនេះ ក៏នៅតែអាចទទួលយកបានដែរ។

➢ត្រូវសរសេរបញ្ជាក់អំពីខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ[9]។ ជាទូទៅ នៅក្នុងពាក្យបណ្ដឹង គឺត្រូវសរសេរបញ្ជាក់អំពីខ្លឹមសារនៃសាលក្រមដែលទាមទារឱ្យតុលាការចេញ និង ត្រូវសរសេរបញ្ជាក់អំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ

---

[8] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ក

[9] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ

បើយោងតាមចំណុចទាំងពីរនេះ គេអាចបញ្ជាក់នូវការទាមទារតាមផ្លូវបណ្ដឹងបាន។ ការទាមទារតាមផ្លូវបណ្ដឹង គឺជាការអះអាងស្ដីពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត តាមផ្លូវច្បាប់សារធាតុដែលបានកំណត់ តាមរយៈបណ្ដឹងរបស់ដើមចោទចំពោះចុងចម្លើយ ហើយការអះអាងនោះ គឺជាកម្មវត្ថុ ឬ ជាមូលដ្ឋានក្នុងការពិចារណានៅពេលធ្វើការជំនុំជម្រះ និង វិនិច្ឆ័យដើម្បីសម្រេចសេចក្ដីនៃបណ្ដឹង។ ចំពោះខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ គឺជាអត្ថន័យនៃសាលក្រមដែលដើមចោទចង់ឱ្យតុលាការសម្រេចសេចក្ដីដូចអ្វីដែលមានសរសេរនៅក្នុងពាក្យបណ្ដឹងរបស់ខ្លួន។ ម្យ៉ាងទៀត ការសរសេរពីខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ នៅក្នុងពាក្យបណ្ដឹង គឺមានភាពខុសប្លែកពីគ្នា ដោយផ្អែកទៅតាមប្រភេទនៃបណ្ដឹង។ រីឯអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារតាមផ្លូវបណ្ដឹង ហើយមូលហេតុចាំបាច់ដែលត្រូវតែសរសេរអំពីអង្គហេតុចាំបាច់ គឺដើម្បីបញ្ជាក់នូវការទាមទារ នៅក្នុងពាក្យបណ្ដឹង និង ដើម្បីកុំឱ្យមានការភាន់ច្រឡំ ឬ មានការបែងចែកមិនច្បាស់លាស់នូវការទាមទារដែលជាកម្មវត្ថុនៃការជំនុំជម្រះ និង ជាមូលដ្ឋាននៃការពិចារណាសម្រាប់ការវិនិច្ឆ័យសម្រេចសេចក្ដី ទាក់ទងទៅនឹងការទាមទារផ្សេងទៀត មានន័យថា សម្ដៅទៅលើអង្គហេតុ ដែលអាចធ្វើការសម្គាល់កុំឱ្យមានការភាន់ច្រឡំរវាងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តអះអាងដោយដើមចោទ និង សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដទៃទៀត។ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺមានលក្ខណៈខុសគ្នាទៅតាមប្រភេទនៃសិទ្ធិ និង ទំនាក់ទំនងគតិយុត្តនីមួយៗ។ ឧទាហរណ៍ទី១៖ ករណីដែលសិទ្ធិអះអាងដោយដើមចោទជាសិទ្ធិប្រត្យក្ស ដែលជាសិទ្ធិផ្ដាច់មុខ(លើកលែងតែសិទ្ធិប្រាតិភោគប្រត្យក្ស) សិទ្ធិនោះមិនអាចមានអត្ថិភាពជាន់គ្នាលើកម្មវត្ថុតែមួយបានទេ ដូចជាករណីដែល នៅលើអចលនវត្ថុ(ដី)មួយកន្លែងមិនអាចមានម្ចាស់កម្មសិទ្ធិពីរលើដីតែមួយបានឡើយ។ ហេតុនេះហើយ ដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិ គឺគ្រាន់តែសរសេរអំពីប្រធាននៃសិទ្ធិ (ដើមចោទ) កម្មវត្ថុនៃសិទ្ធិ (ទីតាំងអចលនវត្ថុ(ដី)នៅកន្លែងណាមួយ) រួមទាំងប្រភេទ និង ខ្លឹមសារនៃសិទ្ធិ (សិទ្ធិលើកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ជាដើម។ល។) គឺគ្រប់គ្រាន់ហើយ។ ឧទាហរណ៍ទី២៖ ករណីដែលសិទ្ធិអះអាងដោយដើមចោទជាសិទ្ធិលើបំណុល គឺដើមចោទអាចមានសិទ្ធិច្រើនចំពោះចុងចម្លើយ ដោយមូលហេតុនៃការបង្កើតសិទ្ធិនោះផ្សេងគ្នា។ ហេតុនេះ ដើម្បីធ្វើការបញ្ជាក់នូវសិទ្ធិ ដើមចោទត្រូវសរសេរនៅក្នុងពាក្យបណ្ដឹងអំពីប្រធាននៃសិទ្ធិ កម្មវត្ថុនៃសិទ្ធិ ប្រភេទនៃសិទ្ធិ ខ្លឹមសារនៃសិទ្ធិ និង មូលហេតុនៃការបង្កើតសិទ្ធិ។ ឧទាហរណ៍៖ ករណីសិទ្ធិទាមទារឱ្យបង់ប្រាក់ចំនួនកំណត់មួយ ដែលអាចមានអត្ថិភាព ដោយសារជាសិទ្ធិទាមទារឱ្យសងប្រាក់កម្ចី ដោយផ្អែកលើកិច្ចសន្យាខ្ចីបរិភោគ[10] ឬ ជាសិទ្ធិទាមទារប្រាក់ថ្លៃលក់ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ[11] ឬ ជាសិទ្ធិទាមទារសំណង

[10] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា៥៧៨

នៃការខូចខាតដោយសារគ្រោះថ្នាក់ចរាចរណ៍ជាដើម។ ក្រៅពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ភាគី គប្បីសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារផងដែរ ប៉ុន្តែគប្បីសរសេរនូវចំណុចអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ ដាច់ដោយឡែកពីគ្នា។ យ៉ាងណាមិញ នៅពេលដែលពាក្យបណ្តឹង មានសរសេរអំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺស្របទៅនឹងលក្ខខណ្ឌនៃមាត្រា៧៥ កថាខណ្ឌទី២ ចំណុច ខ ហេតុនេះហើយតុលាការមិនត្រូវលើកពាក្យបណ្តឹងនោះចោលទេ។

**កថាខណ្ឌទី៣៖ ចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹង**

ក្រៅពីចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ដែលមានចែងនៅក្នុងមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏នៅមានចំណុចដែលដើមចោទគប្បីសរសេរបញ្ជាក់ឱ្យច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង[12]។

អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាសិទ្ធិទាមទារតាមផ្លូវបណ្តឹង។ ដូចនេះ ដើម្បីសិក្សាឱ្យស៊ីជម្រៅលើចំណុចអង្គហេតុដែលជាមូលហេតុនៃការទាមទារនេះ យើងត្រូវដឹងជាមុនអំពីភាពខុសគ្នារវាងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ។

ការសរសេរអំពី អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ នៅក្នុងពាក្យបណ្តឹង គឺដើម្បីបែងចែកឱ្យច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្តឹង ពីការទាមទារដទៃទៀត។ ឧទាហរណ៍៖ ដើមចោទ បានទាមទារឱ្យចុងចម្លើយ សងប្រាក់កម្ចី ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើង ហើយគេអាចបញ្ជាក់ឱ្យច្បាស់លាស់នូវការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទបានតាមរយៈ ការបញ្ជាក់ឱ្យបានច្បាស់លាស់នូវប្រធាននៃសិទ្ធិ កម្មវត្ថុនៃសិទ្ធិ ប្រភេទនៃសិទ្ធិ ខ្លឹមសារនៃសិទ្ធិ និង មូលហេតុនៃការកកើតសិទ្ធិ។ រីឯការសរសេរអំពី អង្គហេតុដែលជាមូលហេតុនៃការទាមទារ នៅក្នុងពាក្យបណ្តឹង គឺដើម្បីបង្ហាញអំពីការកើតមានឡើងនៃការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ។ ឧទាហរណ៍៖ ដើមចោទ បានទាមទារឱ្យចុងចម្លើយ សងប្រាក់កម្ចី ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគដែលបានបង្កើតឡើង ដោយបានបញ្ជាក់បន្ថែមថា ដើមចោទ បានប្រគល់ប្រាក់ឱ្យចុង

---

[11] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា៥១៥

[12] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៥ កថាខណ្ឌទី៣

ចម្លើយនៅក្នុងចំនួនកំណត់ណាមួយ ដោយកាលកំណត់សងត្រូវបានកន្លងផុតទៅហើយ។ ដូច្នេះ អង្គហេតុទាំងនេះ អាចអះអាងអំពីការកកើតសិទ្ធិតាមក្រមរដ្ឋប្បវេណីបាន។

ម៉្យាងទៀត ករណីដែលនៅក្នុងពាក្យបណ្ដឹងមានសរសេរអំពីអង្គហេតុទាំងពីរខាងលើនេះជាន់គ្នា គឺមានច្រើនណាស់។ ប៉ុន្តែ អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺមានលក្ខណៈសំខាន់ជាងអង្គហេតុដែលជាមូលហេតុនៃការទាមទារ ពីព្រោះថា ប្រសិនបើនៅក្នុងពាក្យបណ្ដឹង មិនមានសរសេរអំពី អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារនោះទេ តុលាការអាចចេញដីកាសម្រេចលើកពាក្យបណ្ដឹងនោះចោលបាន។ ផ្ទុយមកវិញ ប្រសិនបើនៅក្នុងពាក្យបណ្ដឹង មិនមានសរសេរអំពី អង្គហេតុដែលជាមូលហេតុនៃការទាមទារនោះទេ តុលាការមិនអាចចេញដីកាសម្រេចលើកពាក្យបណ្ដឹងនោះចោលបានទេ។

យ៉ាងណាមិញ ការសរសេរអំពី អង្គហេតុដែលជាមូលហេតុនៃការទាមទារ នៅក្នុងពាក្យបណ្ដឹង នៅតែជាចំណុច ឬ អង្គហេតុដែលមានអត្ថប្រយោជន៍ចំពោះដំណើរការនៃនីតិវិធីរបស់តុលាការ ដូចជា អាចបង្កភាពងាយស្រួលដល់តុលាការ ក្នុងការរៀបចំចំណុចវិវាទ ចាប់តាំងពីពេលដែលចាប់ផ្ដើមកាលបរិច្ឆេទនៃការជំនុំជម្រះលើកដំបូង និង តុលាការអាចចេញសាលក្រមកំបាំងមុខបាន ប្រសិនបើចុងចម្លើយអវត្តមាន[13] ដោយពុំចាំបាច់ធ្វើការបញ្ជូនជាថ្មីនូវខ្លឹមសារនៃសេចក្ដីថ្លែងការណ៍របស់ដើមចោទ ទៅចុងចម្លើយតាមមាត្រា២០២ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

អង្គហេតុដែលជាមូលហេតុនៃការទាមទារនេះ គឺមានទំនាក់ទំនងយ៉ាងសំខាន់ទៅនឹងអង្គហេតុចម្បង និង អង្គហេតុតវ៉ា។

➢ អង្គហេតុចម្បង គឺជាអង្គហេតុដែលនាំឱ្យមានអានុភាពតាមផ្លូវច្បាប់ មានន័យថា ជាអង្គហេតុដែលបង្កើត ឬ ជាឧបសគ្គនៃការកកើត ឬ រារាំង ឬ រំលត់ សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត។ ឧទាហរណ៍៖ ករណីដើមចោទ បានឱ្យចុងចម្លើយខ្ចីប្រាក់ គឺជាអង្គហេតុដែលបង្កើតសិទ្ធិ។ ប្រសិនបើកិច្ចសន្យាកើតឡើងដោយមានវិការៈនៃការបង្ហាញឆន្ទៈនោះ គឺជាអង្គហេតុដែលជាឧបសគ្គនៃការកកើតសិទ្ធិ។ បើករណីដែលចុងចម្លើយបានបង់ប្រាក់ដែលបានខ្ចីនោះឱ្យទៅដើមចោទវិញរួចហើយ គឺជាអង្គហេតុដែលរំលត់សិទ្ធិ។ ចំណែកឯករណីដែលកាលកំណត់សងមិនទាន់មកដល់ គឺជាអង្គហេតុដែលរារាំងការអនុវត្តសិទ្ធិ។ ទំនាក់ទំនងរវាងអង្គហេតុទាំងពីរ គឺអង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺជាអង្គហេតុដែលបង្កើតសិទ្ធិតាមផ្លូវបណ្ដឹង ហើយជាអង្គហេតុចម្បងដែលដើមចោទបានអះអាងដំបូងបំផុត ចំណែកឯអង្គហេតុចម្បង គឺជាទស្សនៈទូលំទូលាយជាង អង្គ

[13] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០១ កថាខណ្ឌទី១ និងកថាខណ្ឌទី២

ហេតុដែលជាមូលហេតុនៃការទាមទារ ព្រោះតែមានរួមទាំង អង្គហេតុតវ៉ា ដែលអះអាងដោយចុងចម្លើយ ឬ អង្គហេតុតវ៉ាតប ដែលអះអាងដោយដើមចោទ។

➢ អង្គហេតុតវ៉ា គឺជាអង្គហេតុដែលចុងចម្លើយអះអាងតវ៉ា ចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ។ អង្គហេតុនេះ អាចជាអង្គហេតុដែលរំលត់ ឬ ដែលជាឧបសគ្គនៃការកកើត ឬ ដែលរារាំងការអនុវត្តសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត។ ទំនាក់ទំនងនៃអង្គហេតុទាំងពីរនេះគឺ អង្គហេតុដែលជាមូលហេតុនៃការទាមទារ គឺដើមចោទជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ដោយភស្តុតាង រីឯអង្គហេតុតវ៉ា គឺចុងចម្លើយជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់។ បានជាគេបែងចែកចំណុចទាំងពីរនេះផ្សេងពីគ្នា ដោយសារតែវាជាចំណុចសំខាន់នៃគោលការណ៍នៃការទទួលខុសត្រូវក្នុងបញ្ជាក់។

នៅក្នុងចំណុចដែលគប្បីសរសេរក្នុងពាក្យបណ្តឹងនេះ នៅមានចំណុចសំខាន់ដែលដើមចោទគប្បីសរសេរ ឬ ដកស្រង់មកដាក់នៅក្នុងពាក្យបណ្តឹងទៀតនោះគឺ អង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង។ អង្គហេតុសំខាន់ៗនោះ អាចជាអង្គហេតុប្រយោល ដែលជាអង្គហេតុទាំងឡាយណាដែលអាចធ្វើឱ្យគេសន្និដ្ឋានអំពីអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុចម្បង ដែលជាអង្គហេតុផ្ទាល់។ ដោយអង្គហេតុនេះត្រូវបញ្ជាក់ដោយភស្តុតាង ហើយដើម្បីបញ្ជាក់នូវភស្តុតាងនៃអង្គហេតុនេះ គេបានបែងចែងវិធីដើម្បីបញ្ជាក់ភស្តុតាងនៃអង្គហេតុចេញជាពីរគឺ៖

➢ ការទទួលស្គាល់ដោយផ្ទាល់នូវអង្គហេតុនោះ ដោយភស្តុតាងផ្ទាល់។

➢ ការទទួលស្គាល់នូវអង្គហេតុប្រយោល តាមរយៈភស្តុតាងប្រយោល ហើយទទួលស្គាល់នូវអង្គហេតុនោះ ដោយអង្គហេតុប្រយោលដែលបានបញ្ជាក់នេះ ដូចនេះគឺជាការសន្និដ្ឋាននូវអង្គហេតុនោះ តាមរយៈអង្គហេតុប្រយោល។

ប្រសិនបើភស្តុតាងមានមិនគ្រប់គ្រាន់សម្រាប់ធ្វើការបញ្ជាក់លើអង្គហេតុចម្បងនោះទេ ដើមចោទគប្បីសរសេរក្នុងពាក្យបណ្តឹងនូវអង្គហេតុប្រយោលឱ្យបានច្រើន។ ប៉ុន្តែប្រសិនបើមាននូវភស្តុតាងផ្ទាល់ដែលច្បាស់លាស់ស្រាប់ហើយ មិនចាំបាច់សរសេរអង្គហេតុប្រយោលក៏បានដែរ។ ឧទាហរណ៍៖ **លោក ក** បានឱ្យប្រាក់ **លោក ខ** ខ្ចីប្រាក់ចំនួនកំណត់ ហើយ **លោក ក** បានអះអាងថាគាត់បានដកប្រាក់ពីធនាគារតាមប្រាក់ដែលបានកំណត់ឱ្យខ្ចីនោះ មុនពេលឱ្យ **លោក ខ** ខ្ចី ហើយបន្ទាប់ពី **លោក ខ** បានទទួលប្រាក់ដែលខ្ចីនោះហើយ **លោក ខ** បានយកប្រាក់នោះទៅទិញរថយន្តមួយគ្រឿងដែលមានតម្លៃប្រហាក់ប្រហែលនឹងចំនួនប្រាក់ដែលបានខ្ចីនោះ។ ដូច្នេះហើយ អង្គហេតុដែលបានរៀបរាប់នៅក្នុងឧទាហរណ៍នេះ គឺជាអង្គហេតុប្រយោល។

ក្រោយពីបានសិក្សាស្វែងយល់ និង បានបំពេញគ្រប់លក្ខខណ្ឌដែលបានសិក្សាកន្លងមករហូតដល់ពេលដែលបានដាក់ពាក្យបណ្តឹងចូលទៅកាន់ស្ថាប័នតុលាការនេះ យើងនឹងធ្វើការសិក្សា និងអត្ថាធិប្បាយបន្តលើចំណុច ការទទួលពាក្យបណ្តឹង។

## ផ្នែកទី២៖ ការទទួលពាក្យបណ្តឹង

ចំពោះការអនុវត្តនាពេលមុនៗ ការទទួលពាក្យបណ្តឹង គឺក្រឡាបញ្ជីជាអ្នកទទួលបន្ទុកក្នុងការទទួលរាល់ពាក្យបណ្តឹងដែលបានដាក់ចូលមកស្ថាប័នតុលាការ ដោយត្រូវអនុវត្តតាមជំហានដូចជា៖

- វាយត្រាលើពាក្យបណ្តឹងដែលបានទទួល និង ចុះកាលបរិច្ឆេទនៃការទទួល។
- ចុះលេខរៀងនៅក្នុងសៀវភៅទទួលពាក្យបណ្តឹង និង នៅលើពាក្យបណ្តឹង។
- យកពាក្យបណ្តឹង និង ឯកសារពាក់ព័ន្ធមកដាក់បញ្ចូលក្នុងក្របសំណុំរឿង។
- បញ្ជូនសំណុំរឿងក្តីនោះទៅចៅក្រមទទួលបន្ទុកទៅតាមដីកាសម្រេចប្រចាំឆ្នាំ។

ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងប្រចាំថ្ងៃនៅតាមសាលាដំបូងរាជធានី និង ខេត្ត គឺបច្ចុប្បន្នស្ថាប័នតុលាការមាននូវលេខាធិការដ្ឋាន ដែលជាអង្គការសម្រាប់ជំនួយដល់ការងាររដ្ឋបាលរបស់ស្ថាប័នតុលាការ ហើយការងាររដ្ឋបាលទាំងអស់នោះ ក៏មានចំណុចដែលពាក់ព័ន្ធនឹងការទទួលពាក្យបណ្តឹងនេះដែរ។ ដោយសព្វថ្ងៃនេះលេខាធិការដ្ឋាន ដើរតួជាអ្នកទទួលពាក្យបណ្តឹង ដោយវាយត្រា និង ចុះកាលបរិច្ឆេទលើពាក្យបណ្តឹង រួមទាំងចុះលេខរៀងនៅក្នុងសៀវភៅទទួលពាក្យបណ្តឹង និង នៅលើពាក្យបណ្តឹង ហើយត្រូវយកពាក្យបណ្តឹង និង ឯកសារពាក់ព័ន្ធមកដាក់បញ្ចូលក្នុងក្របសំណុំរឿង និង ការបញ្ជូនសំណុំរឿងក្តីទៅចៅក្រមទទួលបន្ទុកទៅតាមដីកាសម្រេចប្រចាំឆ្នាំ។

យ៉ាងណាមិញ នៅមុនពេលដែលទទួលពាក្យបណ្តឹងមកធ្វើចំណាត់ការ អ្នកទទួលពាក្យបណ្តឹង(សម្តៅទៅលើក្រឡាបញ្ជី ឬ មន្ត្រីរបស់លេខាធិការដ្ឋាន) គួរពិនិត្យមើលពាក្យបណ្តឹងជាមុនសិន ហើយប្រសិនបើមានការខ្វះខាត អ្នកទទួលពាក្យបណ្តឹងគប្បីពន្យល់ណែនាំឱ្យអ្នកដាក់ពាក្យបណ្តឹងធ្វើការកែតម្រូវលើចំណុចខ្វះខាតដែលមាននោះ ហើយចំណុចដែលអ្នកទទួលពាក្យបណ្តឹងគប្បីពិនិត្យ និង ពន្យល់ដល់អ្នកដាក់ពាក្យបណ្តឹង គឺ៖

- ពិនិត្យលើពាក្យបណ្តឹងថា តើពាក្យបណ្តឹងនោះមានបានសរសេរត្រឹមត្រូវស្របតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៧៥ កថាខណ្ឌទី២ ដែរ ឬ ទេ?
- ប្រសិនបើខាងដើមចោទមានអ្នកតំណាងដោយអាណត្តិ ត្រូវពិនិត្យថា តើមានលិខិតបញ្ជាក់ ឬ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ដែរ ឬ ទេ?

បើទោះជាយ៉ាងក៏ដោយ អ្នកទទួលពាក្យបណ្តឹង គឺពុំមានសិទ្ធិនៅក្នុងការលើកពាក្យបណ្តឹងចោល ឬ មិនទទួលពាក្យបណ្តឹងដែលមិនត្រឹមត្រូវនោះបានទេ ពោលគឺមានតែតុលាការ(សម្តៅទៅលើចៅក្រម ឬ ក្រុមប្រឹក្សា

ជំនុំជម្រះ ដែលទទួលបន្ទុករឿងក្តីនោះ)ប៉ុណ្ណោះ ដែលមានសិទ្ធិអាចលើកពាក្យបណ្តឹងដែលមិនត្រឹមត្រូវនោះចោលបាន ដោយចេញដីកាសម្រេច[14]។ ដូចនេះ អ្នកទទួលពាក្យបណ្តឹងគ្រាន់តែអាចពន្យល់ឱ្យអ្នកដាក់ពាក្យបណ្តឹងកែតម្រូវតែប៉ុណ្ណោះ ហើយសិទ្ធិសម្រេចថាកែ ឬ មិនកែ គឺជាសិទ្ធិរបស់អ្នកដាក់ពាក្យបណ្តឹង។ ក្នុងករណីដែលអ្នកដាក់ពាក្យបណ្តឹងមិនព្រមកែតាមការពន្យល់ណែនាំរបស់អ្នកទទួលពាក្យបណ្តឹងទេនោះ អ្នកទទួលពាក្យបណ្តឹងក៏មិនអាចច្រានចោលដោយមិនទទួលពាក្យបណ្តឹងនោះបានទេ ពោលគឺត្រូវតែទទួលពាក្យបណ្តឹងនោះមកដដែរ និង ចាត់ការតាមនីតិវិធី ប៉ុន្តែក្នុងករណីនេះ អ្នកទទួលពាក្យបណ្តឹងគប្បីសរសេរជាកំណត់ចំណាំ ជាអាទិ៍នូវបញ្ហាដែលខ្លួនបានកត់សម្គាល់អំពីចំណុចខ្វះខាតនោះ ហើយដាក់ភ្ជាប់ជាមួយនឹងពាក្យបណ្តឹង ដើម្បីឱ្យចៅក្រមដែលទទួលបន្ទុកតាមការបែងចែករឿងក្តី ចាត់ការបន្ត។

ជាទូទៅនៅក្នុងពាក្យបណ្តឹងដែលអ្នកដាក់ពាក្យបណ្តឹងបានយកមកដាក់នៅស្ថាប័នតុលាការនេះ គឺរមែងតែងមាននូវឯកសារភ្ជាប់មកជាមួយ ទោះជាតិចក្តី ឬ ច្រើនក្តី ដោយឯកសារភ្ជាប់ទាំងអស់នោះ គឺដាក់អមជាមួយនឹងពាក្យបណ្តឹងដើម្បីបញ្ជាក់អំពីភស្តុតាងនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តរបស់ខ្លួន។ ម្យ៉ាងទៀត តុលាការគួរតែតម្រូវឱ្យដើមចោទ រៀបចំនូវលិខិតចម្លងនៃពាក្យបណ្តឹងទៅតាមចំនួននៃភាគីចុងចម្លើយជាការល្អ ដោយមូលហេតុថា តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទៅឱ្យចុងចម្លើយ[15]។

ដើមចោទគួរតែភ្ជាប់ជាមួយពាក្យបណ្តឹងនូវលិខិតចម្លងនៃឯកសារជាភស្តុតាងសំខាន់ៗ ដើម្បីបង្ការកុំឱ្យមានកំហុសនៅក្នុងការសរសេរអំពីអង្គហេតុជាក់លាក់ ហើយងាយស្រួលដល់តុលាការ ដើម្បីពិនិត្យ និង ធ្វើការរៀបចំ ឬ កំណត់នូវចំណុចវិវាទឱ្យបានឆាប់រហ័ស និង ចំណេញពេលវេលា ព្រមទាំងអាចឱ្យតុលាការប្រើប្រាស់លិខិតចម្លងនោះធ្វើជាភស្តុតាងបានផងដែរ។ ឧទាហរណ៍ទី១៖ ករណីវិវាទទាក់ទងទៅនឹងដីធ្លីមួយកន្លែង ដូចនេះដើមចោទគប្បីភ្ជាប់មកជាមួយនូវលិខិតចម្លងនៃប័ណ្ណកម្មសិទ្ធិ។ ឧទាហរណ៍ទី២៖ ករណីវិវាទទាក់ទងទៅនឹងឋានៈបុគ្គល ដូចនេះ ដើមចោទគប្បីភ្ជាប់មកជាមួយនូវលិខិតចម្លងនៃសំបុត្រអត្រានុកូលដ្ឋាន ឬ អត្តសញ្ញាណប័ណ្ណ ឬ ឯកសារបញ្ជាក់អំពីអត្តសញ្ញាណផ្សេងៗដែលអាចយកមកប្រើប្រាស់ជាផ្លូវការបានដូចជា លិខិតឆ្លងដែនជាដើម។ល។

ប្រសិនបើដើមចោទមានអ្នកតំណាងដោយអាណត្តិ ដើមចោទគប្បីភ្ជាប់មកជាមួយកុំបីខាននូវឯកសារបញ្ជាក់សិទ្ធិអំណាចអ្នកតំណាង[16] ឬ លិខិតបញ្ជាក់សិទ្ធិអ្នកតំណាងដោយអាណត្តិ ដែលគេហៅថាជា លិខិត

---

[14] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៨ កថាខណ្ឌទី២

[15] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៩ កថាខណ្ឌទី១

[16] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៥៣ កថាខណ្ឌទី២

ប្រគល់សិទ្ធិតំណាងដោយអាណត្តិ(អ្នកតំណាងដោយអាណត្តិជាមេធាវី)។ ចំណែកឯករណី ដែលដើមចោទមានអ្នកតំណាងដែលច្បាប់បានកំណត់វិញ ដូចជា ឪពុកម្ដាយ ដែលជាអ្នកតំណាងឱ្យកូនជាអនីតិជន ឬ អ្នកអាណាព្យាបាល គឺត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់សិទ្ធិតំណាងនោះ[17] ហើយសម្រាប់អ្នកតំណាងដែលជាឪពុកម្ដាយ លិខិតបញ្ជាក់នោះអាចជា សំបុត្រកំណើតរបស់កូន សៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅជាដើម។ ប៉ុន្តែសម្រាប់អ្នកតំណាងដែលជាអ្នកអាណាព្យាបាល លិខិតបញ្ជាក់នោះ គឺត្រូវតែជាសេចក្ដីសម្រេចរបស់តុលាការ។ ជាពិសេស ក្នុងករណី ដែលអ្នកតំណាង គឺជាអ្នកតំណាងនៃនីតិបុគ្គល លិខិតបញ្ជាក់នោះ ត្រូវតែជាលិខិតបញ្ជាក់សិទ្ធិតំណាង[18]។

លើសពីនេះទៅទៀត នៅពេលដែលដាក់ពាក្យបណ្ដឹងទៅតុលាការ ដើមចោទត្រូវតែបង់ពន្ធនៃការដាក់ពាក្យបណ្ដឹង ដោយគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្ដឹង ដូចមានចែងនៅក្នុងបញ្ញត្តិនៃមាត្រា៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែចំពោះបុគ្គលដែលគ្មានលទ្ធភាពទ្រព្យធន ដែលមិនអាចធ្វើនីតិវិធីបណ្ដឹងបាន ឬ ចំពោះបុគ្គលដែលអាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពដោយសារការបង់ប្រាក់ពន្ធនេះ តុលាការអាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្ដឹងតាមពាក្យសុំបាន[19]។ ឧទាហរណ៍៖ ដើមចោទបានដាក់ពាក្យបណ្ដឹង ទាមទារឱ្យចុងចម្លើយផ្ដល់នូវដីមួយកន្លែងដែលដើមចោទកំពុងរស់នៅសព្វថ្ងៃ ដោយបានធ្វើលទ្ធកម្មត្រឹមត្រូវតាមច្បាប់ រហូតដល់ទទួលបានកម្មសិទ្ធិពេញលេញស្របច្បាប់នៅលើដីនោះ ហើយនៅពេលដាក់ពាក្យបណ្ដឹងតុលាការបានធ្វើការគណនាពន្ធលើតម្លៃកម្មវត្ថុនៃបណ្ដឹង ដែលត្រូវជាបន្ទុករបស់ដើមចោទត្រូវបង់ពន្ធនោះទៅឱ្យតុលាការ ប៉ុន្តែ ដោយហេតុថា ដើមចោទ ជាជនក្រីក្រដែលពុំមានទ្រព្យធនគ្រប់គ្រាន់សម្រាប់ការបង់ពន្ធជូនតុលាការនោះទេ ពោលគឺពន្ធសម្រាប់ការដាក់ពាក្យបណ្ដឹងមានចំនួនច្រើនហួសសមត្ថភាពរបស់ដើមចោទ ដូចនេះ ដើមចោទអាចដាក់ពាក្យសុំឱ្យជួយសង្គ្រោះលើបណ្ដឹង ហើយតុលាការអាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្ដឹងតាមពាក្យសុំរបស់ដើមចោទនោះបាន។

ក្នុងករណីដែលកម្មវត្ថុនៃបណ្ដឹងមិនមែនជាប្រាក់ទេ គឺត្រូវកំណត់តម្លៃកម្មវត្ថុនៃបណ្ដឹងសិន មុននឹងធ្វើការគណនាពន្ធដាក់ពាក្យបណ្ដឹង។ ប៉ុន្តែចំពោះការអនុវត្តជាក់ស្ដែង គឺមានការលំបាកក្នុងការកំណត់តម្លៃលើកម្មវត្ថុនៃវិវាទអំពីដីធ្លី ពីព្រោះតែ ពុំមានស្ដង់ដារជាក់លាក់ណាមួយកំណត់ពីរបៀបនៃការវាយតម្លៃលើដីធ្លីនេះឡើយ ហើយវិធីងាយស្រួលសម្រាប់ការវាយតម្លៃលើកម្មវត្ថុនៃវិវាទដីធ្លី គឺតុលាការអាចពិចារណាលើតម្លៃដែលភាគីបាន

[17] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣៥ កថាខណ្ឌទី៣

[18] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣៨

[19] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៦៩

លើកឡើង ឬ តាមតម្លៃទីផ្សារដែលមានឯកសារជាសំអាង តែបើក្រោយមកតុលាការពិនិត្យឃើញថា ការកំណត់តម្លៃដីផ្លីវិវាទរបស់ភាគីដែលបានលើកឡើងនៅពេលដាក់ពាក្យបណ្ដឹង មានតម្លៃទាបជាងតម្លៃជាក់ស្ដែង ដូចនេះ តុលាការ ត្រូវយកពន្ធបន្ថែមទៀត ដោយគិតទៅតាមតម្លៃជាក់ស្ដែងនៃដីនៅពេលដាក់ពាក្យបណ្ដឹង។ បើទោះជាក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានចែងជាក់លាក់អំពីការយកពន្ធបន្ថែមលើពាក្យបណ្ដឹងនេះក៏ដោយ ក៏តុលាការ អាចចេញដីកាសម្រេចបង្គាប់ឱ្យបង់ពន្ធដាក់ពាក្យបណ្ដឹងបានដែរ ដោយផ្អែកទៅលើបញ្ញត្តិនៃមាត្រា៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកបច្ចុប្បន្ននេះ យើងឃើញថាក៏មាននូវក្រុមហ៊ុនមួយចំនួន ដែលមានជំនាញផ្នែកវាយតម្លៃលើវិស័យអចលនវត្ថុនេះដែរ ដូចនេះ តុលាការអាចធ្វើការសម្រេចឱ្យក្រុមហ៊ុននោះ ធ្វើការវាយតម្លៃលើអចលនវត្ថុនៃវិវាទបាន តាមការស្នើសុំរបស់ភាគី។ ក្រៅពីពន្ធដាក់ពាក្យបណ្ដឹងនេះ ដើមចោទក៏ត្រូវបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធដែរ [20] ។ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធមានដូចជា៖ ប្រាក់ចាំបាច់ដើម្បីធ្វើការពិនិត្យភស្តុតាង ការបញ្ជូនឯកសារ ឬ សកម្មភាពផ្សេងទៀតតាមនីតិវិធីក្នុងបណ្ដឹងរដ្ឋប្បវេណី និង សោហ៊ុយធ្វើដំណើរ សោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និង ក្រឡាបញ្ជី ក្នុងករណីដែលត្រូវធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬ សកម្មភាពផ្សេងទៀតដែលប្រព្រឹត្តទៅនៅក្រៅតុលាការ។ ចំពោះប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធនេះ តុលាការត្រូវបង្គាប់ឱ្យភាគី ឬ បុគ្គលដែលទាក់ទងនឹងរឿងក្ដី បង់ចំនួននោះជាមុន[21]។ ប៉ុន្តែនៅពេលដែលដាក់ពាក្យបណ្ដឹង ដើមចោទតែងតែត្រូវបានតុលាការតម្រូវឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធមួយចំនួនជាមុន ដើម្បីធ្វើការបញ្ជូនពាក្យបណ្ដឹង ឯកសារផ្សេងៗ ដីកាកោះ និង សោហ៊ុយផ្សេងទៀតដែលចាំបាច់ ហើយដែលអាចប៉ាន់ប្រមាណបាន ហើយចំនួនទឹកប្រាក់នោះ ត្រូវកំណត់តាមសភាពជាក់ស្ដែង។ ក្នុងករណីដែលដើមចោទពុំបានបង់នូវប្រាក់សម្រាប់បញ្ជូនពាក្យបណ្ដឹងទុកជាមុន[22] តុលាការត្រូវលើកបណ្ដឹងចោល ដោយដីកាសម្រេច[23]។ ម្យ៉ាងទៀតប្រសិនបើដើមចោទ មិនព្រមបង់ប្រាក់ចាំបាច់សម្រាប់ធ្វើការបញ្ជូនដីកាកោះហៅភាគីឱ្យចូលមកនៅកាលបរិច្ឆេទ ដែលតុលាការបានបង្គាប់ទេនោះ តុលាការអាចលើកបណ្ដឹងចោល ដោយដីកាសម្រេច ប្រសិនបើគ្មានការតវ៉ាពីសំណាក់ភាគីចុងចម្លើយ[24]។

---

[20] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៦២ កថាខណ្ឌទី១

[21] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៦២ កថាខណ្ឌទី៣

[22] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៩ កថាខណ្ឌទី២

[23] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៨ កថាខណ្ឌទី២

[24] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨២ កថាខណ្ឌទី១

## ផ្នែកទី៣៖ ការបែងចែករឿងក្តី

ដោយផ្អែកលើស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២៦ បានចែងអំពីការបែងចែងរឿងក្តី ដែលធានាបាននូវតម្លាភាពនៃការទទួលបន្ទុកដោះស្រាយសំណុំរឿងដោយចៅក្រមគ្រប់រូបក្នុងស្ថាប័នតុលាការ។

នៅតាមបណ្តាស្ថាប័នតុលាការនីមួយៗ ការបែងចែករឿងក្តី និង លំដាប់សម្រាប់ជំនួស នៅក្នុងករណីដែលចៅក្រមណាម្នាក់មានធុរៈ ត្រូវបានកំណត់ជាមុនរៀងរាល់ឆ្នាំ ដោយដីកាសម្រេចរបស់ប្រធានតុលាការ។ ដូចនេះចៅក្រម ឬ ក្រុមប្រឹក្សាជំនុំជម្រះ ត្រូវទទួលបន្ទុកជាស្វ័យប្រវត្តិដើម្បីដោះស្រាយរឿងក្តីទៅតាមលំដាប់សម្រាប់ចៅក្រមម្នាក់ និងលំដាប់សម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ។

ចំពោះរឿងក្តីដែលអាចធ្វើការជំនុំជម្រះដោយចៅក្រមម្នាក់ ឬ ដោយក្រុមប្រឹក្សាជំនុំជម្រះ គឺអាស្រ័យទៅតាមប្រភេទនៃរឿងក្តីដែលច្បាប់កំណត់ ឬ អាស្រ័យទៅតាមភាពស្មុគស្មាញនៃរឿងក្តីដែលទទួលស្គាល់ដោយតុលាការ។ ជាក់ស្តែង ប្រសិនបើជារឿងក្តីដែលច្បាប់បានកំណត់ថា ត្រូវធ្វើការវិនិច្ឆ័យ និង ជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ រឿងក្តីនោះត្រូវតែបែងចែកទៅឱ្យក្រុមប្រឹក្សាជំនុំជម្រះ ដែលមានសមាសភាពជាចៅក្រមចំនួនបីរូប ដោយធ្វើទៅតាមលំដាប់នៃការបែងចែករឿងក្តីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ[25]។ ឧទាហរណ៍៖ ប្រសិនបើមានបណ្តឹងជិតចិត្ត ឬ ពាក្យសុំដកហូតចំពោះចៅក្រមណាម្នាក់ រឿងក្តីនេះ ត្រូវតែវិនិច្ឆ័យ និងជំនុំជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ[26] ហេតុនេះ ត្រូវធ្វើការបែងចែករឿងក្តីប្រភេទនេះទៅឱ្យក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម តាមលំដាប់សម្រាប់ក្រុមប្រឹក្សាជំនុំជម្រះ។ ក្រៅពីនេះ គ្រប់រឿងក្តីទាំងអស់ គឺត្រូវធ្វើការបែងចែកទៅឱ្យចៅក្រមម្នាក់ដោយត្រូវធ្វើទៅតាមលំដាប់នៃការបែងចែករឿងក្តីសម្រាប់ចៅក្រម[27]។

ប៉ុន្តែចំពោះរឿងក្តីដែលមានតម្លៃកម្មវត្ថុនៃបណ្តឹងមិនតិចជាង ៥លានរៀល ហើយតុលាការទទួលស្គាល់ថាគួរតែត្រូវបានវិនិច្ឆ័យ និង ជម្រះដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម ដោយគិតពិចារណាអំពីចំនួននៃគូភាគី និងបញ្ហាផ្សេងទៀត [28] ។ ហើយប្រសិនបើរឿងក្តីនោះ ត្រូវបានចៅក្រមម្នាក់ទទួលបន្ទុកដោះស្រាយរឿងក្តីតាមលំដាប់របស់ចៅក្រម ដូចនេះចៅក្រមនោះអាចស្នើសុំឱ្យមានការជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះបាន ដោយយោងទៅលើចំនួនភាគី និងបញ្ហាផ្សេងទៀត។ ក្នុងករណីនេះ ការសម្រេចថាតើរឿងក្តីនោះត្រូវវិនិច្ឆ័យ និង ជម្រះ

[25] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៣ កថាខណ្ឌទី២ ចំណុច ខ

[26] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣០ កថាខណ្ឌទី១

[27] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៣ កថាខណ្ឌទី១

[28] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៣ កថាខណ្ឌទី២ ចំណុច ក

ក្តីដោយក្រុមប្រឹក្សាជំនុំជម្រះ ឬ ចៅក្រមម្នាក់ ត្រូវធ្វើតាមដីកាសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ[29]។ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះ សម្រេចថារឿងក្តីត្រូវវិនិច្ឆ័យ និងជម្រះក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនោះ ក្រុមប្រឹក្សាជំនុំជម្រះនឹងចេញដីកាសម្រេច។ ប៉ុន្តែ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា រឿងក្តីត្រូវវិនិច្ឆ័យ និងជម្រះក្តីដោយចៅក្រមម្នាក់នោះ ក្រុមប្រឹក្សាជំនុំជម្រះនឹងមិនចេញដីកាសម្រេចទេ ដោយឱ្យចៅក្រមដែលទទួលបន្ទុកដោះស្រាយរឿងក្តីនោះ បន្តទទួលបន្ទុកដោះស្រាយរឿងក្តីនោះតាមនីតិវិធីដដែរ។

## ផ្នែកទី៤៖ ការពិនិត្យពាក្យបណ្តឹង

ដោយអនុលោមតាមបញ្ញត្តិនៃមាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា នៅពេលដែលរឿងក្តីត្រូវបានបញ្ជូនមកដល់សមត្ថកិច្ចរបស់ចៅក្រមម្នាក់ ឬ ក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមរួចហើយនោះ តុលាការត្រូវធ្វើការពិនិត្យលើពាក្យបណ្តឹង ថាតើពាក្យបណ្តឹងនោះបានធ្វើឡើងត្រឹមត្រូវតាមលក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាហើយ ឬ នៅ?

នៅក្នុងការពិនិត្យពាក្យបណ្តឹងនេះ មានលក្ខណៈពិសេស២យ៉ាងគឺ៖

- ការពិនិត្យពាក្យបណ្តឹងដើម្បីចេញដីកាបង្គាប់ឱ្យកែតម្រូវ ប្រសិនបើពាក្យបណ្តឹងនោះ ពុំបានធ្វើឡើងត្រឹមត្រូវតាមលក្ខខណ្ឌនៃមាត្រា៧៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា និងដើម្បីចេញដីកាសម្រេចលើកបណ្តឹងចោល ប្រសិនបើដើមចោទពុំបានកែតម្រូវពាក្យបណ្តឹងទៅតាមដីកាបង្គាប់ឱ្យកែតម្រូវរបស់តុលាការ ឬ ដោយដើមចោទពុំបានបង់ពន្ធដាក់ពាក្យបណ្តឹងដូចមានចែងនៅក្នុងមាត្រា៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា។
- ការពិនិត្យពាក្យបណ្តឹងដើម្បីដឹកនាំរឿងក្តីឱ្យបានឆាប់រហ័ស គឺត្រូវពិនិត្យថា តើអង្គហេតុដែលជាមូលហេតុនៃការទាមទារ អង្គហេតុសំខាន់ៗដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងភស្តុតាងជាឯកសារសំខាន់ៗ ជាអាទិ៍ មានសរសេរ និង ភ្ជាប់មកជាមួយពាក្យបណ្តឹងហើយ ឬ នៅ? ការពិនិត្យបែបនេះ គឺមានបំណងចង់ឱ្យការចាត់ការរឿងក្តីមានប្រសិទ្ធភាព អាចមានលក្ខណៈងាយស្រួលដល់ការរៀបចំ ឬ កំណត់ចំណុចវិវាទ និង មានភាពឆាប់រហ័សនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

ជាទូទៅ នៅពេលដែលតុលាការពិនិត្យឃើញនូវចំណុចខ្វះខាតក្នុងពាក្យបណ្តឹងនោះ តុលាការគប្បីណែនាំឱ្យដើមចោទកែតម្រូវនូវចំណុចខ្វះខាតនោះដោយឆន្ទានុសិទ្ធិ តាមរយៈអ្នកទទួលពាក្យបណ្តឹង ហើយបើដើមចោទមិនព្រមធ្វើការកែតម្រូវនូវចំណុចខ្វះខាតតាមការណែនាំនោះទេ តុលាការត្រូវពិចារណាទៅតាមស្ថានភាពនៃចំណុចខ្វះខាតនោះ។ ក្នុងករណីនេះ តុលាការត្រូវចេញដីកាបង្គាប់ឱ្យកែតម្រូវជាមុនសិន ដោយកំណត់

[29] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៣ កថាខណ្ឌទី៤

នៅអំឡុងពេលសមរម្យ ហើយបើដើមចោទនៅតែមិនព្រមកែតម្រូវតាមដីកាបង្គាប់ឱ្យកែតម្រូវនេះទៀត តុលាការត្រូវលើកពាក្យបណ្តឹងនោះចោល ដោយដីកាសម្រេច។ ម្យ៉ាងទៀត ក្នុងករណីដែលដើមចោទមិនបានបង់ពន្ធដាក់ពាក្យបណ្តឹង ឬ ក្នុងករណីដែលពាក្យបណ្តឹងមិនអាចបញ្ជូនទៅបាន ដោយដើមចោទមិនបានបង់ប្រាក់សម្រាប់ធ្វើការបញ្ជូនពាក្យបណ្តឹងទុកជាមុន[30] តុលាការត្រូវអនុវត្តនីតិវិធីដូចគ្នា គឺតុលាការត្រូវលើកពាក្យបណ្តឹងនោះចោល ដោយដីកាសម្រេច។

ផ្ទុយមកវិញ បើដើមចោទមិនបានកែតម្រូវតាមការណែនាំរបស់អ្នកទទួលពាក្យបណ្តឹង ដោយឆន្ទានុសិទ្ធិនូវចំណុចដែលគប្បីសរសេរនៅក្នុងពាក្យបណ្តឹងដូចមានចែងនៅក្នុងមាត្រា៧៥ កថាខណ្ឌទី៣នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដោយ ក៏តុលាការមិនអាចលើកពាក្យបណ្តឹងនោះចោលបានដែរ ហើយតុលាការត្រូវតែបន្តនីតិវិធី ដោយធ្វើការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលលើកទី១ ដើម្បីអាចទាមទារឱ្យដើមចោទពន្យល់បន្ថែម នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីនោះ។

## ផ្នែកទី៥៖ ការពិនិត្យលក្ខខណ្ឌបណ្តឹង

លក្ខខណ្ឌនៃបណ្តឹង គឺសម្តៅទៅលើលក្ខខណ្ឌដើម្បីឱ្យតុលាការអាចចេញសាលក្រម ដែលសម្រេចអំពីរឿងក្តីអង្គសេចក្តី ហើយលក្ខខណ្ឌបណ្តឹងសំខាន់ៗមានដូចជា៖

- តុលាការនៃព្រះរាជាណាចក្រកម្ពុជា ជាតុលាការដែលមានសមត្ថកិច្ចជំនុំជម្រះ
- តុលាការដែលចាត់ការ ត្រូវមានសមត្ថកិច្ចលើរឿងក្តីនោះ
- មានភាគីពិតប្រាកដ ហើយមានសមត្ថភាពភាគី[31]
- មានផលប្រយោជន៍នៃបណ្តឹង[32] មានន័យថាមានផលប្រយោជន៍ ឬ ភាពចាំបាច់តាមផ្លូវច្បាប់រវាងភាគីនៃបណ្តឹង ក្នុងការទាមទារឱ្យតុលាការចេញសាលក្រមស្តីពីការទាមទារតាមផ្លូវបណ្តឹងដែលត្រូវបានបង្ហាញក្នុងបណ្តឹងដោយដើមចោទ។
- បណ្តឹងដែលច្បាប់មិនបានហាមឃាត់ ចំណុចនេះគឺសំខាន់ ដោយសារតែមានបណ្តឹងមួយចំនួនដែលត្រូវបានច្បាប់ហាមឃាត់មិនឱ្យធ្វើឡើងនោះទេ។ ឧទាហរណ៍៖ ការហាមបណ្តឹងជាន់គ្នា[33] ការហាមមិនឱ្យធ្វើបណ្តឹងតបនៅក្នុងរឿក្តីចំនួនទឹកប្រាក់តិច[34] ជាដើម។

---

[30] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៩ កថាខណ្ឌទី២

[31] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣២

[32] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៤

[33] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨៣

[34] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២៧

➢ ពុំមានការហាមឃាត់នូវការធ្វើបណ្ដឹងនោះតាមរយៈកិច្ចសន្យារវាងភាគីនោះទេ ពោលគឺពុំមានការព្រមព្រៀងគ្នារវាងភាគីនៃកិច្ចសន្យាថា មិនទាមទារឱ្យអនុវត្តតាមផ្លូវតុលាការ[35] នោះទេ។

ក្នុងករណីដែលមានកង្វះលក្ខខណ្ឌនៃបណ្ដឹង ហើយពុំអាចកែតម្រូវបាន តុលាការអាចលើកបណ្ដឹងចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បាន[36]។ ក្នុងករណីដែលមានភាពមិនស្របនឹងលក្ខខណ្ឌនៃបណ្ដឹងច្បាស់លាស់នៅដំណាក់កាលនៃការដាក់ពាក្យបណ្ដឹង តុលាការត្រូវចាត់ការរឿងក្ដីនោះតាមរយៈសាលក្រមលើកបណ្ដឹងចោល ហេតុនេះហើយ ពេលទទួលពាក្យបណ្ដឹង តុលាការត្រូវពិនិត្យលក្ខខណ្ឌនៃបណ្ដឹងនោះ។

សាលក្រមលើកបណ្ដឹងចោល និង ដីកាសម្រេចលើកបណ្ដឹងចោល មានលក្ខណៈខុសគ្នាដូចជា សាលក្រមលើកបណ្ដឹងចោល គឺជាសាលក្រមដែលចេញក្នុងករណីដែលបណ្ដឹងមានលក្ខណៈផ្ទុយនឹងច្បាប់ ពោលគឺជាសាលក្រមដែលមានខ្លឹមសារលើកបណ្ដឹងចោលក្នុងករណីដែលបណ្ដឹងនោះខ្វះនូវលក្ខខណ្ឌនៃបណ្ដឹង។ រីឯដីកាសម្រេចលើកពាក្យបណ្ដឹងចោលវិញ គឺជាដីកាសម្រេចដែលមានខ្លឹមសារលើកពាក្យបណ្ដឹងចោល ក្នុងករណីដែលពាក្យបណ្ដឹងនោះមានកង្វះនូវចំណុចដែលតម្រូវឱ្យសរសេរ ហើយតុលាការបានបង្គាប់ឱ្យកែតម្រូវ ប៉ុន្តែដើមចោទ មិនបានកែតម្រូវនូវចំណុចខ្វះខាតនោះ តាមការបង្គាប់របស់តុលាការ ឬ ក្នុងករណីដែលដើមចោទមិនបានបង់ពន្ធសម្រាប់ដាក់ពាក្យបណ្ដឹង។

លក្ខណៈពិសេសដែលតុលាការមិនអាចចេញដីកាសម្រេចលើកពាក្យបណ្ដឹងចោលបានទេ ក្នុងករណីដែលពាក្យបណ្ដឹងបានបញ្ជូនទៅចុងចម្លើយរួចហើយ បើទោះជាពាក្យបណ្ដឹងនោះមានចំណុចខ្វះខាតក៏ដោយ។ ដូចនេះបើសិនជាមានកង្វះលក្ខខណ្ឌនៃបណ្ដឹង តុលាការត្រូវចេញសាលក្រមលើកបណ្ដឹងចោល។

## ផ្នែកទី៦៖ ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផលលើកដំបូង

បន្ទាប់ពីបានធ្វើការពិនិត្យបណ្ដឹងរួចរាល់អស់ហើយ ប្រសិនបើតុលាការយល់ឃើញថាពាក្យបណ្ដឹងនោះត្រឹមត្រូវស្របតាមច្បាប់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង និង ចេញដីកាកោះហៅភាគីទាំងសងខាងឱ្យបង្ហាញខ្លួននៅតុលាការ តាមកាលបរិច្ឆេទដែលបានកំណត់។

ការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង តុលាការត្រូវកំណត់ក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងត្រូវបានដាក់យ៉ាងឆាប់រហ័ស និង កោះហៅគូភាគី

[35] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា៣៨៥ កថាខណ្ឌទី២

[36] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨១

លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស [37] ដែលតុលាការយល់ឃើញថាចាំបាច់ ទើបអាចកំណត់អំឡុងពេលលើសពី៣០(សាមសិប)ថ្ងៃបាន។ ឧទាហរណ៍ដូចជាៈ ភាពស្មុគស្មាញនៃសំណុំរឿង, ការបញ្ជូនដីកាកោះហៅ ឬ ឯកសារត្រូវការអំឡុងពេលវែង ដោយសារតែទីលំនៅរបស់ចុងចម្លើយនៅឆ្ងាយ ឬ នៅបរទេស, ឬ ការទាមទាររយៈពេលដើម្បីធ្វើការកែតម្រូវពាក្យបណ្ដឹងជាដើម។

## ផ្នែកទី៧ៈ ការបញ្ជូនពាក្យបណ្ដឹង

ជាគោលការណ៍ ពាក្យបណ្ដឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់[38] ព្រោះថាការបញ្ជូនពាក្យបណ្ដឹង គឺជាការផ្ដល់ឱកាសឱ្យភាគីម្ខាងទៀត ឬ ចុងចម្លើយ បានដឹងអំពីអ្នកប្ដឹង កម្មវត្ថុនៃបណ្ដឹង និង មធ្យោបាយតទល់របស់អ្នកប្ដឹងជាដើម ហើយក៏ជាការផ្ដល់ឱកាសឱ្យភាគីម្ខាងទៀត ឬ ចុងចម្លើយ បានត្រៀមខ្លួនឆ្លើយដោះសារ និង រៀបចំមធ្យោបាយសម្រាប់ការពារខ្លួនផងដែរ។ ក្នុងករណីដែលពាក្យបណ្ដឹងមិនអាចបញ្ជូនទៅបាន ដូចជាក្នុងករណីដែលអាសយដ្ឋានរបស់ចុងចម្លើយ ដែលដើមចោទបានផ្ដល់ឱ្យ ឬ បានសរសេរនៅក្នុងពាក្យបណ្ដឹងមិនមានភាពច្បាស់លាស់ ឬ ករណីដែលចុងចម្លើយជាអសមត្ថជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ ករណីដែលចុងចម្លើយជាជនបរទេសដែលមានអភ័យឯកសិទ្ធិ ហើយបដិសេធការទទួលនៃការបញ្ជូនពាក្យបណ្ដឹង តុលាការត្រូវធ្វើការបង្គាប់ឱ្យដើមចោទកែតម្រូវនូវអាសយដ្ឋាន ឬ ព័ត៌មាននោះ។ ប្រសិនបើដើមចោទមិនកែតម្រូវទេ តុលាការត្រូវលើកពាក្យបណ្ដឹងចោល ដោយដីកាសម្រេច[39]។

រឿងក្ដី ត្រូវបានចាត់ការតាមរយៈការបញ្ជូនពាក្យបណ្ដឹង ហើយការចាត់ការរឿងក្ដីនេះ គឺជាទស្សនៈមួយសំខាន់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ដោយមានមាត្រាមួយចំនួនដែលមានការប្រើពាក្យចាត់ការរឿងក្ដី។ ជាក់ស្ដែងដូចជានៅក្នុងមាត្រា៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាមានចែងថា ក្រោយពេលដែលតុលាការចាត់ការរឿងក្ដីហើយ ភាគីមិនអាចប្ដឹងទៀតបានឡើយ។ ជាងនេះទៅទៀត សាលក្រមស្ថាពរមានអានុភាពចំពោះបុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ក្រោយពីបណ្ដឹងត្រូវបានចាត់ការ[40]។ ម៉្យាងទៀត រឿងក្ដីមិនទាន់ត្រូវបានចាត់ការ តាមរយៈការដាក់ពាក្យបណ្ដឹងទេ ប៉ុន្តែតាមរយៈការដាក់ពាក្យបណ្ដឹងនេះ រឿងក្ដីត្រូវបានចាប់ផ្ដើម ដោយអាចបកស្រាយថា មានអានុភាពផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល[41]។

---

[37] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨០

[38] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៩ កថាខណ្ឌទី១

[39] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៧៩ កថាខណ្ឌទី២

[40] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៩៨ ចំណុច គ

[41] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៤៨៩ កថាខណ្ឌទី១

ជាទូទៅ ដើម្បីឱ្យការអនុវត្តមានលក្ខណៈងាយស្រួល តុលាការត្រូវធ្វើការបញ្ជូនពាក្យបណ្ដឹង ព្រមទាំងដីកាកោះសម្រាប់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ទៅឱ្យចុងចម្លើយ។

# ជំពូកទី២
# នីតិវិធីនៃការជំនុំជម្រះក្តី

ក្រោយពីបានបញ្ចប់នូវនីតិវិធីនៃការចាប់ផ្តើមបណ្តឹងរួចរាល់ហើយ នីតិវិធីនៃការជំនុំជម្រះក្តី ក៏ត្រូវបានចាប់ផ្តើមស្របតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាផងដែរ ដោយនីតិវិធីនៃការជំនុំជម្រះក្តីនេះមានដូចជា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការទាញហេតុផលដោយផ្ទាល់មាត់ និងការបញ្ចប់បណ្តឹង។ ដូចនេះយើងនឹងធ្វើការសិក្សា និងអត្ថាធិប្បាយបន្តលើនីតិវិធីនៃការជំនុំជម្រះក្តីដូចតទៅ៖

### ផ្នែកទី១៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជានីតិវិធីរៀបចំនូវការអះអាងរបស់ភាគី និងរៀបចំ ឬ កំណត់នូវចំណុចវិវាទនៃរឿងក្តី ព្រមទាំងរៀបចំនូវភស្តុតាងដែលពាក់ព័ន្ធនឹងចំណុចវិវាទ ដើម្បីឱ្យតុលាការអាចធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់[42]។ ហើយនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមាន ប៉ុន្តែមិនចាំបាច់ទាមទារឱ្យធ្វើជាសាធារណៈឡើយ[43] ដោយជាធម្មតា គឺគេប្រើបន្ទប់ក្រៅពីសាលសវនាការ ដូចជាការអនុវត្តជាក់ស្តែង គឺគេប្រើប្រាស់បន្ទប់របស់ចៅក្រម ដើម្បីធ្វើនីតិវិធីនេះ ជាអាទិ៍។

ជាគោលការណ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការមិនអាចធ្វើការពិនិត្យភស្តុតាងបានទេ លុះត្រាតែការពិនិត្យភស្តុតាងនោះ គឺជាការពិនិត្យភស្តុតាងជាឯកសារ ដែលជាករណីចាំបាច់ត្រូវរៀបចំ ឬ កំណត់នូវចំណុចវិវាទ និង ភស្តុតាង[44] ដូចនេះ តុលាការអាចធ្វើការពិនិត្យភស្តុតាងជាឯកសារបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ផ្ទុយមកវិញ ចំពោះការពិនិត្យភស្តុតាងដទៃទៀត ដូចជា ការសាកសួរសាក្សី, ការសាកសួរសាមីភាគី, ការធ្វើកោសលវិច័យ និង ការត្រួតពិនិត្យ គឺមិនអាចធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។

ហេតុដូច្នេះហើយ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និង រៀបចំភស្តុតាងដែលទាក់ទងនឹង

---

[42] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៣

[43] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៥

[44] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៦

ចំណុចវិវាទនៃរឿងក្ដីនោះ ដើម្បីអាចធ្វើការវិនិច្ឆ័យរឿងក្ដីនៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ឱ្យបានល្អិតល្អន់[45]។

**កថាខណ្ឌទី១៖ គោលការណ៍ចំពោះមុខ និងគោលការណ៍បើកជាសាធារណៈ**

តុលាការត្រូវតែគោរពនូវគោលការណ៍ចំពោះមុខនេះ បើទោះជានៅក្នុងករណីណាក៏ដោយ[46] ហេតុដូចនេះហើយ ទើបនៅក្នុងមាត្រា១០៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មានចែងថា នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន[47]។

ចំណែកឯ គោលការណ៍បើកជាសាធារណៈ ចំពោះនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលមិនចាំបាច់ធ្វើជាសាធារណៈនោះទេ ប៉ុន្តែតុលាការអាចអនុញ្ញាតឱ្យអ្នកដែលតុលាការយល់ឃើញថាសមរម្យ ចូលស្ដាប់ជាអ្នកសង្កេតការណ៍បាន[48] ដោយតុលាការត្រូវចេញដីកាសម្រេចអនុញ្ញាតឱ្យ ដោយផ្អែកលើកត្តាផ្សេងៗ ដូចជាមូលហេតុដែលជននោះចង់ចូលស្ដាប់ ហើយតុលាការត្រូវពិចារណាថា តើការចូលស្ដាប់របស់អ្នកសង្កេតការណ៍នោះមានឧបសគ្គនៅក្នុងនីតិវិធី ដែរ ឬ ទេ? ឬ ក៏តុលាការអាចសម្រេចឱ្យអ្នកសង្កេតការណ៍ចូលស្ដាប់បាន ដោយផ្អែកលើយោបល់របស់ភាគី។ ក្នុងករណីដែលភាគីមានគ្រួសារ ឬ អ្នកមានជាប់ទាក់ទងនឹងផលប្រយោជន៍វិញ តុលាការច្រើនតែអនុញ្ញាតឱ្យចូលស្ដាប់ បើសិនជាពុំមានផលប៉ះពាល់ ឬ ឧបសគ្គដល់នីតិវិធីទេ។

**កថាខណ្ឌទី២៖ សកម្មភាពបណ្ដឹងដែលអាចធ្វើនៅក្នុងនីតិវិធី**

ដោយផ្អែកតាមស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគីយល់មិនស្របគ្នា និងរៀបចំភស្ដុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដីនោះ ដូច្នេះហើយ តុលាការត្រូវធ្វើសកម្មភាពដូចជា៖

- ឱ្យភាគីធ្វើការអះអាងដោយខ្លួនឯង ហើយឱ្យភាគីម្ខាងទៀតធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការអះអាងនោះ ដោយការអះអាងនោះមានដូចជា ឱ្យភាគីធ្វើសេចក្ដីថ្លែងការណ៍អំពីពាក្យបណ្ដឹង, ឯកសារចម្លើយ និង ឯកសារត្រៀម។

---

[45] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៣

[46] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣ កថាខណ្ឌទី២

[47] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៥ កថាខណ្ឌទី១

[48] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៥ កថាខណ្ឌទី២

➢ ឱ្យភាគីស្នើសុំដាក់ភស្តុតាង ប៉ុន្តែភស្តុតាងនោះ មិនត្រូវបានធ្វើការពិនិត្យនៅក្នុងនីតិវិធីនេះទេ លើកលែងតែមានភាពចាំបាច់ត្រូវរៀបចំចំណុចវិវាទ និង ភស្តុតាង ទើបតុលាការធ្វើការពិនិត្យលើភស្តុតាងជាឯកសារនោះ។

ជាងនេះទៅទៀត ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១០៦ មានចែងថា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការអាចធ្វើសកម្មភាពដូចខាងក្រោមនេះ៖

➢ ចេញដីកាសម្រេចដែលទាក់ទងនឹងការស្នើសុំពិនិត្យភស្តុតាងដូចជា ចេញដីកាសម្រេចទទួល ឬ មិនទទួលការស្នើសុំឱ្យពិនិត្យភស្តុតាង[49] ឬ ចេញដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ[50]។

➢ ចេញដីកាសម្រេចផ្សេងទៀត ដែលអាចធ្វើនៅក្រៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល (មាត្រា១០៦) ឧទាហរណ៍ដូចជា ដីកាសម្រេចអនុញ្ញាតឱ្យប្តូរបណ្តឹង[51] ឬ ដីកាសម្រេចអនុញ្ញាតឱ្យចូលរួមជួយអន្តរាគមន៍[52] ជាអាទិ៍។

➢ អាចធ្វើការពិនិត្យភស្តុតាងដែលជាឯកសារក្នុងកម្រិតចាំបាច់ដើម្បីរៀបចំ ឬ កំណត់នូវចំណុចវិវាទ និង ភស្តុតាងបាន។ ដោយឡែក នីតិវិធីនៃការពិនិត្យភស្តុតាងនេះ គឺត្រូវធ្វើនៅក្នុងនីតិវិធីនៃការទាញហេតុដោយផ្ទាល់មាត់ ដែលត្រូវធ្វើជាសាធារណៈ។ យ៉ាងណាមិញ ការពិនិត្យភស្តុតាងជាឯកសារ គឺជាការអានឯកសារដោយចៅក្រម ដូចនេះហើយ បើសិនជាប្រៀបធៀបទៅនឹងការសាកសួរសាក្សីវិញ ការពិនិត្យភស្តុតាងជាឯកសារនេះ មិនសូវមានទំនាក់ទំនងខ្លាំងទៅនឹងគោលការណ៍បើកជាសាធារណៈនោះទេ ហើយដើម្បីរៀបចំនូវចំណុចវិវាទឱ្យបានត្រឹមត្រូវ គឺមានករណីជាច្រើនដែលចាំបាច់ក្នុងការពិនិត្យភស្តុតាងជាឯកសារ ហេតុនេះហើយ ក្រមនេះអនុញ្ញាតឱ្យពិនិត្យភស្តុតាងជាឯកសារ ដោយមានកម្រិតចាំបាច់ដើម្បីរៀបចំចំណុចវិវាទនៃរឿងក្តី នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។ ក្រៅពីនេះ ភាគីអាចដកពាក្យបណ្តឹង ដោយធ្វើការសះជាគ្នាបាន ដោយលះបង់ការទាមទារ និងទទួលស្គាល់នូវការទាមទារជាដើម។

ម្យ៉ាងទៀត ភាគីត្រូវធ្វើការស្រាវជ្រាវឱ្យបានលម្អិតជាមុន នូវទំនាក់ទំនងនៃអង្គហេតុ ចំពោះសាក្សី និង ភស្តុតាងផ្សេងៗ ដើម្បីធ្វើការអះអាង និង បញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងបណ្តឹង[53]។ ដើម្បីធ្វើការអះអាង និង បញ្ជាក់ឱ្យបានគ្រប់ជ្រុងជ្រោយនៅកាលបរិច្ឆេទ ភាគីទាំងសងខាងត្រូវស្រាវជ្រាវអំពីអង្គហេតុ ដែល

---

[49] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៦

[50] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៥២

[51] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨៤

[52] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៤៥ កថាខណ្ឌទី១

[53] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩២

ជាមូលដ្ឋាននៃការបញ្ជាក់ភស្តុតាងនៃការអះអាងរបស់ខ្លួន នៅក្រៅកាលបរិច្ឆេទ ដោយនេះគឺជាសកម្មភាព សម្រាប់ទូទាំងនីតិវិធីបណ្តឹង ហើយដើម្បីឱ្យការអះអាង និង ការបញ្ជាក់ មានដំណើរការលឿន ដែលតុលាការរំពឹងថា ភាគីទាំងសងខាងបានខំប្រឹងប្រែងស្រាវជ្រាវអំពីអង្គហេតុ ហើយធ្វើសកម្មភាពបណ្តឹងនៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

ជាពិសេស តុលាការប្រើសិទ្ធិដឹកនាំបណ្តឹង និង សិទ្ធិបំភ្លឺ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលសម្រាប់ដំណាក់កាលនៃការរៀបចំនូវការអះអាង និង រៀបចំភស្តុតាង។

សិទ្ធិដឹកនាំបណ្តឹង គឺជាសិទ្ធិរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដោយត្រូវដឹកនាំ ចាត់ចែងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ត្រូវដឹកនាំ ចាត់ចែងការទាញហេតុផលដោយផ្ទាល់មាត់[54] ប្រសិនបើការជំនុំជម្រះរឿងក្តី ត្រូវបានធ្វើឡើងដោយក្រុមប្រឹក្សាជំនុំជម្រះ។ ប៉ុន្តែប្រសិនបើ ការជំនុំជម្រះរឿងក្តី ត្រូវបានធ្វើឡើងដោយចៅក្រមទោល ដូចនេះចៅក្រមនោះ គឺជាអ្នកអនុវត្តសិទ្ធិដឹកនាំបណ្តឹង។

ចំណែកឯ សិទ្ធិបំភ្លឺ គឺជាសិទ្ធិរបស់តុលាការ ដែលអាចសាកសួរភាគី ឬ ឱ្យភាគីអះអាង ឬ បញ្ជាក់ភស្តុតាង ដើម្បីឱ្យចំណុចនៃអង្គហេតុ និង អង្គច្បាប់ដែលទាក់ទងទៅនឹងបណ្តឹង មានភាពច្បាស់លាស់ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់[55]។ ចំពោះការទាមទារ ការអះអាង ការបញ្ជាក់ភស្តុតាងរបស់ភាគី ប្រសិនបើមានចំណុចណាដែលមិនស្របគ្នា ឬ មិនច្បាស់លាស់ ឬ មិនគ្រប់គ្រាន់នោះ តុលាការអាចសួរអំពីចំណុចនោះ ឬ អាចដាស់តឿនឱ្យភាគីដាក់ភស្តុតាងបាន។ ដោយការប្រើសិទ្ធិបំភ្លឺនេះឱ្យបានសមស្រប គឺជាការចាំបាច់ដើម្បីរៀបចំនូវការអះអាង និង ភស្តុតាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដើម្បីរកចំណុចវិវាទពិតប្រាកដ។

ជាគោលការណ៍នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ភាគីត្រូវធ្វើសកម្មភាពបណ្តឹងដោយគំនិតខ្លួន ឧទាហរណ៍ដូចជា៖ គោលការណ៍នៃសិទ្ធិចាត់ចែង ឬ គោលការណ៍នៃការទាញហេតុផល។

យ៉ាងណាមិញ គេសង្ឃឹមថា តុលាការអាចនឹងប្រើសិទ្ធិបំភ្លឺនេះឱ្យបានត្រឹមត្រូវតាមវិសាលភាពឱ្យមានយុត្តិធម៌ ដើម្បីឱ្យភាគីទាំងសងខាងអាចធ្វើការទាញហេតុផលឱ្យបានពេញលេញ មានន័យថា សិទ្ធិបំភ្លឺ គឺជាសិទ្ធិដែលតុលាការអាចបំពេញបន្ថែមលើ គោលការណ៍នៃសិទ្ធិចាត់ចែង និង គោលការណ៍នៃការទាញហេតុផល។

---

[54] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨៩

[55] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩០

**កថាខណ្ឌទី៣៖ កំណត់ហេតុនៃនីតិវិធី**

នៅក្នុងកាលបរិច្ឆេទនៃការត្រៀមសម្រាប់ការទាញហេតុផលនីមួយៗ គឺចៅក្រម ភាគី អ្នកតំណាងរបស់ភាគី ឬ អ្នកជំនួយការ ជាអាទិ៍ ធ្វើសកម្មភាពបណ្តឹងជាច្រើនប្រភេទ ហើយខណៈពេលនោះផងដែរ ក្រឡាបញ្ជីមានកាតព្វកិច្ចត្រូវធ្វើកំណត់ហេតុ [56] ។ កំណត់ហេតុនេះមានសារៈសំខាន់ណាស់ សម្រាប់តុលាការជាន់ខ្ពស់ នៅពេលដែលតុលាការជាន់ខ្ពស់ធ្វើការពិនិត្យការជំនុំជម្រះនៅតុលាការដើម។

នៅក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប្រធានក្រុមប្រឹក្សាជំនុំជម្រះ និង ក្រឡាបញ្ជីត្រូវចុះហត្ថលេខា ប៉ុន្តែប្រសិនបើចៅក្រមជំនុំជម្រះ គឺជាចៅក្រមទោល ដូចនេះចៅក្រមនោះត្រូវចុះហត្ថលេខា។ ផ្ទុយមកវិញ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចំពោះភាគីនៃបណ្តឹង អ្នកតំណាង អ្នកជំនួយការ ឬ អ្នកបកប្រែ មិនបានតម្រូវឱ្យចុះហត្ថលេខានោះទេ។

ម៉្យាងទៀត ចំពោះចំណុចដែលត្រូវសរសេរនៅក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺមានចែងនៅក្នុងមាត្រា១១០ និងមាត្រា១១១ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាដែលមានដូចជា ចំណុចជារូបមន្ត និង ចំណុចសារធាតុ ៖

ចំណុចជារូបមន្ត គឺត្រូវកត់ត្រាអំពី៖

- សញ្ញាណរឿងក្តី។
- ឈ្មោះចៅក្រម និង ក្រឡាបញ្ជី។
- ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន។
- ពេលវេលា និង ទីកន្លែង។

ចំណុចសារធាតុ គឺត្រូវកត់ត្រាអំពីសេចក្តីសង្ខេបអំពីសកម្មភាពដែលបានធ្វើឡើងនៅកាលបរិច្ឆេទនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចដែមមានដូចជា៖

- ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និង ចម្លើយតបរបស់ចុងចម្លើយចំពោះការទាមទារនោះ។
- ខ្លឹមសារនៃអង្គហេតុដែលបានអះអាង និង ការស្នើសុំឱ្យពិនិត្យភស្តុតាង។
- ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះអង្គហេតុដែលបានអះអាងដោយភាគីម្ខាងទៀត និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះភាពត្រឹមត្រូវនៃឯកសារ។
- ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ និង ការទទួលស្គាល់ការទាមទារ។

[56] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៩

➢ ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និង ចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រា តាមការទាមទាររបស់ភាគី។

➢ ការសម្រេចសេចក្តីដែលបានធ្វើឡើងនៅកាលបរិច្ឆេទនោះ ដោយមិនធ្វើជាលាយលក្ខណ៍អក្សរ។

ដោយឡែក ក្នុងករណីដែលភាគី ឬ អ្នកដទៃទៀតដែលពាក់ព័ន្ធ ប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុនោះ ត្រូវកត់សេចក្តីប្តឹងតវ៉ានេះ នៅក្នុងកំណត់ហេតុនោះ។ ម្យ៉ាងទៀត ភាពត្រឹមត្រូវក្នុងការអនុវត្តតាមបញ្ញត្តិទាក់ទងនឹងរបៀបធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអាចបញ្ជាក់បាន ដោយកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលតែប៉ុណ្ណោះ ប៉ុន្តែប្រសិនបើកំណត់ហេតុនេះ ត្រូវបានបាត់ ឬវិនាស អានុភាពនៃកំណត់ហេតុនេះនឹងពុំមានអានុភាពដែលអាចបញ្ជាក់ភាពត្រឹមត្រូវបានទៀតឡើយ[57]។

**កថាខណ្ឌទី៤៖ ការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង**

នៅក្នុងកាលបរិច្ឆេទដំបូងនៃនីតិវិធីសម្រាប់ការទាញហេតុផល តុលាការត្រូវធ្វើការសាកល្បងផ្សះផ្សាជាដំបូងសិន លើកលែងតែយល់ឃើញថា មិនមានភាពសមរម្យដើម្បីធ្វើការផ្សះផ្សា[58]។ តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន បើទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ[59] ប៉ុន្តែ ជាគោលការណ៍ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ជាកិច្ចដំបូង តុលាការត្រូវតែសាកល្បងធ្វើការផ្សះផ្សាជាមុនសិន មុននឹងធ្វើការបន្តដំណើរការនៃនីតិវិធី។

ផ្ទុយមកវិញ ប្រសិនបើតុលាការយល់ឃើញថា មិនសមរម្យ ដូចនេះតុលាការមិនចាំបាច់ធ្វើការផ្សះផ្សាក៏បានដែរ ករណីដូចជា សិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលដើមចោទទាមទារដោយការប្តឹង មិនអាចអនុញ្ញាតឱ្យគូភាគីដោះស្រាយវិវាទតាមការព្រមព្រៀងរវាងគូភាគីបាននោះទេ ឬ ករណីដែលតុលាការអាចពិចារណា ឬសន្និដ្ឋានបានយ៉ាងច្បាស់លាស់ថា គូភាគីគ្មានបំណងដើម្បីធ្វើការសម្រុះសម្រួលគ្នានោះទេ។

បន្ទាប់ពីការផ្សះផ្សាត្រូវបានបញ្ចប់ តុលាការត្រូវធ្វើការបន្តនីតិវិធី ដោយឱ្យដើមចោទថ្លែងការណ៍អំពីពាក្យបណ្តឹងរបស់ខ្លួន។ ជាគោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់ ដូច្នេះហើយ គ្រាន់តែដាក់ពាក្យបណ្តឹងមិនអាចក្លាយជាឯកសារបានទេ ដោយចាំបាច់ត្រូវតែធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនោះ។

---

[57] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១២

[58] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៤

[59] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៧

លើសពីនេះទៅទៀត បើយោងតាមគោលការណ៍នៃការជម្រះក្តីដោយផ្ទាល់មាត់ តាមធម្មតា ភាគីនៃវិវាទ ត្រូវធ្វើសេចក្តីថ្លែងការណ៍ជាសារធាតុ អំពីខ្លឹមសារនៃឯកសារនានា ដោយផ្ទាល់មាត់។ ជាពិសេស បើផ្អែកតាម ការអនុវត្តជាក់ស្តែង ទាំងចៅក្រម ទាំងភាគីទាំងសងខាង បានអានឯកសារទាំងនោះ ហើយបានក្តាប់នូវខ្លឹមសារ ជាមុនហើយ ដូច្នេះការអានឯកសារទាំងស្រុងទៅ ក៏មិនចាំបាច់ដែរ ហេតុនេះហើយ គួរតែពន្យល់សង្ខេបៗនូវខ្លឹម សារនោះជាការល្អ ហើយការសង្ខេបនោះ ត្រូវគិតទៅតាមស្ថានភាពនៃការអនុវត្តជាក់ស្តែង។

បន្ទាប់មកទៀត គឺការធ្វើការអះអាង ឬ សេចក្តីថ្លែងការណ៍អំពីឯកសារចម្លើយ ពោលគឺជាឯកសារត្រៀម ដែលចុងចម្លើយបានដាក់លើកដំបូង[60]។ ឯកសារត្រៀម គឺជាឯកសារដែលមានសរសេរអំពីខ្លឹមសារដែលភាគី នឹងថ្លែងការណ៍ នៅពេលកាលបរិច្ឆេទបន្ទាប់ ដើម្បីជូនដំណឹងជាមុនទៅភាគីម្ខាងទៀត និង តុលាការ។ គោល បំណងនៃឯកសារនេះ គឺឱ្យតុលាការ និង ភាគីម្ខាងទៀត ពិចារណាឱ្យបានគ្រប់គ្រាន់អំពីខ្លឹមសារនៃសេចក្តីថ្លែង ការណ៍នេះ និង ត្រៀមខ្លួនចូលរួមក្នុងកាលបរិច្ឆេទបន្ទាប់ ដើម្បីឱ្យការតតាំងនៅកាលបរិច្ឆេទដែលបានកំណត់ មានដំណើររលូន។ ដូច្នេះហើយ គប្បីដាក់ឯកសារនេះនាពេលកំណត់ណាមួយឱ្យបានមុនកាលបរិច្ឆេទ ហើយ តុលាការអាចធ្វើការកំណត់នូវកាលបរិច្ឆេទដែលត្រូវដាក់ឯកសារត្រៀមនេះបាន។ ហើយដើម្បីអាចឱ្យមានការ តតាំងគ្នាបានរលូននៅកាលបរិច្ឆេទ និង ដើម្បីឱ្យអាចធ្វើការជំនុំជម្រះ ប្រព្រឹត្តទៅដោយមានប្រសិទ្ធភាពល្អ ចំពោះភាគីដែលមានសមត្ថភាពធ្វើឯកសារត្រៀម តុលាការគួរតែបង្គាប់ឱ្យភាគីនោះដាក់នូវឯកសារត្រៀមនេះ។

អ្វីដែលសំខាន់នោះ គឺនៅក្នុងឯកសារត្រៀម ត្រូវសរសេរអំពីមធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន និង សេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនរបស់ភាគីម្ខាងទៀត[61]។ មធ្យោបាយ តទល់ គឺសម្តៅទៅលើឯកសារទាំងឡាយណាដែលដើមចោទបានដាក់ជូនតុលាការ ដើម្បីបញ្ជាក់អំពីមូលហេតុ នៃការទាមទាររបស់ខ្លួន។ ចំណែកឯ មធ្យោបាយការពារខ្លួន គឺជាឯកសារទាំងឡាយណាដែលចុងចម្លើយបាន ដាក់ជូនតុលាការដើម្បីបញ្ជាក់ថា ការទាមទាររបស់ដើមចោទ ពុំមានមូលហេតុត្រឹមត្រូវ។

នៅក្នុងឯកសារចម្លើយ ចំណុចដែលចុងចម្លើយត្រូវសរសេរ គឺមានដូចជា ការឆ្លើយតបចំពោះខ្លឹមសារនៃ សាលក្រមដែលដើមចោទបានទាមទារ និង ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរ នៅក្នុងពាក្យបណ្តឹង ព្រមទាំងអង្គហេតុតវ៉ា។ ផ្ទុយមកវិញ ប្រសិនបើចុងចម្លើយខកខានមិនបានដាក់ឯកសារ ចម្លើយទេ ដូចនេះតុលាការត្រូវឱ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់នៅក្នុងកាលបរិច្ឆេទ។ ហេតុ

[60] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០១ កថាខណ្ឌទី៣

[61] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០១ កថាខណ្ឌទី២

ដូចនេះ ចុងចម្លើយត្រូវឆ្លើយចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារ ដែលមាននៅក្នុងពាក្យបណ្តឹង ហើយចម្លើយចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារ មាន០៣ប្រភេទ ដូចជា៖

➢ ការទទួលស្គាល់នូវការទាមទារ [62] ។ ពេលដែលមានចុះ ឬ សរសេរអំពីការទទួលស្គាល់នៅក្នុងកំណត់ហេតុ នោះកំណត់ហេតុនឹងមានអានុភាពដូចគ្នានឹងសាលក្រមដែលចូលជាស្ថាពរដែរ[63]។

➢ ទាមទារឱ្យច្រានចោលនូវការទាមទារ ដោយអះអាងថាគ្មានមូលហេតុនៃការទាមទារ។

➢ ទាមទារឱ្យលើកបណ្តឹងចោល ដោយសារតែពុំមាននូវលក្ខខណ្ឌបណ្តឹង។

ចំពោះការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះអង្គហេតុដែលជាមូលហេតុនៃការទាមទារ ដោយនៅក្នុងចម្លើយចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារ ក្នុងករណីដែលចុងចម្លើយទាមទារឱ្យច្រានចោលនូវការទាមទាររបស់ដើមចោទ តុលាការត្រូវឱ្យចុងចម្លើយធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះ អង្គហេតុដែលជាមូលហេតុនៃការទាមទារតទៅទៀត។ បើសិនជាចុងចម្លើយបានសរសេរអំពីចំណុចនេះនៅក្នុងឯកសារចម្លើយ[64] តុលាការត្រូវឱ្យចុងចម្លើយធ្វើសេចក្តីថ្លែងការណ៍អំពីឯកសារចម្លើយនោះ។ ហើយសម្រាប់របៀបធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី ចំពោះការអះអាងរបស់ភាគីម្ខាងទៀតមាន០៤យ៉ាងដូចជា៖

➢ ការសារភាព សម្តៅទៅលើការទទួលស្គាល់ ដូចនេះមិនចាំបាច់បញ្ជាក់ដោយភស្តុតាងនោះទេ[65]។

➢ ការបដិសេធ សម្តៅទៅលើការមិនទទួលស្គាល់ ដូចនេះត្រូវតែធ្វើការបញ្ជាក់ដោយភស្តុតាង[66] លើកលែងតែករណីដែលអង្គហេតុជាក់ស្តែង។

➢ ការមិនដឹង សម្តៅទៅលើការមិនដឹងអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង ដូចនេះត្រូវបានសន្មតថា បានតវ៉ាអំពីអង្គហេតុនោះ[67] ហេតុនេះហើយត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង។

➢ ការនៅស្ងៀមដោយមិនបង្ហាញឆន្ទៈ សម្តៅទៅលើករណីដែលភាគីមិនបានបង្ហាញច្បាស់លាស់នូវឆន្ទៈតវ៉ាអំពីអង្គហេតុដែលភាគីម្ខាងទៀតបានអះអាង នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង ការទាញហេតុផលដោយផ្ទាល់មាត់ទេ ភាគីនោះត្រូវបានចាត់ទុកថា បានសារភាពអំពីអង្គហេតុនោះ ហើយករណីនេះមិនចាំបាច់ធ្វើការបញ្ជាក់ដោយភស្តុតាងនោះទេ។ ប៉ុន្តែប្រសិនបើតុលាការគិតពិចារណាអំពីដំណើរការ និង

---

[62] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២១

[63] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២២

[64] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០១ កថាខណ្ឌទី៣

[65] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៣ កថាខណ្ឌទី២

[66] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៣ កថាខណ្ឌទី១

[67] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៦ កថាខណ្ឌទី២

ខ្លឹមសារនៃរឿងក្តី ហើយយល់ឃើញថា ភាគីនោះបានតវ៉ាអំពីអង្គហេតុ ដូចនេះអង្គហេតុដែលមានវិវាទ គឺចាំបាច់ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង[68]។

ការធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវការទាមទារ គឺមានភាពចាំបាច់ និង មានផលប្រយោជន៍ ដោយការចាំបាច់ធ្វើការបញ្ជាក់ដោយភស្តុតាងនេះ គឺអាស្រ័យទៅតាមរបៀបទទួលស្គាល់ ឬ មិនទទួលស្គាល់ ដូចនេះ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា តើត្រូវពិនិត្យភស្តុតាងទៅលើអង្គហេតុណាមួយ ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ភាគី គឺមានសារៈសំខាន់ណាស់។ ហើយដើម្បីឱ្យការទទួលស្គាល់ ឬ មិនទទួលស្គាល់នេះ មានអានុភាពសំខាន់ មិនត្រូវមើលតែឯកសារ ដូចជាឯកសារចម្លើយ ជាអាទិ៍ ដូចនេះចាំបាច់ត្រូវក្តាប់ឱ្យបានត្រឹមត្រូវនូវចិត្តគំនិតរបស់ភាគី។ ម្យ៉ាងទៀត នៅពេលដែលការអះអាងរបស់ដើមចោទ ឬ ការទទួលស្គាល់ ឬ មិនទទួលស្គាល់របស់ចុងចម្លើយ មានភាពមិនច្បាស់លាស់ គឺត្រូវតែទាមទារឱ្យធ្វើការបំភ្លឺ [69] ដើម្បីបញ្ជាក់ឱ្យច្បាស់លាស់នូវគោលគំនិតនោះ។ ឧទាហរណ៍៖ ដើមចោទ បានធ្វើការអះអាងចំពោះប្រាក់កម្ចី ដែលចុងចម្លើយបានខ្ចីនោះ គឺមិនទាន់បានសងមកឱ្យខ្លួនវិញសោះឡើយ ប៉ុន្តែចុងចម្លើយបានធ្វើការមិនទទួលស្គាល់ ដោយបដិសេធ ហើយតុលាការបានឱ្យចុងចម្លើយធ្វើការបំភ្លឺនូវការបដិសេធរបស់ចុងចម្លើយនោះ ដោយចុងចម្លើយបានបំភ្លឺថា ខ្លួនបានសងប្រាក់កម្ចីនោះបានចំនួន៣០(សាមសិប)ភាគរយហើយ ប៉ុន្តែមិនបានធ្វើឯកសារ ឬ លិខិតប្រគល់ទទួលប្រាក់នោះទេ ដោយដើមចោទគ្រាន់តែបានចេញនូវវិក័យបត្រមួយមកឱ្យខ្លួនតែប៉ុណ្ណោះ។

ក្នុងករណីដែលមានវិវាទចំពោះការទាមទារ ចុងចម្លើយត្រូវធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ ហើយក្រៅពីនេះទៀត ក៏អាចមានករណីដែលចុងចម្លើយអះអាងអំពីការតវ៉ា ដើម្បីតតាំងនឹងការទាមទារផងដែរ។ ហើយការតវ៉ា គឺជាអង្គហេតុដែលអះអាងដោយចុងចម្លើយ ដើម្បីបង្កើតជាឧបសគ្គនៃការកកើតនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត ដែលអះអាងដោយដើមចោទ ដូច្នេះអាចសន្មតបានថា ការតវ៉ា គឺជាការអះអាងចម្បងរបស់ចុងចម្លើយ។ ដូចនេះនៅពេលដែលសរសេរអំពីអង្គហេតុតវ៉ានៅក្នុងឯកសារចម្លើយ គួរតែសរសេរអំពីអង្គហេតុដែលអាចឱ្យសន្និដ្ឋានអំពីអត្ថិភាពនៃអង្គហេតុតវ៉ានោះ ពោលគឺអង្គហេតុប្រយោល ដែលដូចគ្នានឹងពេលសរសេរអំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារដែរ។ ម្យ៉ាងទៀត ចំពោះអង្គហេតុដែលចុងចម្លើយបានអះអាងដែលជាការតវ៉ានោះ ដើមចោទត្រូវតែធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់។

---

[68] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៦ កថាខណ្ឌទី១

[69] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩០

ជាងនេះទៅទៀត ចំពោះអង្គហេតុដែលមានវិវាទរវាងភាគី ត្រូវធ្វើការបញ្ជាក់ដោយភស្តុតាង ហើយចំពោះភស្តុតាងនោះត្រូវបានបែងចែកចេញជា ៥ប្រភេទ ដូចជា៖

- ការសាកសួរសាក្សី
- ការសាកសួរសាមីភាគី
- ការធ្វើកោសល្យវិច័យ
- ភស្តុតាងជាឯកសារ
- ការត្រួតពិនិត្យ ។

នៅក្នុងដំណាក់កាលនីមួយៗនៃនីតិវិធីពិនិត្យភស្តុតាង គឺមាន ការស្នើសុំឱ្យពិនិត្យភស្តុតាងដោយភាគី, ការសម្រេចទទួលយកសំណើ ឬ មិនទទួលដោយតុលាការ និង ការពិនិត្យភស្តុតាង។ ហើយនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចធ្វើសកម្មភាពពីរ ពោលគឺ ការស្នើសុំ និង ការសម្រេចទទួលយកសំណើ ឬ មិនទទួលយក ចំពោះភស្តុតាងទាំង៥ប្រភេទខាងលើនេះ។ ហើយក៏អាចពិនិត្យលើភស្តុតាងជាឯកសារបានដែរ ក្នុងករណីកំណត់មួយចំនួន ប៉ុន្តែចំពោះភស្តុតាង៤ប្រភេទទៀត មិនអាចធ្វើការពិនិត្យបាននៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះបានទេ ដោយត្រូវធ្វើការពិនិត្យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។

ការពិនិត្យភស្តុតាងជាឯកសារ គឺមានលំហូរនីតិវិធីដូចជា៖

- ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ដោយភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង ត្រូវកំណត់ឱ្យបានជាក់លាក់នូវអង្គហេតុដែលត្រូវបញ្ជាក់ [70] ហើយភាគីដែលបានស្នើសុំ គប្បីបំភ្លឺឱ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និង ទំនាក់ទំនងរវាងអង្គហេតុ និង ភស្តុតាង[71]។ ការស្នើសុំនេះ ត្រូវធ្វើឡើងដោយការផ្តល់នូវឯកសារដែលសាមីភាគីមាន ឬ ដោយដាក់ពាក្យសុំទៅតុលាការដើម្បីធ្វើការបង្គាប់ឱ្យម្ចាស់ឯកសារផ្តល់ឯកសារដែលជាភស្តុតាងនោះមក[72]។

- ការសម្រេចទទួលយកភស្តុតាងជាឯកសារ គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ដែលតុលាការត្រូវសម្រេចទទួលយក ឬ មិនទទួលយកនូវការស្នើសុំឱ្យពិនិត្យភស្តុតាងរបស់ភាគី។

[70] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៥ កថាខណ្ឌទី១

[71] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៥ កថាខណ្ឌទី២

[72] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៤៨

យ៉ាងណាមិញ រាល់ការធ្វើភស្តុតាងជាឯកសារ គឺត្រូវតែមានភាពត្រឹមត្រូវ ពោលគឺ ភាគីដែលបានស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ ត្រូវបញ្ជាក់ថាឯកសារនោះត្រូវបានធ្វើឡើងដោយត្រឹមត្រូវ[73] ហើយចំពោះឯកសារឯកជនដែលមានចុះហត្ថលេខារបស់សាមីខ្លួនផ្ទាល់ ឬ អ្នកតំណាង ត្រូវសន្មតថាជាឯកសារដែលបានធ្វើឡើងដោយត្រឹមត្រូវ[74]។

ជាពិសេស គឺនៅពេលដែលពិនិត្យភស្តុតាងជាឯកសារ ចៅក្រមបានមើល និង អានសំណៅដើមនៃឯកសារដែលភាគីបានដាក់ ហើយក្រោយពីបានពិនិត្យភស្តុតាងរួចរាល់ហើយ តុលាការត្រូវសងសំណៅដើមទៅឱ្យភាគីវិញ និង បញ្ចូលឯកសារដែលបានថតចម្លងចូលទៅក្នុងសំណុំរឿង។ ផ្ទុយមកវិញ ប្រសិនបើតុលាការយល់ឃើញថាមានភាពចាំបាច់ត្រូវឃាត់ឯកសារនោះទុក តុលាការអាចឃាត់ទុកនូវឯកសារនោះបាន[75]។

នៅពេលដែលកាលបរិច្ឆេទនៃលំហូរនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ត្រូវបានបញ្ចប់ ប្រសិនបើតុលាការបានកំណត់នូវចំណុចវិវាទបានច្បាស់លាស់ និង ភាគីបានដាក់ភស្តុតាងគ្រប់គ្រាន់ហើយនោះ តុលាការនឹងធ្វើការបន្តនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថានៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងនេះ ពុំទាន់អាចកំណត់នូវចំណុចវិវាទបាន និង ភាគីមិនទាន់បានរៀបចំនូវភស្តុតាងផ្សេងៗរួចរាល់នោះ តុលាការអាចធ្វើការបន្តនីតិវិធីដោយកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២បាន។

**កថាខណ្ឌទី៥៖ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២**

ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូងហើយ ប្រសិនបើតុលាការបានកំណត់នូវកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២ ដូចនេះនៅពេលដែលកាលបរិច្ឆេទដែលបានកំណត់នោះចូលមកដល់ ដំណើរការនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២នេះ នឹងត្រូវបានចាប់ផ្ដើមបន្តពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង។

ករណីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង តុលាការបានបង្គាប់ឱ្យដើមចោទដាក់ឯកសារត្រៀមទី១ ហើយដើមចោទបានដាក់ឯកសារនោះជាមុន ហើយបានធ្វើសេចក្ដីថ្លែងការណ៍អំពីខ្លឹមសារនោះ នៅកាលបរិច្ឆេទត្រៀមសម្រាប់ការទាញហេតុផលលើកទី២។

[73] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៥៥ កថាខណ្ឌទី១

[74] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៥៥ កថាខណ្ឌទី៤

[75] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៤៨ កថាខណ្ឌទី៣

ម៉្យាងទៀត ករណីដែលចុងចម្លើយបានអះអាងនូវអង្គហេតុដែលជាការតវ៉ា ប៉ុន្តែត្រូវបានដើមចោទធ្វើការបដិសេធទាំងស្រុង។ ឧទាហរណ៍៖ ចុងចម្លើយបានអះអាងថា ខ្លួនបានសងប្រាក់ទៅឱ្យដើមចោទវិញគ្រប់ចំនួនអស់ហើយ នៅថ្ងៃកំណត់ណាមួយ ប៉ុន្តែដើមចោទបានបដិសេធចំពោះការអះអាងនោះ ដោយបានទទួលស្គាល់ថានៅថ្ងៃនោះគឺខ្លួនបានទទួលប្រាក់ពីចុងចម្លើយមែន ប៉ុន្តែចំនួនទឹកប្រាក់នោះ គឺជាចំនួនទឹកប្រាក់មួយផ្នែកប៉ុណ្ណោះ ពោលគឺមិនទាន់គ្រប់ចំនួនទាំងអស់នៅឡើយទេ។

ចំពោះភស្តុតាងជាឯកសារនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២នេះវិញ ប្រសិនបើដើមចោទបានស្នើសុំឱ្យពិនិត្យភស្តុតាងលើឯកសារណាមួយ ដែលមាននៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកដំបូង ហើយដើមចោទបានដាក់ឯកសារពន្យល់អំពីភស្តុតាង និង បានបញ្ជាក់ច្បាស់លាស់អំពីទំនាក់ទំនងរវាងអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាងនេះ និង ភស្តុតាងនោះ។ ដូចនេះតុលាការត្រូវធ្វើការសម្រេចទទួលយក ឬ មិនទទួលយកនូវឯកសារនោះនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២នេះ។ ឧទាហរណ៍៖ ដើមចោទបានស្នើសុំឱ្យពិនិត្យភស្តុតាងណាមួយ ដោយមានភ្ជាប់ជាមួយឯកសារបញ្ជាក់ច្បាស់លាស់ ហើយតុលាការក៏សម្រេចទទួលយកនូវភស្តុតាងនោះ ហើយបញ្ចូលឯកសារនោះចូលទៅក្នុងសំណុំរឿង។ ផ្ទុយមកវិញ ប្រសិនបើចុងចម្លើយស្នើសុំឱ្យពិនិត្យភស្តុតាងនោះ នីតិវិធីនៃការស្នើសុំ ការទទួលយក ឬ មិនទទួលយកការបញ្ជាក់ភាពត្រឹមត្រូវ និង ការបញ្ជាក់ភស្តុតាង ត្រូវអនុវត្តដូចគ្នានឹងដើមចោទដែរ។

ម៉្យាងទៀតការស្នើសុំឱ្យពិនិត្យភស្តុតាងលើសាមីភាគី និង សាក្សី ភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង ត្រូវតែកំណត់ឱ្យបានជាក់លាក់អំពីអង្គហេតុដែលត្រូវបញ្ជាក់[76] ហើយភាគីដែលស្នើសុំឱ្យពិនិត្យភស្តុតាង គប្បីបំភ្លឺឱ្យច្បាស់លាស់អំពីអង្គហេតុដែលត្រូវបញ្ជាក់ និង ទំនាក់ទំនងរវាងអង្គហេតុនោះ និង ភស្តុតាង[77]។ ការស្នើសុំសាកសួរសាក្សី ឬ ការសាកសួរសាមីភាគី ត្រូវធ្វើឡើងដោយកំណត់ឱ្យបានច្បាស់លាស់ទៅលើសាក្សី ឬ សាមីភាគីណាមួយ ហើយអ្នកដែលស្នើសុំសាកសួរសាក្សី ឬ សាកសួរសាមីភាគី ត្រូវភ្ជាប់មកជាមួយនូវឯកសារដែលកំណត់អំពីចំណុចដែលត្រូវសាកសួរ។ ឧទាហរណ៍៖ ដើមចោទបានដាក់ពាក្យសុំបញ្ចូលភស្តុតាង ហើយបានស្នើសុំឱ្យសាកសួរសាក្សី ដោយនៅក្នុងពាក្យសុំបញ្ចូលភស្តុតាង មានសរសេរអំពីអង្គហេតុដែលត្រូវបញ្ជាក់ និងចំណុចដែលចង់សាកសួរ។ ក្នុងករណីនេះចុងចម្លើយក៏អាចធ្វើបែបនេះបានដែរ។

---

[76] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៥ កថាខណ្ឌទី១

[77] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៥ កថាខណ្ឌទី២

លើសពីនេះទៅទៀត ចំពោះការទទួលយក ឬ មិនទទួលយកនូវភស្តុតាងដែលស្នើសុំដោយភាគីនោះ គឺជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការសម្រេចទទួលយក ឬ មិនទទួលយកនូវភស្តុតាងនោះ។ ឧទាហរណ៍៖ ដើមចោទបានស្នើសុំឱ្យសាកសួរសាក្សីម្នាក់ ហើយតុលាការបានសម្រេចទទួលយកការស្នើសុំរបស់ដើមចោទ។

យ៉ាងណាមិញ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២នេះ តុលាការមិនអាចធ្វើការពិនិត្យភស្តុតាងលើសាក្សី និង សាមីភាគីបាននោះទេ គឺតុលាការគ្រាន់តែអាចធ្វើការសម្រេចទទួលយក ឬ មិនទទួលយកនូវភស្តុតាងនោះតែប៉ុណ្ណោះ ដោយសារតែការពិនិត្យភស្តុតាងលើសាក្សី និង សាមីភាគីនេះ គឺត្រូវធ្វើនៅក្នុងដំណាក់កាលការទាញហេតុផលដោយផ្ទាល់មាត់។

អ្វីដែលសំខាន់នោះគឺ ដើម្បីឱ្យការសាកសួរសាក្សី និង សាមីភាគី ប្រព្រឹត្តទៅបានដោយរលូននៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នោះ តុលាការគប្បីតែសួរបញ្ជាក់ភាគីនូវចំណុចមួយចំនួនដូចខាងក្រោម៖

- តើត្រូវធ្វើការសាកសួរសាក្សី និង សាមីភាគី តាមលំដាប់លំដោយណា?
- នៅក្នុងការសាកសួរសាក្សី និង សាមីភាគី ការសាកសួររបស់តុលាការ ការសាកសួររបស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ ការសាកសួររបស់អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយ ត្រូវធ្វើតាមលំដាប់ណា?
- តើត្រូវកំណត់រយៈពេលសម្រាប់ការសាកសួរសាក្សី និង សាមីភាគី ដោយរបៀបណា?

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុលើកទី២ ត្រូវបានបញ្ចប់ នៅពេលដែលតុលាការបានរៀបចំ ឬ កំណត់នូវចំណុចរួចរាល់ហើយ និង ភាគីបានដាក់ភស្តុតាងគ្រប់គ្រាន់ហើយ។ ប៉ុន្តែមុននឹងធ្វើការបញ្ចប់នីតិវិធីនេះ តុលាការត្រូវបញ្ជាក់ជាមួយនឹងភាគី អំពីអង្គហេតុដែលនឹងត្រូវបំភ្លឺ[78]នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីឱ្យការពិនិត្យភស្តុតាងអាចធ្វើដោយសមូហវិធីបាន ដោយតុលាការ និង ភាគីទាំងសងខាង ត្រូវមានការយល់ដឹងរួមគ្នាអំពីអង្គហេតុ ដែលត្រូវបំភ្លឺតាមរយៈការពិនិត្យភស្តុតាង ដូច្នេះហើយ ចាំបាច់ត្រូវតែធ្វើការបញ្ជាក់បែបនេះ។ ការបញ្ជាក់នោះ គឺមានសារសេរនៅក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី២។

[78] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៧

### កថាខណ្ឌទី៦៖ អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ ឬ នៅពេលដែលបានធ្វើការបញ្ជាក់នូវអង្គហេតុដែលត្រូវបញ្ជាក់ដោយភស្តុតាងរួចរាល់ហើយ តុលាការត្រូវប្រកាសបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនថ្មីបានទៀតនោះទេ[79]។

ផ្ទុយមកវិញ នៅក្នុងករណីដែលភស្តុតាងជាកម្មវត្ថុពាក់ព័ន្ធនឹងចំណុចដែលត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់តុលាការ ឬ ក្នុងករណីដែលពុំបានធ្វើឱ្យនីតិវិធីបណ្ដឹងមានការយឺតយ៉ាវខ្លាំង ឬ ក្នុងករណីដែលភាគីអាចធ្វើការបញ្ជាក់ដំបូងថា ខ្លួនពុំមានកំហុសធ្ងន់ធ្ងរក្នុងការមិនបានដាក់មុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេនោះ ដូចនេះតុលាការអាចអនុញ្ញាតឱ្យដាក់ភស្តុតាងក្រោយពេលនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន។

ចំពោះការកំណត់នូវកាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង ត្រូវធ្វើឡើងនៅពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានចប់សព្វគ្រប់រួចរាល់ហើយ ដូចនេះតុលាការត្រូវតែធ្វើការកំណត់នូវកាលបរិច្ឆេទដើម្បីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដោយត្រូវធ្វើការកោះហៅគូភាគីឱ្យមកចូលរួមនៅពេលដែលកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ចូលមកដល់[80]។ ម៉្យាងទៀត ចំពោះការកោះហៅឱ្យចូលរួមនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់នេះ តុលាការអាចជូនដំណឹងទៅភាគីដោយផ្ទាល់មាត់បាន[81]។

## ផ្នែកទី២៖ ការទាញហេតុផលដោយផ្ទាល់មាត់

ការទាញហេតុផលដោយផ្ទាល់មាត់ គឺជានីតិវិធីបន្ត ដែលត្រូវធ្វើឡើងក្រោយពីពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានបញ្ចប់ ហើយភាពចាំបាច់នៃការទាញហេតុផលដោយផ្ទាល់មាត់នេះ គឺដើម្បីជាមូលដ្ឋាននៃការពិចារណាចេញសាលក្រម ដោយមុននឹងចេញសាលក្រមស្ដីពីបណ្ដឹង ឬ រឿងក្ដីណាមួយនោះ តុលាការចាំបាច់ត្រូវឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីស្ដាប់ការអះអាងដោយផ្ទាល់មាត់ដោយផ្អែកលើគោលការណ៍ចំពោះមុខ និង គោលការណ៍នៃការជម្រះក្ដីជាសាធារណៈ[82]។

---

[79] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៨

[80] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៣

[81] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៤២

[82] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៤ កថាខណ្ឌទី១

ជាគោលការណ៍ ភាគីត្រូវបានទទួលនូវឱកាសបញ្ចេញមតិរបស់ខ្លួនអំពីចំណុចដែលនឹងវិនិច្ឆ័យដោយតុលាការនៅក្នុងបណ្តឹងនោះ ហើយដើម្បីធ្វើការឆ្លើយតបនឹងមតិដែលត្រូវបានថ្លែងដោយភាគីម្ខាងទៀតមុនពេលតុលាការសម្រេចសេចក្តី។ ហេតុដូចនេះ ភាគីនៃបណ្តឹងមានសិទ្ធិទាមទារឱ្យមានឱកាសបញ្ចេញមតិរបស់ខ្លួន និង ឆ្លើយតបនឹងមតិដែលថ្លែងដោយភាគីម្ខាងទៀត។

ដើម្បីធានាឱ្យមានប្រសិទ្ធភាពនូវសិទ្ធិទាមទារឱ្យសាកសួរ គូភាគីគួរតែមានវត្តមាននៅគ្រប់កាលបរិច្ឆេទនៃនីតិវិធីទាំងអស់ និង ដើម្បីឱ្យបានដឹងអំពីហេតុដែលបានលើកឡើងនៅចំពោះមុខគ្នាទៅវិញទៅមក។ នៅក្នុងករណីដែលតុលាការធ្វើការកោះហៅភាគីតែម្ខាងដើម្បីមកសួរមតិយោបល់នៅកាលបរិច្ឆេទ និង ទីកន្លែងណាមួយ ដែលភាគីម្ខាងទៀតអវត្តមាននោះ នឹងនាំឱ្យមានភាពលំអៀងចំពោះការវិនិច្ឆ័យលើរឿងក្តីនោះ។ ដោយឡែក ជាគោលការណ៍ ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីទាំងសងខាងអាចមានវត្តមានបាន[83] និង នៅសាលសវនាការជាសាធារណៈ[84]។ ប៉ុន្តែប្រសិនបើការទាញហេតុផលដោយផ្ទាល់មាត់ដែលធ្វើឡើងនៅក្នុងសាលសវនាការសាធារណៈនោះ អាចបណ្តាលឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈបាន ដោយតុលាការត្រូវកត់អំពីហេតុការណ៍នេះ និង មូលហេតុនៅក្នុងកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់។

ដូច្នេះហើយ ដើម្បីឱ្យយល់កាន់តែច្បាស់អំពីលំហូរនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់នេះ យើងនឹងធ្វើការសិក្សា និង ធ្វើការអត្ថាធិប្បាយលើផ្នែកនីមួយៗនៃនីតិវិធីនេះដូចតទៅៈ

### កថាខណ្ឌទី១ៈ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី១

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី១ លំហូរនីតិវិធីដែលត្រូវធ្វើបន្ត គឺមានដូចជា ការធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាបការទាញហេតុផល, សកម្មភាពដែលអាចធ្វើនៅក្នុងនីតិវិធី និង ការពិនិត្យភស្តុតាងដោយសមូហវិធី។

#### វាក្យខណ្ឌទី១ៈ ការធ្វើសេចក្តីថ្លែងការណ៍

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ជាបឋម ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[85] ដោយនេះគឺជានីតិវិធីដាក់ជូនតុលាការតាមរយៈការទាញហេតុផលដោយផ្ទាល់មាត់នូវសកម្មភាពទាំងអស់ ដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

[83] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៥ កថាខណ្ឌទី២

[84] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១

[85] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៦ កថាខណ្ឌទី១

ដោយចាត់ទុកថា បានធ្វើដូចគ្នានៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែរ ដើម្បីយកមកធ្វើជាឯកសារមូលដ្ឋាននៃការចេញសាលក្រម។

តុលាការ និង ភាគីទាំងសងខាងបានដឹងអំពីសកម្មភាពទាំងឡាយដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុន្តែសកម្មភាពទាំងនោះមិនមែនបានធ្វើឡើងនៅក្នុងសាលសវនាការជាសាធារណៈនោះទេ ហើយក៏មាននូវករណីមួយចំនួនផងដែរ ដែលចៅក្រមដែលនឹងចេញសាលក្រមចំពោះរឿងក្តីនោះ មិនមែនជាចៅក្រមដែលបានដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ ហេតុនេះហើយទើបបានជាមិនអាចយកមកធ្វើជាឯកសារមូលដ្ឋាននៃការចេញសាលក្រមតែម្តងបាននោះទេ។ ការណ៍ដែលទាមទារឱ្យភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍នេះ គឺដើម្បីជៀសវាង ដោយមិនចាំបាច់ធ្វើសកម្មភាពដែលបានធ្វើរួចនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលឡើងវិញនោះទេ ដោយគ្រាន់តែធ្វើសេចក្តីថ្លែងការណ៍សរុបអំពីសកម្មភាពដែលបានធ្វើរួចនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាការគ្រប់គ្រាន់ហើយ។

នៅពេលដែលភាគីធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអង្គហេតុដែលនឹងត្រូវបញ្ជាក់ដោយការពិនិត្យភស្តុតាង ពោលគឺ ចំណុចវិវាទដែលនឹងធ្វើឡើងនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បន្ទាប់ពីនោះ។ ម្យ៉ាងទៀត ភាគីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីចំណុចវិវាទ ហើយថ្លែងការណ៍សង្ខេបអំពីអង្គហេតុដែលបានអះអាង អំពីភស្តុតាងដែលបានស្នើដាក់ អំពីដីកាសម្រេចស្តីពីភស្តុតាងចេញដោយតុលាការ និងអំពីលទ្ធផលនៃការពិនិត្យភស្តុតាងជាឯកសារ។

យ៉ាងណាមិញ ភាគីទាំងសងខាងមិនចាំបាច់ធ្វើក៏បានដែរ ដោយឱ្យភាគីណាម្ខាងតំណាងឡើងធ្វើក៏បានដែរ។ លើសពីនេះទៅទៀត ក៏អាចមាននូវករណីដែលភាគីទាំងសងខាងពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីថ្លែងការណ៍ដែរ ហើយករណីនេះ តុលាការអាចធ្វើការពន្យល់សង្ខេបអំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និង សួរបញ្ជាក់ពីភាគីថា យល់ស្រប ឬ ទេ ហើយបើសិនជាភាគីទាំងសងខាងយល់ស្របអាចបកស្រាយបានថា ភាគីទាំងសងខាង បានធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបាន។

### **ខាក្យខណ្ឌទី២៖ សកម្មភាពដែលអាចធ្វើនៅក្នុងនីតិវិធី**

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ គេអាចធ្វើសកម្មភាពបណ្តឹងដូចខាងក្រោមបាន៖

- ភាគីអាចអះអាងអំពីអង្គហេតុបាន[86]។

[86] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៦ កថាខណ្ឌទី៣

➢ ភាគីអាចដាក់ឯកសារត្រៀម និង ធ្វើសេចក្តីថ្លែងការណ៍បាន[87]។

➢ ភាគីអាចស្នើដាក់ភស្តុតាងបាន[88]។ ប៉ុន្តែចំណុចដែលជាការអះអាងអំពីអង្គហេតុ ការដាក់ឯកសារត្រៀម ការធ្វើសេចក្តីថ្លែងការណ៍ និង ការដាក់ភស្តុតាងនេះ អាចធ្វើទៅបានតែក្នុងករណីដែលមិនផ្ទុយនឹងបញ្ញត្តិនៃមាត្រា១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ពីព្រោះថា ជាគោលការណ៍ចំណុចទាំងអស់នេះត្រូវបញ្ចប់នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។

➢ ការចេញដីកាសម្រេចស្តីពីការស្នើសុំដាក់ភស្តុតាង ករណីដែលបានស្នើសុំដាក់ភស្តុតាង។

➢ ការពិនិត្យភស្តុតាង[89]។

➢ ភាគីត្រូវធ្វើការទាញហេតុផលចុងក្រោយ[90]។

➢ ក្រៅពីនេះ ការដកពាក្យបណ្តឹង ការសះជា ការបោះបង់នូវការទាមទារ ការទទួលស្គាល់នូវការទាមទារ និង ការសារភាព ជាអាទិ៍[91]។

នៅក្នុងការដឹកនាំកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចអនុវត្តសិទ្ធិដឹកនាំបណ្តឹង និង សិទ្ធិបំភ្លឺបានដូចគ្នាទៅនឹងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែរ។

**វាក្យខណ្ឌទី៣៖ ការពិនិត្យភស្តុតាងដោយសមូហវិធី**

នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង ដែលធ្វើឡើងបន្ទាប់ពីបានបញ្ចប់ការរៀបចំ ឬ កំណត់នូវចំណុចវិវាទ និង ភស្តុតាងរួចរាល់ហើយ តុលាការត្រូវធ្វើឱ្យការពិនិត្យភស្តុតាងអាចប្រព្រឹត្តទៅជាបន្ទាន់បាន[92] ហើយការសាកសួរសាក្សី ឬ សាមីភាគី បើអាចធ្វើបាន ត្រូវធ្វើដោយសមូហវិធី[93]។ តាមរយៈការពិនិត្យភស្តុតាងដោយសមូហវិធីនេះ តុលាការនឹងអាចធ្វើការវិនិច្ឆ័យបានត្រឹមត្រូវ និង បានលឿនដោយផ្អែកលើទំនុកចិត្តថ្មីៗ។ ឧទាហរណ៍៖ តុលាការបានធ្វើការសាកសួរទៅលើសាក្សី។

ការសាកសួរសាក្សី គឺត្រូវធ្វើឡើងឱ្យមានលំដាប់លំដោយ ដូចខាងក្រោម៖

---

[87] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០១ កថាខណ្ឌទី១

[88] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៦ កថាខណ្ឌទី៣

[89] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៦ កថាខណ្ឌទី៤

[90] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៦ កថាខណ្ឌទី៥

[91] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១០ កថាខណ្ឌទី១

[92] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៧ កថាខណ្ឌទី១

[93] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២៧ កថាខណ្ឌទី២

ចំពោះការសាកសួរសាក្សី ភាគី និងតុលាការមានតួនាទីនៅក្នុងការសាកសួរសាក្សី ដែលបានចាប់ផ្តើមពីតុលាការដូចជា៖

តួនាទីរបស់តុលាការក្នុងការសាកសួរសាក្សី៖

- សួរសាក្សីអំពីអង្គហេតុវិវាទប្រកបដោយអព្យាក្រឹត្យ។
- ធ្វើការវាយតម្លៃប្រកបដោយការជឿជាក់លើចម្លើយរបស់សាក្សី ដោយពិចារណាគ្រប់ចម្លើយរបស់សាក្សីដែលបានឆ្លើយនៅពេលសួរដោយចៅក្រម និង ដោយភាគី។

ភាគីដែលស្នើសុំឱ្យធ្វើការសាកសួរសាក្សី៖

- សួរសាក្សីអំពីអង្គហេតុវិវាទដែលតុលាការមិនបានសួរ។
- សួរសំណួរស្តីពីអង្គហេតុដែលបង្កើននូវទំនុកចិត្តលើចម្លើយរបស់សាក្សី។

ភាគីម្ខាងទៀត៖

- ធ្វើសំណួរឱ្យសាក្សីឆ្លើយខុសពីចម្លើយដែលឆ្លើយនៅពេលដែលសួរដោយចៅក្រម និង ភាគីដែលស្នើសុំឱ្យសាកសួរសាក្សី។
- សួរពីអង្គហេតុដែលកាត់បន្ថយនូវការទុកចិត្តលើចម្លើយរបស់សាក្សីនោះ។

ចំពោះការសាកសួរសាក្សី ភាគី និង តុលាការមានតួនាទីនៅក្នុងការសាកសួរសាក្សី ដែលបានចាប់ផ្តើមដោយភាគីជាអ្នកសាកសួរ ដូចជា៖

ការសាកសួរចម្បងដែលធ្វើឡើងដោយភាគីដែលស្នើសុំឱ្យសាកសួរសាក្សី៖

- ភាគីនោះនឹងសួរសាក្សីអំពីអង្គហេតុចាំបាច់ ដែលគាត់ចង់បញ្ជាក់តាមរយៈចម្លើយរបស់សាក្សី។
- ភាគីនោះនឹងសួរសាក្សីអំពីអង្គហេតុដែលអាចទាញនូវផលប្រយោជន៍សម្រាប់ខ្លួន ដោយចំពោះសំណួរដែលគ្មានផលប្រយោជន៍សម្រាប់អង្គហេតុ គឺមិនចាំបាច់សួរនោះទេ។
- ជាលទ្ធផលចម្លើយរបស់សាក្សី គឺគ្រាន់តែផ្តល់នូវការបញ្ជាក់ចំពោះអង្គហេតុដែលបានអះអាងដោយភាគីនោះតែប៉ុណ្ណោះ។

ការសាកសួរតបដោយភាគីម្ខាងទៀត៖

- គោលបំណងនៃការសាកសួរនេះ គឺធ្វើយ៉ាងណាឱ្យភស្តុតាងតាមរយៈការសាកសួរចម្បងទទួលនូវបរាជ័យ។
- ភាគីម្ខាងទៀត នឹងសួរសាក្សីដើម្បីស្វែងរកនូវកំហុស ដែលសាក្សីនោះបានឆ្លើយនៅក្នុងការសាកសួរចម្បង។

➢ ភាគីម្ខាងទៀត នឹងសួរសាក្សីនូវសំណួរដែលធ្វើយ៉ាងណាកាត់បន្ថយនូវការជឿទុកចិត្តលើសាក្សីនោះ។

ការសាកសួររបស់តុលាការ៖

➢ តុលាការអាចសួរសាក្សីបាន ស្ដីពីអង្គហេតុណាមួយដែលនៅតែមិនច្បាស់លាស់ ពោលគឺអាចធ្វើការសាកសួរបន្ថែម។

➢ តុលាការនឹងធ្វើការវាយតម្លៃអំពីភាពដែលអាចជឿទុកចិត្តបាននៃការសាកសួរសាក្សី ដោយពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ នូវចម្លើយនៃការសាកសួរចម្បង និង ការសួរតប ព្រមទាំងពិចារណាដល់ភស្តុតាងផ្សេងៗទៀត។

➢ តួនាទីដ៏សំខាន់របស់តុលាការក្នុងការសាកសួរសាក្សីនៃគោលការណ៍ភាគី គឺមិនទទួលទាំងបង្ខំចិត្តនូវចម្លើយរបស់សាក្សីថាជាការពិតនោះទេ ពោលគឺ តុលាការត្រូវធ្វើការវិនិច្ឆ័យដោយពិចារណាថា តើចម្លើយរបស់សាក្សីនោះពិត ឬ មិនពិត លើចម្លើយដែលមានលក្ខណៈច្របូកច្របល់លាយឡំគ្នា ទាំងចម្លើយពិត និងចម្លើយមិនពិត។

ចំណុចពិសេសនៃការសាកសួរសាក្សី គឺឱ្យសាក្សីធ្វើសេចក្ដីថ្លែងការណ៍នូវអង្គហេតុដែលខ្លួនបានដឹងតាមការពិសោធន៍របស់ខ្លួននៅចំពោះមុខតុលាការ ហើយចម្លើយរបស់សាក្សី ក៏ជាភស្តុតាងដែរ។ ការធ្វើសាក្សីបញ្ចេញពាក្យសម្ដីដើម្បីប្រាប់ដល់ចៅក្រម គឺជាតួនាទីមួយសំខាន់ណាស់របស់តុលាការក្នុងការរកឃើញនូវការពិតពីចម្លើយរបស់សាក្សី។

ដោយឡែកការធ្វើការសាកសួរសាក្សីនេះ គឺមាននូវនីតិវិធីនៃការសាកសួរសាក្សី ដែលត្រូវបានកំណត់ដូចតទៅ៖

➢ ការសួរអំពីអត្តសញ្ញាណរបស់សាក្សី៖ តុលាការត្រូវសួរសាក្សីនូវសំណួរមួយចំនួនដើម្បីបញ្ជាក់នូវអត្តសញ្ញាណរបស់សាក្សីដូចជា សួរឈ្មោះ, ថ្ងៃ ខែ ឆ្នាំកំណើត, អាសយដ្ឋាន, និងមុខរបរជាដើម។ យ៉ាងណាមិញបើទោះជាគ្មានបញ្ញត្តិណាមួយដែលតម្រូវឱ្យមាននីតិវិធីដូចនេះក៏ដោយ ក៏គេអាចចាត់ទុកបានថា វាជាការសំខាន់មួយដើម្បីកុំឱ្យមានការភ័ន្តច្រឡំលើអត្តសញ្ញាណរបស់បុគ្គលនោះ។

➢ ការធ្វើសម្បថ៖ តុលាការត្រូវឱ្យសាក្សីធ្វើសម្បថ[94] ហើយសម្បថនោះត្រូវធ្វើឡើងនៅក្នុងអំឡុងពេលសាកសួរ[95]។ ចំពោះទម្រង់នៃការធ្វើសម្បថ ត្រូវធ្វើតាមការកំណត់ឧបសម្ព័ន្ធនីតិវិធីក្នុងការធ្វើសម្បថ[96]។ ការធ្វើ

[94] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៧ កថាខណ្ឌទី១

[95] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៧ កថាខណ្ឌទី៤

សម្បថ ត្រូវដឹកនាំធ្វើឡើងដោយក្រឡាបញ្ជីមួយរូប ហើយត្រូវធ្វើនៅចំពោះមុខវត្ថុសក្ដិសិទ្ធិនៅទីកន្លែងរបស់តុលាការនីមួយៗ ឬ នៅទីណាមួយតាមការព្រមព្រៀងរបស់គូភាគី។ ប្រសិនបើ មិនមានការចុះសម្រុងគ្នាទេ តុលាការគឺជាអ្នកសម្រេចកំណត់ទីកន្លែងវិញ។ ម៉្យាងទៀត មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកធ្វើសម្បថត្រូវអុជធូប ទៀន ដើម្បីបួងសួងដល់វត្ថុសក្ដិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មក ក្រឡាបញ្ជីត្រូវអានប្រាប់វាទខ្លាំងៗ និង ច្បាស់ៗ ឱ្យអ្នកស្បថស្ដាប់រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម។ ក្រោយពីបានធ្វើសម្បថរួច ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុដែលបានឱ្យស្បថនោះ ដើម្បីបញ្ជាក់ថាបានធ្វើត្រឹមត្រូវ ហើយសេចក្ដីបានចេញវាចាឱ្យស្បងយ៉ាងណា ត្រូវកត់នៅក្នុងកំណត់ហេតុទាំងអស់។ អ្វីដែលសំខាន់នោះគឺ ជនគ្រប់រូបដែលជាសាក្សី បើទោះជាសាក្សីមានជំនឿសាសនាផ្សេងពីព្រះពុទ្ធសាសនា ក៏ត្រូវធ្វើសម្បថដែរ ដោយផ្អែកទៅតាមនីតិវិធីក្នុងការធ្វើសម្បថនេះដូចគ្នា។ ឧទាហរណ៍៖ ដើមចោទបានស្នើសុំសាកសួរសាក្សីជាជនជាតិខ្មែរ-ឥស្លាម ជនជាតិវៀតណាម ឬ ជនជាតិចិន ដូចនេះការធ្វើសម្បថអាចនឹងត្រូវបានឱ្យធ្វើទៅតាមប្រពៃណីរបស់សាក្សីនោះ។

➢ ការសាកសួរសាក្សី៖ ជាគោលការណ៍ ការសាកសួរសាក្សីម្នាក់ៗ ត្រូវធ្វើឡើងតាមលំដាប់លំដោយពោលគឺដំបូង តុលាការ ឬ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ, ភាគីដែលបានស្នើសុំឱ្យសាកសួរសាក្សីនោះ និង បន្ទាប់មកទៀត គឺភាគីម្ខាងទៀត [97] ។ ចៅក្រមប្រឹក្សាអាចសាកសួរសាក្សីបាន ក្រោយពីបានទទួលការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយការធ្វើការលំដាប់លំដោយនេះ គឺដោយសារតែតាមសភាពការណ៍បច្ចុប្បន្នរបស់ព្រះរាជាណាចក្រកម្ពុជា កម្រិតយល់ដឹងរបស់ភាគីនៃវិវាទគឺនៅមានកម្រិត។ ប៉ុន្តែ តុលាការអាចប្ដូរលំដាប់នៃការសាកសួរសាក្សីខាងលើនេះបាន[98] ឧទាហរណ៍៖ ប្រសិនបើ ភាគីមានតំណាងដោយអាណត្តិជាមេធាវី ភាគីនោះអាចទាមទារធ្វើការសាកសួរសាក្សីមុនតុលាការបាន ដោយតុលាការបានអនុញ្ញាតជាអាទិ៍។ ក្នុងករណីនេះភាគីម្ខាងទៀតជាអ្នកសាកសួរបន្ទាប់ ហើយអ្នកសាកសួរចុងក្រោយគេ គឺតុលាការ។ ដោយឡែក ប្រសិនបើតុលាការយល់ឃើញថាមានភាពចាំបាច់ តុលាការអាចអនុញ្ញាតឱ្យសាក្សីដែលត្រូវបានសាកសួរហើយ ឬ សាក្សីដែលបម្រុងនឹងត្រូវសាកសួរឱ្យនៅសាលសវនាការបាន[99]។ ម៉្យាងទៀត នៅពេលដែលតុលាការទទួលស្គាល់ថាសាក្សីពុំអាចឆ្លើយឱ្យគ្រប់គ្រាន់បាននៅចំពោះមុខអ្នកសង្កេតការណ៍ណាម្នាក់ ដោយសារតែអ្នកនោះជាហេតុនាំឱ្យមានការភ័យព្រួយ តុលាការអាចបង្គាប់ឱ្យអ្នកសង្កេតការណ៍នោះចេញក្រៅសាលសវនាការ នៅពេលដែល

[96] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៧ កថាខណ្ឌទី៥

[97] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៨ កថាខណ្ឌទី៥

[98] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៨ កថាខណ្ឌទី៦

[99] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៨ កថាខណ្ឌទី៨

សាក្សីនោះឆ្លើយ[100]។ លើសពីនេះទៅទៀត នៅពេលដែលតុលាការយល់ឃើញថាមានភាពចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើការសាកសួរសាក្សី និង សាក្សីផ្សេងទៀតនៅពេលតែមួយជាមួយគ្នា[101]។

➢ ការកម្រិតការសាកសួរៈ ចំពោះសំណួរ ប្រសិនបើអាចធ្វើ គឺត្រូវតែធ្វើឱ្យដាច់ដោយឡែក និងច្បាស់លាស់[102] ពោលគឺសំណួរដាច់ដោយឡែកពីគ្នា។ ដោយសារតែនៅក្នុងករណីខ្លះ សាក្សីនិយាយវែងពេក ហើយអ្វីៗដែលគេបាននិយាយនោះមិនពាក់ព័ន្ធនឹងចំណុចវិវាទ ដែលជាហេតុនាំឱ្យតុលាការមានការពិបាកនៅក្នុងការយល់អំពីចម្លើយនោះ ទើបចំពោះសំណួរ ត្រូវតែធ្វើឡើងដាច់ដោយឡែក និងច្បាស់លាស់ ដែលអាចឱ្យសាក្សីឆ្លើយបានងាយស្រួល និងតុលាការងាយស្រួលនៅក្នុងការយល់អំពីចម្លើយរបស់សាក្សី។ យ៉ាងណាមិញ ប្រសិនបើពុំមានមូលហេតុត្រឹមត្រូវទេ មិនត្រូវសួរសំណួរនាំមុខឡើយ[103] ហើយចំពោះសំណួររបស់អ្នកសាកសួរ សាក្សីគ្រាន់តែឆ្លើយថា "បាទ ឬ ចា" នោះ តុលាការមានការពិបាកនឹងបង្កើតនូវជំនឿទៅលើចម្លើយដែលសាក្សីបានឆ្លើយនោះណាស់ ដែលជាហេតុនាំឱ្យមានភាពចាំបាច់ឱ្យសាក្សីឆ្លើយដោយពាក្យសម្តីរបស់ខ្លួន ប៉ុន្តែប្រសិនបើសំណួរដែលពាក់ព័ន្ធនឹងចំណុចដែលគ្មានវិវាទ អាចសួរសំណួរនាំមុខបាន។ ម្យ៉ាងទៀត ប្រសិនបើសាក្សីមិនយល់នូវគោលបំណងនៃសំណួរ ឬ មិនបានឆ្លើយឱ្យចំទៅនឹងគោលបំណងនោះទេ ត្រូវប្តូរសំណួរដើម្បីឱ្យសាក្សីយល់ដោយឆ្លើយឱ្យចំ ហើយនៅក្នុងអំឡុងពេលដែលកំពុងសាកសួរសាក្សី គឺមិនត្រូវធ្វើការស៊ើបន្ទោសឱ្យសាក្សីជាដាច់ខាត។ ដោយឡែក នៅមុនពេលដែលនឹងត្រូវសាកសួរសាក្សី គឺត្រូវដាក់នូវឯកសារដែលកំណត់អំពីចំណុចដែលត្រូវសាកសួរ[104] ប៉ុន្តែនៅពេលដែលសាកសួរជាក់ស្តែង ពេលខ្លះក៏អាចមាននូវសំណួរដែលពុំបានសរសេរនៅក្នុងឯកសារជាមុនដែរ ដូច្នេះហើយចំពោះករណីនេះ ប្រសិនបើសំណួរប្រភេទនេះជាសំណួរដែលកើតចេញមកពីស្ថានភាពនៃសំណួរដែលបានសរសេរនៅក្នុងឯកសារជាមុន ហើយមិនអាចជៀសវាងមិនសួរពុំបាន ដោយអាចមានផលប៉ះពាល់ដល់ការស្វែងរកការពិត ដូចនេះអាចធ្វើការសាកសួរសាក្សីបាន។ លើសពីនេះទៅទៀត សាក្សីមិនអាចឆ្លើយនូវសំណួរដោយយកឯកសារមកអានធ្វើជាមូលដ្ឋានបាននោះទេ[105] ពោលគឺ ជាគោលការណ៍ ការសាកសួរសាក្សីត្រូវធ្វើឡើងដោយផ្អែកលើការចងចាំរបស់សាក្សី។ ជាងនេះទៅទៀត ប្រសិនបើ

[100] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៨ កថាខណ្ឌទី៩

[101] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៨ កថាខណ្ឌទី១០

[102] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៩ កថាខណ្ឌទី១

[103] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៩ កថាខណ្ឌទី២ ចំណុចខ

[104] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៨ កថាខណ្ឌទី២

[105] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៨ កថាខណ្ឌទី៧

មានការអនុញ្ញាតឱ្យផ្តល់ចម្លើយបែបនេះ អាចនាំឱ្យសាក្សីមានការងាយស្រួលក្នុងផ្តល់ចម្លើយ មិនពិត ឬ ផ្តល់ចម្លើយក្លែងបន្លំបាន។

➢ ករណីកិច្ចពេលធ្វើជាសាក្សី៖ តុលាការអាចសាកសួរជនណាមួយជាសាក្សីក៏បាន ហើយអាចនាំខ្លួនសាក្សីដែលមិនព្រមចូលខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវ ដោយដីកាសម្រេចបាន ហើយបើសិនជាសាក្សីមិនព្រមចូលខ្លួនមកតុលាការ ដោយគ្មានមូលហេតុត្រឹមត្រូវទេនោះ តុលាការអាចធ្វើការពិន័យជាប្រាក់ចំនួនមិនលើសពី១,០០០,០០០(មួយលាន)រៀលបាន ដោយដីកាសម្រេច[106]។ ក្នុងករណីដែលការសាកសួរសាក្សីជាមន្ត្រីរាជការ ឬ អតីតមន្ត្រីរាជការ ចំពោះកិច្ចការសម្ងាត់នៅក្នុងតួនាទីនោះ តុលាការត្រូវទទួលការយល់ព្រមពីសំណាក់ស្ថាប័នដែលគ្រប់គ្រងលើសាក្សីនោះ[107] ឧទាហរណ៍ជាក់ស្តែងដូចជា ប្រសិនបើសមាជិករដ្ឋសភា គឺត្រូវទទួលសេចក្តីអនុញ្ញាតពីរដ្ឋសភា, ប្រសិនបើសមាជិករាជរដ្ឋាភិបាល គឺត្រូវទទួលសេចក្តីអនុញ្ញាតពីគណៈរដ្ឋមន្ត្រី។ យ៉ាងណាមិញ ការយល់ព្រមពីសំណាក់ស្ថាប័នដែលគ្រប់គ្រងលើសាក្សីនោះ គឺមិនអាចបដិសេធបានឡើយ លើកលែងតែក្នុងករណីដែលការយល់ព្រមនោះនាំឱ្យខូចផលប្រយោជន៍សាធារណៈ ឬ បណ្តាលឱ្យមានឧបសគ្គធ្ងន់ធ្ងរ ក្នុងការបំពេញការងាររបស់រដ្ឋ។ ម៉្យាងទៀត ប្រសិនបើការផ្តល់ចម្លើយទាក់ទងនឹងហេតុដែលធ្វើឱ្យសាក្សី ឬ សហព័ទ្ធរបស់សាក្សី ឬ ញាតិឯទៀតរបស់សាក្សី អាចទទួលរងនូវការចោទប្រកាន់អំពីបទអាជ្ញា ឬ ទទួលការផ្តន្ទាទោសនោះ សាក្សីអាចធ្វើការបដិសេធនូវការផ្តល់ចម្លើយបាន[108] ហើយចំពោះការបដិសេធនេះ សាក្សីត្រូវធ្វើសេចក្តីបញ្ជាក់ដំបូង ចំណែកឯតុលាការវិញ ត្រូវសម្រេចដោយយកសេចក្តីបញ្ជាក់ដំបូងរបស់សាក្សីនោះជាមូលដ្ឋាន។ សេចក្តីបញ្ជាក់ដំបូងនេះ ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន[109]។ ក្រៅពីនេះ តុលាការអាចសាកសួរសាក្សីនៅក្រៅតុលាការបាន ក្នុងករណីដែលសាក្សីគ្មានករណីកិច្ចចូលខ្លួនទៅតុលាការដែលទទួលបណ្តឹង ឬ មានមូលហេតុត្រឹមត្រូវដែលមិនអាចចូលខ្លួនទៅតុលាការបាន ឬ ការចូលខ្លួនរបស់សាក្សីទៅតុលាការដែលទទួលបណ្តឹង បណ្តាលឱ្យមានការចំណាយទៅលើពេលវេលា ឬ សោហ៊ុយមិនសមរម្យ ឬ ក្នុងករណីដែលគូភាគីពុំមានការតវ៉ា[110] ហើយនៅពេលដែលធ្វើការសាកសួរសាក្សីនៅក្រៅតុលាការ គេអាចអនុញ្ញាតឱ្យចៅក្រមម្នាក់ ក្នុងចំណោមចៅក្រមដែលនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះ ដែលហៅ

---

[106] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣២ កថាខណ្ឌទី៣

[107] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៣ កថាខណ្ឌទី១

[108] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៤

[109] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣១

[110] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៣៦ កថាខណ្ឌទី១

ថា ចៅក្រមដែលទទួលបញ្ជា ឬ ចៅក្រមណាដែលមានកន្លែងនៅក្បែរលំនៅដ្ឋានរបស់សាក្សី ដែលហៅថា ចៅក្រមដែលទទួលការប្រគល់សិទ្ធិ ដើម្បីបំពេញកិច្ចការសាកសួរសាក្សីនេះ[111]។

លំហូរនីតិវិធីនៃការសាកសួរសាក្សី គឺមានដូចបានរៀបរាប់ខាងលើនេះ ចំណែកលំហូរនីតិវិធីនៃការសាកសួរសាមីភាគីវិញ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នា ដោយមានលំហូរនីតិវិធីដូចខាងក្រោម៖

➢ ជាគោលការណ៍ នីតិវិធីនៃការសាកសួរសាមីភាគី ក៏ដូចគ្នាទៅនឹងនីតិវិធីនៃការសាកសួរសាក្សីដែរ គឺត្រូវយកបញ្ញត្តិស្តីពីការសាកសួរសាក្សី មាត្រា១៤១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មកអនុវត្តផងដែរ។ ប៉ុន្តែ ចំណុចខ្លះដែលមានលក្ខណៈខុសគ្នានោះ គឺភាគីពុំមានកាតព្វកិច្ចស្បថដូចសាក្សីនោះទេ។ ដោយឡែក តុលាការអាចឱ្យសាមីភាគីស្បថបាន ដោយអាស្រ័យតាមឆន្ទានុសិទ្ធិរបស់តុលាការ[112] ហើយនៅក្នុងករណីដែលតុលាការឱ្យសាមីភាគីណាម្ខាងស្បថនោះ គឺមានន័យថាត្រូវឱ្យភាគីទាំងអស់ស្បថគ្រប់ៗគ្នា ដោយមិនត្រូវឱ្យភាគីតែម្ខាងធ្វើការស្បថដោយឯកឯងនោះទេ។

➢ ចំពោះភាគីដែលពុំចូលខ្លួន ឬ បដិសេធនូវការធ្វើសម្បថ ឬ ផ្តល់នូវចម្លើយ ដោយគ្មានមូលហេតុត្រឹមត្រូវ នោះតុលាការអាចទទួលស្គាល់ថា សេចក្តីអះអាងអំពីចំណុចសាកសួររបស់ភាគីម្ខាងទៀតជាការពិតបាន[113]។ ម្យ៉ាងទៀត ចំពោះភាគីដែលបានស្បថក្លែងបន្លំសេចក្តីថ្លែងការណ៍ តុលាការអាចចេញដីកាសម្រេចពិន័យជាប្រាក់ចំនួនមិនលើសពី ២,០០០,០០០(ពីរលាន)រៀលបាន[114] ហើយចំពោះដីកាសម្រេចនេះ គឺអាចប្តឹងជំទាស់បាន[115]។

➢ ការអះអាងរបស់ភាគី គឺជាសកម្មភាពបង្ហាញចំពោះតុលាការនូវអង្គហេតុដែលជាមូលដ្ឋាននៃអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលទាមទារតាមផ្លូវបណ្តឹង មានន័យថា គឺជាការលើកឡើងនូវបញ្ហាតាមផ្លូវច្បាប់ ប្រសិនបើបានទទួលស្គាល់នូវអង្គហេតុ នោះអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិនឹងមាន ។ ដូចនេះហើយ ការអះអាងរបស់ភាគី មិនចាត់ទុកថាជា ភស្តុតាងនោះទេ។ ម្យ៉ាងទៀត ការអះអាងរបស់ភាគីនេះ អាចធ្វើជំនួស ដោយអ្នកតំណាងដោយអាណត្តិរបស់ភាគីនោះបាន។

➢ សេចក្តីថ្លែងការណ៍របស់ភាគី គឺជាសកម្មភាពរៀបរាប់ដោយភាគី ជូនចំពោះតុលាការនូវអ្វីៗដែលខ្លួនបានជួបប្រទះផ្ទាល់ពីមុន ហើយនេះគឺជាសកម្មភាព ដើម្បីបញ្ជាក់នូវអង្គហេតុដែលភាគីអះអាង ដូច្នេះហើយ

[111] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា១៣៦ កថាខណ្ឌទី២

[112] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៤០ កថាខណ្ឌទី១

[113] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៤០ កថាខណ្ឌទី២

[114] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៤០ កថាខណ្ឌទី៣

[115] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៤០ កថាខណ្ឌទី៤

សេចក្តីថ្លែងការណ៍របស់សាមីភាគី ត្រូវចាត់ទុកថាជាភស្តុតាង ដូចសេចក្តីថ្លែងការណ៍របស់សាក្សីដែរ។ ចំពោះការធ្វើសេចក្តីថ្លែងការណ៍នេះ អ្នកតំណាងដោយអាណត្តិរបស់ភាគី មិនអាចធ្វើសេចក្តីថ្លែងការណ៍ជំនួសភាគីបានឡើយ។

ក្រៅពីការសាកសួរសាក្សី ឬ សាមីភាគីខាងលើនេះ នៅមានចំណុចផ្សេងៗទៀត ដូចជា កោសលវិច័យ និង ការត្រួតពិនិត្យ។ កោសលវិច័យ គឺជាភស្តុតាង ដោយបង្គាប់ឱ្យតតិយជន ដែលមានឯកទេស បច្ចេកទេស និង ចំណេះដឹងផ្សេងៗ ឱ្យធ្វើការវិនិច្ឆ័យនូវចំណុចណាមួយ ដោយផ្អែកលើឯកទេស បច្ចេកទេស និងចំណេះដឹងនោះ។ ឧទាហរណ៍៖ ករណីដែលត្រូវធ្វើកោសលវិច័យលើស្នាមមេដៃ ឬ ហត្ថលេខា ដូចនេះតុលាការត្រូវចាត់តាំងស្ថាប័នដែលមានសមត្ថកិច្ចធ្វើកោសលវិច័យ ពោលគឺអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃរបស់ព្រះរាជាណាចក្រកម្ពុជា។ ម៉្យាងទៀត កោសលវិច័យ គឺជាការពិនិត្យភស្តុតាងមួយប្រភេទ ដែលជាគោលការណ៍ត្រូវធ្វើឡើងដោយការស្នើសុំពីភាគី ដូចភស្តុតាងដទៃទៀតដែរ ក៏ប៉ុន្តែនៅក្នុងករណីខ្លះដែលទទួលស្គាល់ថាមានការចាំបាច់ តុលាការអាចបង្គាប់ឱ្យធ្វើកោសលវិច័យបាន ដោយឆន្ទានុសិទ្ធិ។ រីឯការត្រួតពិនិត្យវិញ គឺជាការពិនិត្យភស្តុតាងដើម្បីទទួលបាននូវធនធានភស្តុតាង ដោយការត្រួតពិនិត្យនូវភិនភាគ ឬ លក្ខណៈនៃវត្ថុដោយផ្ទាល់ ដោយតុលាការ ដោយប្រើវិញ្ញាណប្រាំរបស់ខ្លួន[116]។

### កថាខណ្ឌទី២៖ កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់

ចំពោះកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ គឺត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រា១១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ដោយស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ គឺតុលាការត្រូវឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុនៅរាល់កាលបរិច្ឆេទនីមួយៗ ហើយនៅក្នុងកំណត់ហេតុនោះ ត្រូវកត់ត្រានូវចំណុចដែលជារូបមន្ត[117] និងចំណុចសារជាតុ[118]។

ចំណុចដែលជារូបមន្តនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវកត់ត្រានូវចំណុចដូចខាងក្រោម៖

- សញ្ញាណរឿងក្តី។
- ឈ្មោះចៅក្រម និង ក្រឡាបញ្ជី។
- ឈ្មោះតំណាងអយ្យការដែលបានចូលរួម ប្រសិនបើមាន។

---

[116] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា១៦១

[117] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៨

[118] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៩

➢ ឈ្មោះភាគី អ្នកតំណាង អ្នកជំនួយការ និង អ្នកបកប្រែដែលបានបង្ហាញខ្លួន។

➢ ពេលវេលា និង ទីកន្លែង នៃការទាញហេតុផលដោយផ្ទាល់មាត់។

➢ ហេតុការណ៍ដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ ឬ ហេតុការណ៍ និង មូលហេតុដែលមិនបានធ្វើជាសាធារណៈក្នុងករណីដែលមិនធ្វើជាសាធារណៈ។

ចំណែកឯចំណុចជាសារធាតុនៃកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់វិញ គឺត្រូវកត់ត្រានូវសេចក្តីសង្ខេបអំពីការទាញហេតុផលនីមួយៗ ហើយជាពិសេស ត្រូវកត់ត្រាឱ្យបានច្បាស់លាស់នូវចំណុចខាងក្រោមនេះ ដែលមានដូចជា៖

➢ ការដកពាក្យបណ្តឹង ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់ការទាមទារ និង ការសារភាព។

➢ សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ។

➢ ការធ្វើសម្បថ ឬ មិនធ្វើសម្បថរបស់សាក្សី របស់ភាគីផ្ទាល់ខ្លួន និង របស់អ្នកធ្វើកោសលវិច័យ និង មូលហេតុដែលមិនបានឱ្យសាក្សី និង អ្នកធ្វើកោសលវិច័យធ្វើសម្បថ។

➢ លទ្ធផលនៃការត្រួតពិនិត្យ។

➢ ចំណុចដែលតុលាការបានបង្គាប់ឱ្យកត់ត្រា និងចំណុចដែលតុលាការអនុញ្ញាតឱ្យកត់ត្រាតាមការទាមទាររបស់ភាគី។

➢ ការសម្រេចសេចក្តីដែលបានធ្វើឡើងដោយមិនបានធ្វើជាលាយលក្ខណ៍អក្សរ។

➢ ការប្រកាសសេចក្តីសម្រេច។

➢ ចំពោះចំណុចសារធាតុនេះ ក្រឡាបញ្ជីអាចថតខ្សែអាត់ ឬ ខ្សែវីដេអូ នូវសេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ ឬ របស់អ្នកធ្វើកោសលវិច័យ ដើម្បីជំនួសកំណត់ហេតុជាលាយលក្ខណ៍អក្សរបាន ប្រសិនបើមានការអនុញ្ញាតពីតុលាការ ហើយភាគីនៃវិវាទអាចធ្វើការបញ្ចេញយោបល់របស់ខ្លួនចំពោះករណីនេះបាន។ ដោយឡែក ប្រសិនបើមានការស្នើសុំរបស់ភាគី រហូតដល់បណ្តឹងនេះបានបញ្ចប់ និង ក្នុងករណីដែលតុលាការជាន់ខ្ពស់កំពុងចាត់ការបណ្តឹងនោះ ហើយតុលាការជាន់ខ្ពស់យល់ឃើញថាចាំបាច់ ដើម្បីឱ្យកត់ត្រាជាលាយលក្ខណ៍អក្សរនោះ ក្រឡាបញ្ជីត្រូវធ្វើឯកសារដែលកត់សេចក្តីថ្លែងការណ៍របស់សាក្សី របស់ភាគីផ្ទាល់ ឬ របស់អ្នកធ្វើកោសលវិច័យជាលាយលក្ខណ៍អក្សរ។[119]

[119] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២០

ជាងនេះទៅទៀត ចំពោះឯកសារ រូបថត ខ្សែអាត់ ខ្សែវីដេអូ ឬ វត្ថុផ្សេងទៀតដែលតុលាការយល់ឃើញថាសមរម្យ អាចយកធ្វើជាផ្នែកមួយនៃកំណត់ហេតុស្តីពីការទាញហេតុដោយផ្ទាល់មាត់ ដោយយកធ្វើជាអាគតដ្ឋានក្នុងកំណត់នោះ ហើយភ្ជាប់ជាមួយសំណុំរឿងជាឧបសម្ព័ន្ធបាន។[120] យ៉ាងណាមិញ ការថតរូប ការកត់ជរលេខ ការថតខ្សែអាត់ ការថតខ្សែវីដេអូ ឬ ការផ្សាយបន្តផ្ទាល់ក្នុងសាលសវនាការ មិនអាចធ្វើបានឡើយ ប្រសិនបើគ្មានការអនុញ្ញាតពីតុលាការ។[121]

ដូចនេះហើយ នៅពេលដែលនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានអនុវត្តរួចរាល់ទៅតាមនីតិវិធីអស់ហើយ តុលាការអាចធ្វើការបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់បាន។

**កថាខណ្ឌទី៣៖ ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់**

តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រមចុងក្រោយ ប្រសិនបើតុលាការយល់ឃើញថា ត្រូវបញ្ចប់ការវិនិច្ឆ័យដោយផ្អែកលើលទ្ធផលដែលបានមកពីការទាញហេតុផលដោយផ្ទាល់មាត់ និង ការពិនិត្យលើភស្តុតាង[122]។ ប៉ុន្តែប្រសិនបើ តុលាការមិនទាន់អាចវិនិច្ឆ័យនូវលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូងបានទេ ឬ នៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកដំបូង មិនអាចដំណើរការនីតិវិធីបានគ្រប់ចំណុចនោះទេ តុលាការអាចបន្តកំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់លើកទី២បាន ដោយធ្វើការបន្តនូវនីតិវិធីដែលមិនទាន់បានធ្វើ ឬ ស្វែងរកចំណុចបញ្ជាក់បន្ថែម ដើម្បីធ្វើជាមូលដ្ឋាននៅក្នុងការវិនិច្ឆ័យលើលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់បាន។

អត្ថន័យសំខាន់នៃការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ គឺតុលាការត្រូវធ្វើការវិនិច្ឆ័យនូវភាពត្រឹមត្រូវនៃការទាមទារ ដោយផ្អែកលើស្ថានភាពនៃការអះអាង និង បញ្ជាក់ភស្តុតាងនៅពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ដូច្នេះហើយ អាជ្ញាអស់ជំនុំនៃការចូលជាស្ថាពររបស់សាលក្រម ត្រូវកំណត់ជាស្ថាពរនូវសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្ត នាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់[123]។ ម៉្យាងទៀតថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវសរសេរនៅក្នុងលិខិតសាលក្រម [124]។

---

[120] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២១

[121] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១២២

[122] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨០ កថាខណ្ឌទី១

[123] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៩៤ កថាខណ្ឌទី២

[124] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨៩ កថាខណ្ឌទី១ ចំណុច ខ

នៅមុនពេលដែលត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចអនុញ្ញាតឱ្យភាគីនីមួយៗធ្វើការទាញហេតុផលចុងក្រោយបាន[125]។ ហើយការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយនេះ ត្រូវធ្វើឡើងក្រោយការពិនិត្យភស្តុតាង ហើយភាគីនីមួយៗត្រូវសរសេរពន្យល់ឱ្យតុលាការយល់ដឹងឱ្យបានពេញលេញនូវអង្គហេតុដែលសាមីខ្លួនម្នាក់ៗបានអះអាងតាមរយៈភស្តុតាងដែលបានពិនិត្យរួចហើយនោះ។ ឧទាហរណ៍៖ ដើមចោទ និង ចុងចម្លើយ បានដាក់ឯកសារត្រៀមចុងក្រោយជូនតុលាការ ហើយនៅកាលបរិច្ឆេទដែលតុលាការបានកំណត់នោះ ភាគីទាំងសងខាងបានធ្វើសេចក្តីថ្លែងការណ៍លើឯកសារត្រៀមនោះ ហើយបន្ទាប់មកត្រូវបានតុលាការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅកាលបរិច្ឆេទនោះ ដោយកំណត់កាលបរិច្ឆេទថ្មីមួយទៀតដើម្បីធ្វើការប្រកាសសាលក្រម។

ហេតុដូច្នេះហើយ បន្ទាប់ពីបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ហើយ គឺតុលាការត្រូវតែធ្វើការប្រកាសសាលក្រម។

## ផ្នែកទី៣៖ នីតិវិធីនៃការបញ្ចប់បណ្តឹង

នីតិវិធីនៃការបញ្ចប់បណ្តឹង អាចធ្វើឡើងតាមរយៈ ការសះជាតាមផ្លូវបណ្តឹង និង ការចេញសាលក្រមដើម្បីបញ្ចប់អានុភាពនៃបណ្តឹង មានន័យថាដើម្បីឱ្យរឿងក្តី ឬ បណ្តឹងនោះបានបញ្ចប់ដោយស្ថាពរ។ នីតិវិធីនៃការបញ្ចប់បណ្តឹងតាមរយៈ ការសះជាតាមផ្លូវបណ្តឹង និង ការចេញសាលក្រម គឺមានលក្ខណៈដាច់ដោយឡែកពីគ្នា ហើយដើម្បីយល់ដឹងអំពីលក្ខណៈខុសប្លែកពីគ្នារវាង ការសះជាតាមផ្លូវបណ្តឹង និង ការចេញសាលក្រមនេះ យើងនឹងធ្វើការពន្យល់ និង អត្ថាធិប្បាយដូចតទៅ៖

### កថាខណ្ឌទី១៖ ការសះជាតាមផ្លូវបណ្តឹង

ការសះជាតាមផ្លូវបណ្តឹង គឺជាសកម្មភាពដែលដើមចោទ និង ចុងចម្លើយ ធ្វើសម្បទានគ្នាទៅវិញទៅមក ឬ ធ្វើការលះបង់រៀងៗខ្លួន នូវការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលជាកម្មវត្ថុនៃបណ្តឹង និង ព្រមព្រៀងបញ្ចប់វិវាទនៅក្នុងនីតិវិធីបណ្តឹង ហើយធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនោះ ដោយឯកភាពគ្នាចំពោះមុខតុលាការ[126]។ ដូចនេះ ការសះជា គឺជាមូលហេតុសំខាន់មួយនៃការបញ្ចប់បណ្តឹង ដូចទៅនឹងសាលក្រមដែរ។

ការសះជាតាមផ្លូវបណ្តឹង អាចកើតមានឡើងនៅគ្រប់នីតិវិធីបណ្តឹងរបស់តុលាការដូចជា៖

---

[125] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១១៦ កថាខណ្ឌទី៥

[126] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨ ទំព័រ១៦៤ កថាភាគទី៥ កថាខណ្ឌទី១

➢ ការសាកល្បងធ្វើការផ្សះផ្សា[127]។

➢ ការសាកល្បងផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[128]។

➢ ការផ្សះផ្សាលើបណ្តឹង[129]។

ដូចនេះ ប្រសិនបើមានការសះជាគ្នារវាងភាគីនៃវិវាទហើយ តុលាការត្រូវតែកត់ត្រាចំណុចដែលសះជាគ្នានោះនៅក្នុងកំណត់ហេតុ ហើយកំណត់ហេតុនោះនឹងមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ[130]។

ចំពោះការសះជាតាមផ្លូវបណ្តឹងនេះ គឺមានអត្ថប្រយោជន៍ខ្លាំងចំពោះការដោះស្រាយវិវាទនៅតុលាការ ដោយសារតែនីតិវិធីនៃការផ្សះផ្សានេះ ធ្វើឱ្យចំណេញនូវពេលវេលា និង ភាគីទទួលបានផលប្រយោជន៍រៀងៗខ្លួន ដោយពុំបានមានការកាត់សេចក្តីលម្អៀងទៅភាគីណាម្ខាង ពីព្រោះថាជាការព្រមព្រៀងផ្សះផ្សាគ្នារវាងភាគីផ្ទាល់ ហើយអាចរក្សានូវទំនាក់ទំនងល្អរវាងភាគីនៃវិវាទបានថែមទៀតផង។ ប្រសិនបើយើងធ្វើការប្រៀបធៀបការសះជានេះ ទៅនឹងការដោះស្រាយជម្លោះតាមរយៈការចេញសាលក្រមវិញ គឺការសះជានេះមានគុណសម្បត្តិច្រើនជាងដែលមានដូចជាៈ

➢ អាចបញ្ចប់ជម្លោះបានឆាប់រហ័ស ព្រោះតែមិនចាំបាច់អនុវត្តឱ្យបានពេញលេញតាមនីតិវិធីនៃការជំនុំជម្រះក្តី និង ពុំមានបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ប្រសិនបើភាគីគោរពអនុវត្តតាមកំណត់ហេតុសះជា។

➢ អាចទទួលនូវខ្លឹមសារនៃការសះជាសមរម្យដែលស្របទៅនឹងលក្ខណៈ និង ស្ថានភាពនៃរឿងក្តី។

➢ ភាគីនឹងអនុវត្តដោយស្ម័គ្រចិត្តនូវកាតព្វកិច្ចដែលបានសន្យាក្នុងការសះជា។

➢ អាចរក្សានូវភាពប្រក្រតីនូវទំនាក់ទំនងរវាងភាគី នាពេលអនាគតបាន។

នៅក្នុងការសាកល្បងផ្សះផ្សា តុលាការអាចធ្វើការផ្សះផ្សាបាន បើទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ ហើយចំពោះករណីដែលភាគីទាំងសងខាង ឬ ភាគីណាម្ខាងមានបំណងចង់ឱ្យតុលាការសាកល្បងផ្សះផ្សា តុលាការត្រូវគោរព និង ពិចារណាដល់បំណងនោះ ហើយធ្វើការសាកល្បងផ្សះផ្សា។

ម៉្យាងទៀត តាមធម្មតា ការផ្សះផ្សាអាចធ្វើទៅបាន នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល, កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និង កាលបរិច្ឆេទនៃការផ្សះផ្សា ហើយការ

---

[127] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៧

[128] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១០៤

[129] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២០

[130] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២២

ផ្សះផ្សាអាចធ្វើឡើងជាអសាធារណៈបាន នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការផ្សះផ្សា។

យ៉ាងណាមិញ ចំពោះហេតុការណ៍ដែលបានសួរ និង ដឹងឮនៅក្នុងនីតិវិធីនៃការផ្សះផ្សា ដែលធ្វើជាអសាធារណៈ មិនអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបានទេ ពីព្រោះថា ហេតុការណ៍ដែលអាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបាន គឺមានតែការអះអាងដែលភាគីបានធ្វើឡើងនៅពេលទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ និង លទ្ធផលនៃការពិនិត្យភស្តុតាងតែប៉ុណ្ណោះ។ មួយវិញទៀត ចំពោះការអះអាងដែលបានធ្វើនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ក៏អាចយកមកធ្វើជាមូលដ្ឋាននៃសាលក្រមបានដែរ ដោយសារតែបានធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនោះ ហើយត្រូវបានចាត់ទុកថាបានធ្វើសេចក្តីថ្លែងការណ៍នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។

ជាងនេះទៅទៀត ការបង្ហាញអំពីជំនឿទុកចិត្តនៅពេលផ្សះផ្សា ក៏ជាចំណុចសំខាន់មួយផងដែរ នៅពេលដែលជជែកគ្នាជាមួយនឹងភាគីដើម្បីផ្សះផ្សា តុលាការអាចបង្ហាញអំពីជំនឿទុកចិត្តរបស់ខ្លួន ប៉ុន្តែការបង្ហាញនូវជំនឿទុកចិត្តនេះ គឺជាបញ្ហាមួយដ៏ពិបាកនៅក្នុងការអនុវត្តជាក់ស្តែង ដែលជាទូទៅការបង្ហាញអំពីជំនឿទុកចិត្តរបស់តុលាការនៅក្នុងដំណាក់កាលដើមនៃបណ្តឹង មិនមែនជាវិធានការល្អនោះទេ ពីព្រោះថា ភាគីអាចនឹងមានអារម្មណ៍ថា តុលាការមានការលំអៀងចិត្តទៅភាគីម្ខាងទៀតដោយការបង្ហាញនូវជំនឿទុកចិត្តនេះ ហើយចំពោះជំនឿទុកចិត្តរបស់តុលាការនេះ អាចនឹងមានការប្រែប្រួលទៅតាមរយៈការពិនិត្យភស្តុតាងផ្សេងៗទៀតដែលនឹងធ្វើនៅពេលក្រោយពីនោះបាន។ ដោយឡែក នៅដំណាក់កាលក្រោយពីពេលបានបញ្ចប់ការពិនិត្យភស្តុតាងរួចរាល់ហើយ គឺនៅមុនពេលដែលនឹងត្រូវប្រកាសសាលក្រមនោះ ការបង្ហាញអំពីជំនឿទុកចិត្តរបស់តុលាការមិនសូវជាមានបញ្ហាចោទទេ។ ម្យ៉ាងទៀត ស្ថានភាពនៃរឿងក្តី គឺមានស្ថានភាពខុសៗពីគ្នាទៅតាមរឿងក្តីនីមួយៗ ហេតុនេះហើយ ការចាត់ចែងទៅតាមស្ថានភាពនីមួយៗរបស់តុលាការ គឺជាការសំខាន់។

យ៉ាងណាមិញ ក្នុងករណីដែលនីតិវិធីនៃការផ្សះផ្សាជាអសាធារណៈ ដើម្បីឱ្យការផ្សះផ្សាមានរបៀបរៀបរយក្នុងរយៈពេលដែលត្រូវបញ្ចុះបញ្ចូល តុលាការអាចជ្រើសរើសវិធីសមស្របដោយឆន្ទានុសិទ្ធិរបស់ខ្លួនបានដូចជាការទាមទារឱ្យភាគីណាម្ខាងដកខ្លួនចេញពីបន្ទប់ជាដើម។ ប៉ុន្តែការនិយាយជាមួយភាគីណាម្ខាង នៅពេលដែលភាគីម្ខាងទៀតអវត្តមាន គឺអាចមានគ្រោះថ្នាក់ ដោយអាចធ្វើឱ្យភាគីដែលត្រូវបានឱ្យចេញពីបន្ទប់នោះមានការសង្ស័យលើតុលាការថាមានការលម្អៀងទៅភាគីម្ខាងទៀតនោះ។ ដូចនេះហើយ មុននឹងសម្រេចឱ្យភាគីណាម្ខាងដកខ្លួនចេញពីបន្ទប់ដែលកំពុងតែដំណើរការនីតិវិធីផ្សះផ្សានេះ គប្បីសួរយោបល់ភាគីនោះជាមុនសិន ហើយប្រសិនបើភាគីនោះមិនយល់ព្រមនោះទេ តុលាការមិនគួរជ្រើសរើសវិធីនេះយកមកប្រើនោះទេ។ ឧទាហរណ៍៖ ដើមចោទ និង ចុងចម្លើយ កំពុងតែនៅក្នុងបន្ទប់ចៅក្រម ដែលកំពុងតែធ្វើនីតិវិធីផ្សះផ្សា ហើយចៅក្រមនោះក៏

បានទាមទារឱ្យដើមចោទដកខ្លួនចេញពីបន្ទប់បន្តិចសិន ដើម្បីឱ្យតុលាការសួរសំណួរមួយចំនួនដែលជាសំណួរទាក់ទងនឹងកិច្ចការងារផ្ទៃក្នុងរបស់ចុងចម្លើយ ដែលមិនគួរឱ្យដើមចោទដឹងនោះទេ ហើយដើមចោទក៏យល់ព្រម។ ប៉ុន្តែក្នុងករណីនេះ ប្រសិនបើដើមចោទមិនយល់ព្រម ដោយមានការសង្ស័យគិតថាចៅក្រមអាចនឹងស្តាប់ចម្លើយរបស់ចុងចម្លើយ ហើយធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ដើមចោទអាចធ្វើការបដិសេធបាន។

មួយវិញទៀត ប្រសិនបើតុលាការយល់ឃើញថាសមរម្យ តុលាការក៏អាចធ្វើការផ្សះផ្សាតាមផ្លូវបណ្តឹងនៅក្រៅតុលាការបានដែរ[131]។ ឧទាហរណ៍៖ ករណីជម្លោះពាក់ព័ន្ធនឹងព្រំដី ឬ ការសាងសង់ អាចជាករណីដែលគួរតែធ្វើការផ្សះផ្សានៅក្រៅតុលាការ ដោយត្រូវមើលស្ថានភាពផ្ទាល់នៅទីកន្លែងនៃជម្លោះ ឬ នៅក្នុងករណីខ្លះទៀត ដូចជា ភាគីណាម្ខាងមានជម្ងឺធ្ងន់ មិនអាចចូលខ្លួនមកតុលាការបាន នោះតុលាការអាចធ្វើការផ្សះផ្សានៅកន្លែងណាមួយសមស្របនៅក្រៅតុលាការបាន។

អ្វីដែលសំខាន់នោះ ក្នុងករណីដែលមានការសះជា ការលះបង់នូវការទាមទារ ឬ ការទទួលស្គាល់នូវការទាមទារ ត្រូវបានកត់ត្រាក្នុងកំណត់ហេតុ ហើយកំណត់ហេតុនោះមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ។ ដូចនេះហើយ តុលាការមិនចាំបាច់ចេញដីកាសម្រេចទទួលស្គាល់នូវការសះជានោះទេ គឺគ្រាន់តែសរសេរនៅក្នុងកំណត់ហេតុអំពីខ្លឹមសារនៃការសះជានោះទៅ ដូចនេះការសះជានោះនឹងមានអានុភាព។

ម៉្យាងទៀត ចំពោះកំណត់ហេតុសះជាដែលមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរ គឺមានដូចជាអានុភាពបញ្ចប់បណ្តឹង និង អាចមានអានុភាពអនុវត្ត ប្រសិនបើនៅក្នុងកំណត់ហេតុមានសរសេរអំពីខ្លឹមសារផ្តល់តាវកាលិកណាមួយ មានន័យថា ភាគីអាចយកកំណត់ហេតុនេះមកធ្វើជាលិខិតអនុវត្តដើម្បីដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំបាន[132]។ ដូចនេះ ប្រសិនបើភាគីដែលត្រូវទទួលអនុវត្តតាមរយៈកំណត់ហេតុសះជានេះ មិនបំពេញកាតព្វកិច្ចនោះទេ នាំឱ្យភាគីម្ខាងទៀតអាចធ្វើការស្នើសុំអនុវត្តដោយបង្ខំបាន ម៉្យាងទៀតចំណុចអនុវត្តដោយបង្ខំនេះ គឺជាចំណុចសំខាន់មួយដែលតែងតែត្រូវបានតុលាការយកមកពន្យល់ភាគីឱ្យឈានទៅរកការត្រូវរ៉ូវចុះសម្រុងនឹងគ្នា ដើម្បីឈានទៅដល់ការធ្វើការសះជា។ ប៉ុន្តែ ការសះជាពុំមានអានុភាពនៃអាជ្ញាអស់ជំនុំជាសារធាតុដូចសាលក្រមនោះទេ ពោលគឺប្រសិនបើមានជម្លោះកើតមានឡើងនៅក្រោយពេលដែលអានុភាពនៃកំណត់ហេតុនៃការសះជាត្រូវបានចាប់ផ្តើមនោះ គឺមិនអាចយកបញ្ញត្តិស្តីអំពីការសុំជំនុំជម្រះសាជាថ្មីមកអនុវត្តដូចនឹងការអនុវត្តរបស់សាលក្រមនោះទេ ដូចនេះប្រសិនបើមានជម្លោះក្រោយពីការបង្កើតអានុភាពនៃកំណត់ហេតុនៃការសះជានេះ គឺត្រូវធ្វើការស្នើសុំឱ្យកំណត់នូវកាលបរិច្ឆេទថ្មីដើម្បីបន្តនីតិវិធីជម្រះក្តីតទៅទៀត។ ហើយជា

[131] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២២០ កថាខណ្ឌទី២

[132] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣៥០ កថាខណ្ឌទី២ ចំណុច ឈ

ទូទៅនៅក្នុងកំណត់ហេតុនៃការសះជានេះ គឺត្រូវសរសេរអំពី ប្រភេទនៃការសះជា ដែលជាខ្លឹមសារនៃការសះជាគ្នាដែលបានព្រមព្រៀង ដោយមិនគួរសរសេរលម្អិតច្រើនហួសហេតុពេកអំពីការចរចារនៅក្នុងនីតិវិធីនៃការសះជានោះទេ ដោយសារតែនៅក្នុងដំណាក់កាលនៃការចរចារ ភាគីបាននិយាយដោយស្មោះអំពីបញ្ហានានា ហេតុនេះភាគច្រើនគឺជាករណីដែលមានការពិបាកក្នុងការយកមកសរសេរជាកំណត់ហេតុទុក។ លើសពីនេះទៀត ប្រការនៃការសះជា អាចជាករណីដែលអាចយកមកធ្វើការអនុវត្តបាន ដូចនេះ ត្រូវតែសរសេរនូវចំណុចនេះដោយប្រុងប្រយ័ត្នបំផុត និង កុំឱ្យមានការខ្វះខាតលើចំណុចណាមួយឡើយ ដើម្បីឱ្យមានលក្ខណៈច្បាស់លាស់ ហើយបន្ទាប់ពីបានសរសេររួចរាល់នូវកំណត់ហេតុនៃការសះជាទាំងមូលហើយ តុលាការគប្បីអានឱ្យភាគីទាំងសងខាងស្តាប់ និង សួរបញ្ជាក់បន្ថែមពីភាគីទាំងសងខាងនោះ។

បន្ទាប់ពីបានសិក្សាអំពីកថាខណ្ឌនៃការសះជាតាមផ្លូវបណ្តឹងរួចរាល់មក យើងនឹងធ្វើការសិក្សាបន្តទៅលើនីតិវិធីនៃការបញ្ចប់ដោយការចេញសាលក្រមវិញម្តង ដែលនឹងមានខ្លឹមសារដូចតទៅៈ

**កថាខណ្ឌទី២ៈ ការចេញសាលក្រម**

ចំពោះវិវាទដែលដោះស្រាយដោយការចេញសាលក្រម គឺជាវិវាទទាំងឡាយដែលកើតចេញពីបណ្តឹងដែលបានធ្វើឡើង ដោយមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និង ជាវិវាទដែលអាចដោះស្រាយបានដោយសាលក្រម រួមទាំងមិនបានធ្វើការសះជានៅក្នុងដំណាក់កាលណាមួយនៃនីតិវិធីជម្រះក្តីរបស់តុលាការ។ ដោយនីតិវិធីនៃការបញ្ចប់បណ្តឹង ត្រូវបានចាប់ផ្តើមនៅក្រោយពេលដែលតុលាការបានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយការប្រកាសសាលក្រម ហេតុនេះហើយសាលក្រមនឹងមានអានុភាពដោយការប្រកាស[133]។ ផ្ទុយមកវិញ សាលក្រមមិនអាចមានអានុភាពតាមរយៈការជូនដំណឹងដោយវិធីណាផ្សេង ក្រៅពីការប្រកាសសាលក្រមនេះបានឡើយ។

ម៉្យាងទៀត ចំពោះរយៈពេលដែលត្រូវបានកំណត់ ដើម្បីធ្វើការប្រកាសសាលក្រម គឺត្រូវធ្វើឡើងក្នុងអំឡុងពេល១ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ដោយការកំណត់អំឡុងពេល១ខែនេះ គឺជាអំឡុងពេលដែលតុលាការអាចមានឱកាសនៅក្នុងការស្រាវជ្រាវឱ្យបានស៊ីជម្រៅបន្ថែមទៀតអំពីអង្គហេតុ និងអង្គច្បាប់ រួមទាំងការត្រៀមពេលវេលាសម្រាប់ការសរសេរសាលក្រមឱ្យបានសមស្របផងដែរ។

យ៉ាងណាមិញ ចំពោះរបៀបនៃការប្រកាសសាលក្រម គឺត្រូវធ្វើឡើងតាមកាលបរិច្ឆេទ នៅក្នុងសាលសវនាការដែលបើកជាសាធារណៈ ដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ជាអ្នកអានសេចក្តីសម្រេចបញ្ចប់ ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម។ ប៉ុន្តែក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះមានធុរៈ ចៅក្រមប្រឹក្សា

[133] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨៦

អាចអានជំនួសបាន[134]។ ហើយការប្រកាសសាលក្រមនេះ អាចធ្វើបាន បើទោះបីជាគ្មានវត្តមានរបស់គូភាគីនៅក្នុងសាលសវនាការក៏ដោយ [135] ពីព្រោះថាភាគីមិនចាំបាច់ធ្វើសកម្មភាពអ្វីទាំងអស់ នៅពេលដែលតុលាការប្រកាសសាលក្រម។ ម៉្យាងទៀត បើទោះជាភាគីអវត្តមាននៅកាលបរិច្ឆេទនៃការប្រកាសសាលក្រមនេះក៏ដោយ ក៏សាលក្រមនោះមិនមែនជាសាលក្រមកំបាំងមុខដែរ។

ដោយឡែក នៅពេលប្រកាសសាលក្រម ប្រធានក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែអានសេចក្តីសម្រេចបញ្ចប់គឺជាការគ្រប់គ្រាន់ហើយ ប៉ុន្តែប្រសិនបើប្រធានក្រុមប្រឹក្សាយល់ឃើញថាសមរម្យ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចអានសំអាងហេតុនៃសាលក្រម ឬ ពន្យល់ខ្លឹមសារនៃសំអាងហេតុនោះដោយផ្ទាល់មាត់បាន[136]។ ជាពិសេសសាលក្រមត្រូវរៀបចំឡើងដោយយកចិត្តទុកដាក់បំផុត មុននឹងធ្វើការប្រកាសសាលក្រម ដូចនេះហើយគឺត្រូវធ្វើនូវលិខិតសាលក្រមជាមុនសិន។

**វាក្យខណ្ឌទី១៖ លិខិតសាលក្រម**

នៅមុនពេលដែលត្រូវធ្វើការប្រកាសសាលក្រម គឺតុលាការត្រូវធ្វើនូវលិខិតសាលក្រមជាមុនសិន ហើយចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងលិខិតសាលក្រម មានទម្រង់ដូចខាងក្រោម៖

- តុលាការ
- ថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់៖ ការទាមទារឱ្យសរសេរនូវថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នេះ គឺដោយសារតែសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តត្រូវបានកំណត់ជាស្ថាពរចាប់ពីថ្ងៃនេះទៅ[137]។
- ចំណុចនៃបណ្តឹង និង ភាគី
- អង្គហេតុ
  - ស្តីពីការទាមទារ
    - ការទាមទារតាមផ្លូវបណ្តឹងរបស់ដើមចោទ
    - ចម្លើយរបស់ចុងចម្លើយ ចំពោះការទាមទារនេះ
  - ស្តីពីការអះអាង៖ នៅពេលដែលសរសេរអំពីចំណុចនេះ គឺត្រូវប្រយ័ត្នអំពីបញ្ញត្តិស្តីពីការទទួលខុសត្រូវក្នុងការអះអាង ដោយតុលាការមិនអាចយកអង្គហេតុណា ដែលភាគីណាមួយមិនបានអះអាង មកធ្វើជា

[134] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨៨ កថាខណ្ឌទី១

[135] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨៨ កថាខណ្ឌទី២

[136] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨៨ កថាខណ្ឌទី៣

[137] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៩៤ កថាខណ្ឌទី២

មូលដ្ឋាននៃសាលក្រមបានឡើយ[138]។ មានន័យថា តុលាការមិនត្រូវធ្វើការទទួលស្គាល់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ, អង្គហេតុតវ៉ា ឬ អង្គហេតុតវ៉ាតប ដែលភាគីមិនបានអះអាងនៅពេលជំនុំជម្រះ យកមកធ្វើជាមូលដ្ឋានក្នុងការវិនិច្ឆ័យដើម្បីចេញសាលក្រមបាននោះទេ។ ម្យ៉ាងទៀត ការអះអាងនេះ គឺជាគោលការណ៍មួយនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលជាគោលការណ៍សំខាន់មួយនៅក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

- អង្គហេតុដែលជាមូលហេតុនៃការទាមទាររបស់ដើមចោទ
- ការទទួលស្គាល់ ឬ មិនទទួលស្គាល់ដោយចុងចម្លើយចំពោះអង្គហេតុទាំងនេះ
- ការតវ៉ារបស់ចុងចម្លើយ ប្រសិនបើមាន
- ការតវ៉ាតបរបស់ដើមចោទ ប្រសិនបើមាន

- ស្ដីពីចំណុចវិវាទ

➢ សំអាងហេតុៈ ជាការវិនិច្ឆ័យចំពោះចំណុចវិវាទ ថាតើអង្គហេតុដែលជាចំណុចត្រូវបានបញ្ជាក់ដោយភស្តុតាងដែរ ឬ ទេ?

➢ សេចក្ដីសម្រេចបញ្ចប់ៈ ជាសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម និង ជាការវិនិច្ឆ័យទៅលើការទាមទាររបស់ដើមចោទ។ នៅក្នុងចំណុចនេះ តុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ[139] ហើយតុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំឡើយ[140]។ ឧទាហរណ៍ៈ ដើមចោទបានទាមទារឱ្យចុងចម្លើយសងតែប្រាក់ដើមនៃប្រាក់កម្ចីតែប៉ុណ្ណោះ ដូចនេះហើយ តុលាការត្រូវចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយសងតែប្រាក់ដើមនៃប្រាក់កម្ចីតែប៉ុណ្ណោះ ដោយតុលាការមិនអាចចេញសាលក្រមដែលមានខ្លឹមសារបង្គាប់ឱ្យចុងចម្លើយសងការប្រាក់ដែលកំណត់ដោយបានច្បាប់នោះទេ។

➢ ចំណុចចុងក្រោយគេ គឺឈ្មោះរបស់ចៅក្រមដែលបានចូលរួមក្នុងការជំនុំជម្រះ និង ក្រឡាបញ្ជី រួមទាំងហត្ថលេខា និង ប្រថាប់ត្រារបស់តុលាការ។

ដូច្នេះហើយនៅពេលដែលធ្វើលិខិតសាលក្រមរួចរាល់អស់ហើយ តុលាការត្រូវធ្វើការប្រកាសសាលក្រមនៅកាលបរិច្ឆេទដែលបានកំណត់។ បន្ទាប់មក តុលាការត្រូវបញ្ជូនលិខិតសាលក្រមទៅឱ្យគូភាគី ក្នុងអំឡុងពេល២សប្ដាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនោះ ហើយការបញ្ជូនត្រូវបានធ្វើឡើងដោយ

[138] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៩៥

[139] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨២ កថាខណ្ឌទី១

[140] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៨២ កថាខណ្ឌទី២

អនុសារសាលក្រម[141] ។ ម៉្យាងទៀត អំឡុងពេលសម្រាប់ប្ដឹងឧទ្ធរណ៍ គឺត្រូវធ្វើនៅក្នុងអំឡុងគិតចាប់តាំងពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម[142]។ លើសពីនេះទៅទៀត នៅមានសាលក្រមកំបាំងមុខមួយទៀតដែលជាបញ្ហាចោទរបស់តុលាការ និង ជាចំណុចពិបាកមួយនៅក្នុងការអនុវត្តជាក់ស្តែងផងដែរ។

**វាក្យខណ្ឌទី២៖ សាលក្រមកំបាំងមុខ**

ជាគោលការណ៍ មូលហេតុដែលនាំឱ្យចេញនូវសាលក្រមកំបាំងមុខ គឺដោយសារតែអវត្តមានរបស់ភាគីនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយអវត្តមានរបស់ភាគី គឺសម្ដៅទៅលើ អវត្តមានរបស់ដើមចោទ ឬ អវត្តមានរបស់ចុងចម្លើយ។

ដោយផ្អែកតាមស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២០០ មានចែងអំពីការចេញសាលក្រមកំបាំងមុខក្នុងករណីដែលដើមចោទមិនបានបង្ហាញខ្លួន ដែលមានខ្លឹមសារដូចជា៖

➢ ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីសម្រាប់ការទាញហេតុផលទេ តុលាការត្រូវប្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ ដោយត្រូវបានសន្មតថា ដើមចោទគ្មានឆន្ទៈក្នុងការធ្វើទៅតាមនីតិវិធីនៃបណ្ដឹង[143]។

➢ ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន ដោយហេតុថា តុលាការមិនអាចសន្មតដោយភ្លាមៗថា ដើមចោទពុំមានឆន្ទៈក្នុងការធ្វើទៅតាមនីតិវិធីនៃបណ្ដឹងបានទេ។ ម៉្យាងទៀត តុលាការអាចគិតថា ដើមចោទមានបំណងចង់ឱ្យតុលាការធ្វើការវិនិច្ឆ័យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយហេតុថា ដើមចោទអាចនឹងយល់ឃើញថា តុលាការបានធ្វើការរៀបចំនូវចំណុចវិវាទបានគ្រប់គ្រាន់ល្មមហើយ ដូចនេះតុលាការមិនអាចចេញសាលក្រមកំបាំងមុខដោយភ្លាមៗបានទេ ដោយតុលាការត្រូវកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់[144]។

➢ ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការត្រូវប្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ។ ម៉្យាងទៀត នៅក្នុងកាល

---

[141] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា១៩០

[142] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២៦៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១

[143] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០០ កថាខណ្ឌទី១

[144] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០០ កថាខណ្ឌទី២

បរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនថាលើកទីប៉ុន្មានក៏ដោយ ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួននោះទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ។ យ៉ាងណាមិញ ដោយសារតែនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការធ្វើការពិនិត្យភស្តុតាងដោយសមូហវិធី ដូចនេះនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ មិនសូវមានកាលបរិច្ឆេទលើកក្រោយបន្តបន្ទាប់ច្រើននោះទេ[145]។

ដោយឡែក នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២០១ ក៏មានចែងអំពី ការចេញសាលក្រមកំបាំងមុខក្នុងករណីដែលចុងចម្លើយមិនបានបង្ហាញខ្លួន ដែលមានអត្ថន័យដូចតទៅ៖

➢ បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ដោយហេតុថា ប្រហែលជាអាចនឹងមានករណីដែលការទាមទាររបស់ដើមចោទមិនសមហេតុផល នៅក្នុងការអះអាងតែឯកឯងរបស់ដើមចោទ ដូចនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខភ្លាមៗបាននោះទេ ហើយតុលាការក៏មិនអាចចេញសាលក្រមដែលទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយមិនធ្វើទៅតាមការទាញហេតុផលដោយផ្ទាល់មាត់បាននោះទេ ដោយសារតែមូលហេតុនេះហើយ ទើបតុលាការត្រូវតែកំណត់កាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់ដើម្បីបន្តនីតិវិធី[146]។

➢ បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុទាំងអស់ដូចដែលដើមចោទបានអះអាង ហើយប្រសិនបើតុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ ប៉ុន្តែប្រសិនបើតុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវ ដោយពុំមានមូលហេតុត្រឹមត្រូវតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដូចដែលបានអះអាងទេនោះ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយចេញសាលក្រមធម្មតា គឺមិនអាចច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយចេញសាលក្រមកំបាំងមុខបាននោះទេ[147]។ យ៉ាងណាមិញ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបាននោះ នៅក្នុងករណី

[145] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០០ កថាខណ្ឌទី៣

[146] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០១ កថាខណ្ឌទី១

[147] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០១ កថាខណ្ឌទី២ វាក្យខណ្ឌទី១

ដែលចុងចម្លើយធ្វើវិវាទលើការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីមុនមក[148] ពោលគឺក្នុងករណីដែលតុលាការមិនអាចដឹងថា ចុងចម្លើយបដិសេធការអះអាងរបស់ដើមចោទ ឬ ទទួលសារភាព ដោយសារចុងចម្លើយមិនបានចូលរួមនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីកុំឱ្យមានការរាំងស្ទះនៅក្នុងការវិនិច្ឆ័យ បញ្ញត្តិនេះអនុញ្ញាតឱ្យតុលាការអាចចេញសាលក្រមទទួលស្គាល់ ឬ ច្រានចោលការទាមទារ ដោយចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ។ ដូចនេះ មានន័យថា ប្រសិនបើចុងចម្លើយបានបដិសេធចំពោះការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ការទាញហេតុផលដោយផ្ទាល់មាត់ពីមុន ទោះបីជាចុងចម្លើយនោះ មិនបានចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់នៅពេលក្រោយក៏ដោយ ក៏ការបដិសេធពីមុននៅតែមានអានុភាព ហើយមិនត្រូវចាត់ទុកការបដិសេធនោះ ថាជាការសារភាពនោះឡើយ ដូច្នេះហើយ តុលាការមិនអាចចេញសាលក្រមកំបាំងមុខចំពោះករណីបែបនេះទេ ពោលគឺចេញសាលក្រមធម្មតា[149]។

ក្រៅពីនេះ ក៏មាននូវករណីដែលតុលាការមិនអាចចេញសាលក្រមកំបាំងមុខបានផងដែរ ជាក់ស្តែងដូចជានៅក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២០២ មានចែងអំពី ករណីដែលមិនអាចចេញសាលក្រមកំបាំងមុខ ដូចមានខ្លឹមសារនៅខាងក្រោមនេះ៖

- ភាគីដែលមិនបានបង្ហាញខ្លួន មិនបានទទួលការកោះហៅស្របច្បាប់។
- ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបានពិតមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន ពោលគឺ ករណីដែលភាគីអវត្តមាន ដោយហេតុដែលមិនអាចជៀសវាងបានក្រៅឆន្ទៈរបស់ខ្លួន។
- បណ្តឹងមិនស្របច្បាប់ សម្តៅទៅលើករណីដែលខ្វះសមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ឬ សិទ្ធិតំណាង ជាដើម ដោយចំពោះករណីទាំងនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានទេ ប៉ុន្តែតុលាការត្រូវសម្រេចសេចក្តីដូចជា សាលក្រមលើកបណ្តឹងចោល[150]។
- ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅ

---

148 ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០១ កថាខណ្ឌទី២ វាក្យខណ្ឌទី២

149 សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០១ កថាខណ្ឌទី២ វាក្យខណ្ឌទី២

150 ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៨១

ចុងចម្លើយមុនកាលបរិច្ឆេទនោះ សម្ដៅទៅលើ បើទោះបីជាចុងចម្លើយមិនបានបង្ហាញខ្លួនក៏ដោយ ប្រសិនបើខ្លឹមសារនៃសេចក្ដីថ្លែងការណ៍របស់ដើមចោទ មិនត្រូវបានជូនដំណឹងទៅចុងចម្លើយ នៅមុនកាលបរិច្ឆេទទេ នោះតុលាការមិនត្រូវបានអនុញ្ញាតឱ្យចេញសាលក្រមកំបាំងមុខដែលទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្ដីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុនោះទេ មានន័យថា មិនត្រូវឱ្យចុងចម្លើយដែលមិនបានបង្ហាញខ្លួន ទទួលសាលក្រមកំបាំងមុខ ដោយផ្អែកលើអង្គហេតុដែលត្រូវបានអះអាងដោយដើមចោទ ទាំងដែលចុងចម្លើយមិនបានដឹងជាមុន[151]។ ឧទាហរណ៍៖ ដើមចោទ អះអាងអង្គហេតុដែលមិនបានសរសេរនៅក្នុងឯកសារត្រៀម ដែលនៅមុនពេលដែលធ្វើការអះអាងនេះ អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង គឺពុំមានភាពស៊ីសង្វាក់គ្នានោះទេ ប៉ុន្តែ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលមានវត្តមានរបស់ដើមចោទ ប៉ុន្តែគ្មានវត្តមានរបស់ចុងចម្លើយ ហើយដើមចោទបានអះអាងនូវអង្គហេតុថ្មី ដែលធ្វើឱ្យខ្លឹមសារដែលមានសរសេរនៅក្នុងពាក្យបណ្ដឹងនោះមានភាពស៊ីសង្វាក់គ្នាឡើងវិញ ដូចនេះតុលាការមិនអាចចេញសាលក្រមកំបាំងមុខ ដែលទទួលស្គាល់ការទាមទាររបស់ដើមចោទបានឡើយ ដោយហេតុថា អង្គហេតុនេះមិនត្រូវបានជូនដំណឹងទៅចុងចម្លើយជាមុន។

ផ្សេងពីនេះទៀត ការពន្យារកាលបរិច្ឆេទ ក៏ជាមូលហេតុសំខាន់មួយផងដែរ ដោយសារតែ ប្រសិនបើតុលាការយល់ឃើញថា អំឡុងពេលនៃការកោះហៅមានរយៈពេលខ្លីពេក ឬ ភាគីមិនអាចមកបង្ហាញខ្លួនបានដោយគ្មានកំហុសទេ តុលាការអាចពន្យារកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយប្រសិនបើតុលាការបានពន្យារនូវកាលបរិច្ឆេទនោះ តុលាការត្រូវធ្វើការកោះហៅភាគីដែលមិនបានបង្ហាញខ្លួននោះ តាមកាលបរិច្ឆេទថ្មីដែលតុលាការបានកំណត់[152]។ ចំពោះការពន្យារកាលបរិច្ឆេទនេះ គឺមានគោលបំណងទុកឱកាសសមរម្យឱ្យភាគីមានលទ្ធភាពចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទបាន ដើម្បីស្របតាមគោលការណ៍ចំពោះមុខ[153]។

លើសពីនេះទៅទៀត នៅពេលដែលតុលាការចេញសាលក្រមកំបាំងមុខរួចរាល់ហើយនោះ ចំពោះភាគីដែលមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ដោយសារមានមូលហេតុមិនអាចព្យាករណ៍បាន ឬហេតុដែលមិនអាចជៀសវាងបាន ហើយបានទទួលសាលក្រមកំបាំងមុខ ភាគីនោះអាចប្ដឹងទាស់ចំពោះសាល

[151] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០២ ចំណុច ឃ

[152] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០៣

[153] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា៣

ក្រមកំបាំងមុខនោះបាន[154]។ ចំណែកឯរយៈពេលដែលបើកសិទ្ធិឱ្យធ្វើការប្តឹងទាស់នឹងសាលក្រមកំបាំងមុខនេះត្រូវធ្វើឡើងក្នុងអំឡុងពេល២(ពីរ)សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ ហើយអំឡុងពេលនេះពុំអាចពន្យាបានឡើយ[155]។ ដោយឡែក ប្រសិនបើសាលក្រមកំបាំងមុខ ត្រូវបានបញ្ជូនតាមរយៈការបិទប្រកាសជាសាធារណៈ ឬ តាមរយៈការបញ្ជូននៅបរទេស តុលាការត្រូវកំណត់អំឡុងពេលដែលអាចប្តឹងទាស់ នៅក្នុងសាលក្រមកំបាំងមុខនោះ[156] ពោលគឺ តុលាការអាចកំណត់អំឡុងពេលដែលអាចប្តឹងទាស់បានលើសពី២(ពីរ)សប្តាហ៍បាន ដោយឆន្ទានុសិទ្ធិរបស់តុលាការ។

ជាងនេះទៅទៀត នីតិវិធីនៃការប្តឹងទាស់ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងទាស់ទៅតុលាការដែលបានចេញសាលក្រមកំបាំងមុខនោះ ហើយចំពោះចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹងទាស់នោះ គឺត្រូវសរសេរឱ្យស្របទៅតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២០៥ ដែមមានខ្លឹមសារដូចខាងក្រោម៖

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់។
- បំណងនៃការប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។
- មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា។

ម៉្យាងទៀត ប្រសិនបើពាក្យបណ្តឹងទាស់ដែលបានធ្វើឡើងមិនស្របទៅនឹងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២០៥ នោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្តឹងទាស់នោះ ដោយការពិនិត្យពាក្យបណ្តឹងទាស់នេះ គឺពិនិត្យទៅលើតែទម្រង់ប៉ុណ្ណោះ ហើយក្នុងករណីដែលភាគីដែលបានប្តឹងទាស់នោះ មិនបានកែតម្រូវនូវចំណុចខ្វះខាតតាមការបង្គាប់របស់តុលាការនោះទេ តុលាការត្រូវលើកបណ្តឹងទាស់នោះចោល ដោយដីកាសម្រេច ប៉ុន្តែដីកាសម្រេចនេះអាចធ្វើការប្តឹងជំទាស់បាន។ យ៉ាងណាមិញ ប្រសិនបើពាក្យបណ្តឹងទាស់គ្មានចំណុចខ្វះខាតទេ តុលាការត្រូវបញ្ជូនពាក្យបណ្តឹងទាស់នោះទៅភាគីម្ខាងទៀត ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យបណ្តឹងទាស់នោះ និង កោះហៅគូភាគីឱ្យចូលរួម[157]។

---

[154] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០៤ កថាខណ្ឌទី១

[155] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០៤ កថាខណ្ឌទី២

[156] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០៤ កថាខណ្ឌទី៣

[157] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០៦

យ៉ាងណាមិញ ចំពោះការវិនិច្ឆ័យ និង ការសម្រេចសេចក្ដីលើបណ្ដឹងទាស់ គឺ តុលាការត្រូវធ្វើការស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីភាពត្រឹមត្រូវនៃពាក្យបណ្ដឹងទាស់តាមទម្រង់ និង អំឡុងពេលដែលកំណត់ដោយច្បាប់ និង អំពីភាពត្រឹមត្រូវនៃមូលហេតុបណ្ដឹងទាស់។ ម៉្យាងទៀត តុលាការត្រូវលើកចោលនូវបណ្ដឹងទាស់ ដោយដីកាសម្រេច ប្រសិនបើយល់ឃើញថា ពាក្យបណ្ដឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ ពោលគឺសម្ដៅទៅលើទម្រង់ ប៉ុន្តែបើយល់ឃើញថា ពាក្យបណ្ដឹងនោះ គ្មានមូលហេតុត្រឹមត្រូវទេ ពោលគឺសម្ដៅទៅលើមូលហេតុដែលភាគីអាចប្ដឹងទាស់ចំពោះសាលក្រមកំបាំងមុខ ដូចបានកំណត់នៅក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២០៤ តុលាការត្រូវច្រានចោលបណ្ដឹងនោះដោយដីកាសម្រេច[158]។

ជាពិសេស អានុភាពនៃបណ្ដឹងទាស់ដែលត្រូវបានទទួលស្គាល់ គឺនៅពេលដែលពាក្យបណ្ដឹងទាស់ត្រូវបានទទួលស្គាល់ នីតិវិធីនៃបណ្ដឹងនោះត្រូវត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមាននោះកើតឡើង ហើយតុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីដើម្បីចាប់ផ្ដើមអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដើម្បីចាប់ផ្ដើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ ហើយត្រូវជូនដំណឹងនេះទៅឱ្យគូភាគី[159]។

ដូច្នេះហើយ សាលក្រមថ្មីដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញ ប្រសិនបើមានលទ្ធផលដូចសាលក្រមកំបាំងមុខ នោះតុលាការត្រូវចេញសាលក្រមថ្មីដែលប្រកាសថាតម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ។ ប៉ុន្តែប្រសិនបើសាលក្រមថ្មីដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញ គ្មានលទ្ធផលដូចសាលក្រមកំបាំងមុខទេ នោះតុលាការត្រូវលុបចោលសាលក្រមកំបាំងមុខនោះនៅក្នុងសាលក្រមថ្មីនោះ [160] ហើយចំពោះការលុបចោលសាលក្រមកំបាំងមុខនេះ អាចមានពីរករណី ពោលគឺ ករណីដែលលុបចោលទាំងអស់នៃសាលក្រមកំបាំងមុខ និង ករណីដែលលុបចោលតែមួយភាគនៃសាលក្រមកំបាំងមុខ[161]។ ម៉្យាងទៀត បើសាលក្រមកំបាំងមុខ ត្រូវបានធ្វើឡើងស្របតាមទម្រង់ដែលច្បាប់បានកំណត់ ទោះបីជាត្រូវលុបចោលសាលក្រមនោះ ដោយផ្អែកលើពាក្យបណ្ដឹងទាស់ក៏ដោយ ក៏សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន ត្រូវជាបន្ទុករបស់ភាគីដែលមិនបានបង្ហាញខ្លួនដែរ ឧទាហរណ៍៖ សោហ៊ុយសម្រាប់ការបញ្ជូនពាក្យបណ្ដឹងទាស់ សោហ៊ុយស្រាវជ្រាវមូលហេតុនៃបណ្ដឹងទាស់ ជាដើម ត្រូវជាបន្ទុករបស់ភាគីអវត្តមាន ដោយហេតុថា ភាគីម្ខាងទៀតមិនមានកំហុសនាំឱ្យមានការចំណាយបន្ថែម

[158] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០៧

[159] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០៨

[160] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មាត្រា២០៩

[161] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២០៩ កថាខណ្ឌទី២

នោះឡើយ លើកលែងតែករណីដែលសោហ៊ុយនោះបានកើតឡើង ដោយសារសកម្មភាពបណ្តឹងមិនត្រឹមត្រូវរបស់ភាគីម្ខាងទៀត[162]។

មួយវិញទៀត ប្រសិនបើភាគីដែលបានប្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូង ក្រោយពេលចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញទេ នោះតុលាការត្រូវច្រានចោលបណ្តឹងទាស់ ដោយសាលក្រមកំបាំងមុខម្តងទៀត លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា២០២ ដែលមានចែងអំពី ករណីដែលមិនអាចចេញសាលក្រមកំបាំងមុខ និង មាត្រា២០៣ កថាខណ្ឌទី៣ ដែលមានចែងអំពី ការពន្យារកាលបរិច្ឆេទ។ ហើយចំពោះសាលក្រមកំបាំងមុខលើកទី២នេះ គឺពុំបានបើកសិទ្ធិឱ្យភាគីអាចធ្វើការប្តឹងទាស់បានទៀតនោះទេ ពីព្រោះថា ភាគីអាចនឹងយកបញ្ញត្តិនៃការប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខនេះ ដើម្បីធ្វើការពន្យារពេលនូវនីតិវិធីនៃបណ្តឹងតែប៉ុណ្ណោះ[163]។

ក្រោយពីបានធ្វើការសិក្សាស្វែងយល់ និង បន្ទាប់ពីបានធ្វើការអត្ថាធិប្បាយ តាំងពីជំពូកទី១ គឺនីតិវិធីនៃការចាប់ផ្តើមបណ្តឹង រហូតមកដល់ជំពូកទី២ គឺនីតិវិធីនៃការជម្រះក្តីនេះ យើងបានឃើញអំពីតថភាពពិតនៃការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា និង តថភាពពិតនៃការអនុវត្តជាក់ស្តែងរបស់អ្នកវិជ្ជាជីវៈដែលកំពុងតែធ្វើការអនុវត្តសព្វថ្ងៃនេះ ឬ ប្រជាពលរដ្ឋដែលមានវិវាទនៅតុលាការ ពោលគឺមាននូវបញ្ហាប្រឈមមួយចំនួនដែលត្រូវបានចោទជាបញ្ហាឡើង ចំពោះការអនុវត្តជាក់ស្តែងដែលអ្នកវិជ្ជាជីវៈ និង ប្រជាពលរដ្ឋដែលមានវិវាទនៅតុលាការ កំពុងតែជួបប្រទះនៅពេលបច្ចុប្បន្ននេះ។ ហេតុដូចនេះហើយ យើងនឹងធ្វើការសិក្សាស្វែងរកនូវបញ្ហាប្រឈមទាំងអស់នោះ និង ព្យាយាមរកនូវវិធីសាស្ត្រល្អៗដើម្បីធ្វើការផ្តល់ជូននូវដំណោះស្រាយចំពោះបញ្ហាប្រឈមទាំងនោះ។

✍🕮✍

[162] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២១០

[163] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២១១

# ជំពូកទី៣
# បញ្ហាប្រឈម និង ដំណោះស្រាយ

ជាការពិតណាស់ នៅក្នុងការអនុវត្តជាក់ស្តែងរបស់អ្នកវិជ្ជាជីវៈ ឬ ប្រជាពលរដ្ឋដែលមានវិវាទនៅតុលាការ ចំពោះក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គឺពិតជាមានភាពស្មុគស្មាញ និង មាននូវបញ្ហាប្រឈម ជាច្រើនដែលត្រូវបានជួបប្រទះទៅតាមស្ថានភាពនៃរឿងក្តីនីមួយៗ ដែលបញ្ហាប្រឈម និង ដំណោះស្រាយ ចំពោះករណីទាំងអស់នោះ មានដូចតទៅ៖

## ផ្នែកទី១៖ បញ្ហាប្រឈម

នៅក្នុងការអនុវត្តជាក់ស្តែង ក៏ដូចជានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា យើងឃើញ ថាមាននូវបញ្ហាប្រឈមមួយចំនួន ដែលមានដូចជា៖ ការសរសេរ និង ការដាក់ពាក្យបណ្តឹង, ការបង់ប្រាក់ ប្រដាប់ក្តីតុលាការក្រៅពីពន្ធ, ពេលវេលាដំណើរការនីតិវិធីនៃការជំនុំជម្រះ, សមត្ថភាពរបស់ចៅក្រម, សកម្មភាព របស់តុលាការ, ការផ្តល់សិទ្ធិឲ្យភាគី, ការអនុវត្តនីតិវិធី, ការកំណត់ចំណុចវិវាទ និង ការយល់ដឹងផ្នែកច្បាប់របស់ ប្រជាពលរដ្ឋ។

### កថាខណ្ឌទី១៖ ការសរសេរ និង ការដាក់ពាក្យបណ្តឹង

នៅក្នុងដំណើរការនីតិវិធីនៃការដាក់ពាក្យបណ្តឹង យើងឃើញថា មាននូវបញ្ហាប្រឈមមួយចំនួនដែល ចោទជាបញ្ហាឡើង ធ្វើឱ្យមានផលវិបាកចំពោះការអនុវត្តជាក់ស្តែងដូចជា៖ ការសរសេរពាក្យបណ្តឹងរបស់ប្រជា ពលរដ្ឋ ការយកពាក្យបណ្តឹងទៅដាក់នៅស្ថាប័នតុលាការ ការគណនាពន្ធដាក់ពាក្យសុំ និង ការធ្វើចំណាត់ការ លើពាក្យបណ្តឹង។

#### វាក្យខណ្ឌទី១៖ ការសរសេរពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ

ការសរសេរពាក្យបណ្តឹង គឺជាចំណុចសំខាន់មួយ ហើយក៏ជាចំណុចដែលពិបាកនៅក្នុងការសរសេរផង ដែរ ដោយពាក្យបណ្តឹង គឺត្រូវសរសេរគោរពតាមទម្រង់ដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជា ណាចក្រកម្ពុជា មាត្រា៧៥ ប៉ុន្តែប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា មួយចំនួន គឺមិនយល់អំពីរបៀបនៃការ សរសេរពាក្យបណ្តឹងនេះទេ ពោលគឺ នៅពេលដែលប្រជាពលរដ្ឋធ្វើ ឬ សរសេរពាក្យបណ្តឹងដាក់ចូលទៅ តុលាការ ច្រើនតែខុសពីទម្រង់ មិនដឹងថាសរសេរយ៉ាងណាឱ្យត្រឹមត្រូវតាមបញ្ញត្តិនៃមាត្រា៧៥ និងមិនដឹងគួរ សរសេរពីចំណុចណា ហើយភាគច្រើនតែងតែធ្វើឡើងដោយខុសពីទម្រង់ច្បាប់។

#### វាក្យខណ្ឌទី២៖ ការយកពាក្យបណ្តឹងទៅដាក់នៅស្ថាប័នតុលាការ

នៅពេលដែលអ្នកដាក់ពាក្យបណ្តឹង បានយកពាក្យបណ្តឹងទៅដាក់នៅតុលាការ ហើយអ្នកទទួលពាក្យ បណ្តឹង ដែលជាបុគ្គលិករបស់លេខាធិការដ្ឋានរបស់តុលាការនោះ បានទទួល ដោយអ្នកទទួលពាក្យបណ្តឹង

បានពិនិត្យពាក្យបណ្តឹងនោះ ហើយអ្នកទទួលពាក្យបណ្តឹងបានយល់ឃើញថា ពាក្យបណ្តឹងនោះ បានធ្វើឡើងដោយមានលក្ខណៈខុសទម្រង់ដែលតុលាការបានណែនាំ ប៉ុន្តែនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានចែងអំពីទម្រង់នោះទេ ឧទាហរណ៍ដូចជា ទម្រង់នៃការគោរពចូលនៅក្នុងលិខិត ដោយត្រូវដាក់ថា សូមគោរពចូលមក លោកប្រធានសាលាដំបូង ប៉ុន្តែនៅក្នុងពាក្យបណ្តឹងនោះបានគោរពចូលឈ្មោះចៅក្រមដែលទទួលបន្ទុករឿងក្តីផ្ទាល់ ដូចនេះហើយ អ្នកទទួលពាក្យបណ្តឹងបានប្រាប់ទៅអ្នកដាក់ពាក្យបណ្តឹងឱ្យកែតម្រូវ ហើយអ្នកដាក់ពាក្យបណ្តឹង បានធ្វើការសំណូមពរឱ្យអ្នកទទួលពាក្យបណ្តឹងធ្វើការទទួលពាក្យបណ្តឹងនេះទៅ ដោយពុំចាំបាច់ធ្វើការកែតម្រូវទេ ហើយប្រសិនបើពាក្យបណ្តឹងនោះខុសពីទម្រង់មែន សុំឱ្យតុលាការធ្វើការបង្គាប់ឱ្យកែតម្រូវពាក្យបណ្តឹងនោះមក ប៉ុន្តែអ្នកទទួលពាក្យបណ្តឹង មិនព្រមទទួលពាក្យបណ្តឹងនោះទេ ដោយឱ្យអ្នកដាក់ពាក្យបណ្តឹងយកពាក្យបណ្តឹងទៅវិញ ដោយមិនព្រមធ្វើការបោះត្រា ចុះលេខ និង ចុះកាលបរិច្ឆេទនៅលើបណ្តឹងនោះទេ។ ចំពោះបញ្ហាប្រឈមបែបនេះ គឺមិនមែនមានតែចំពោះករណីដែលខុសទម្រង់ដូចដែលបានលើកឡើងនេះទេ ដោយនៅពេលខ្លះអ្នកទទួលពាក្យបណ្តឹង បានឃើញនូវចំណុចដែលខុសពីទម្រង់ដែលក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រឹមត្រូវតាមការត្រួតពិនិត្យប្រាកដមែន ហើយបានណែនាំឱ្យអ្នកដាក់ពាក្យបណ្តឹងទៅធ្វើការកែតម្រូវពាក្យបណ្តឹងនោះ ប៉ុន្តែនៅពេលដែលអ្នកដាក់ពាក្យបណ្តឹងបានបង្ហាញឆន្ទៈក្នុងការមិនកែតម្រូវ បែរជាអ្នកទទួលពាក្យបណ្តឹងមិនព្រមទទួលពាក្យបណ្តឹងនោះ ដែលទង្វើនេះបានប្រាសចាកឆ្ងាយពីស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា។

**ខណ្ឌទី៣៖ ការគណនាពន្ធដាក់ពាក្យសុំ**

នៅពេលដែលអ្នកដាក់ពាក្យបណ្តឹង យកពាក្យបណ្តឹងទៅដាក់នៅតុលាការ ដូចនេះអ្នកទទួលពាក្យបណ្តឹងដែលជាបុគ្គលិករបស់លេខាធិការដ្ឋានរបស់តុលាការ ត្រូវធ្វើការគណនាពន្ធលើតម្លៃកម្មវត្ថុនៃបណ្តឹងដែលពន្ធនោះគឺតម្រូវឱ្យអ្នកដាក់ពាក្យបណ្តឹងជាអ្នកទទួលបន្ទុក។ ប៉ុន្តែនៅពេលដែលរឿងក្តីដែលមានកម្មវត្ថុច្រើន និង ស្មុគស្មាញនៅក្នុងការគណនា អ្នកទទួលពាក្យបណ្តឹងបែរជាពុំមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការគណនាពន្ធលើតម្លៃកម្មវត្ថុនៃបណ្តឹងនោះ ដែលនាំឱ្យមានការយឺតយ៉ាវដល់នីតិវិធីរបស់តុលាការ។ ដោយឡែកនៅក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៦០ ដែលមានចែងអំពី ការគណនាតម្លៃកម្មវត្ថុនៃបណ្តឹង ការគណនាតម្លៃក្នុងករណីបណ្តឹងទាមទារច្រើនចំណុច និង មាត្រា៦១ ដែលមានចែងអំពីពន្ធដាក់ពាក្យសុំ មានលក្ខណៈស្មុគស្មាញ និង ពិបាកនៅក្នុងការសិក្សាស្វែងយល់ដែលជាមូលហេតុនាំឱ្យការគណនាពន្ធ គឺជាបញ្ហាប្រឈមមួយសម្រាប់ការអនុវត្តនីតិវិធីរបស់តុលាការ។

**វាក្យខណ្ឌទី៤៖ ការធ្វើចំណាត់ការលើពាក្យបណ្តឹង**

នៅពេលដែលពាក្យបណ្តឹង ត្រូវបានបញ្ជូនទៅដល់ចៅក្រមទទួលបន្ទុករឿងក្តីនោះ ហើយចៅក្រមបាន ពិនិត្យឃើញថា ពាក្យបណ្តឹងនោះធ្វើឡើងពុំបានត្រឹមត្រូវតាមទម្រង់ច្បាប់នោះទេ ប៉ុន្តែ ចៅក្រមនោះពុំបានធ្វើការ កំណត់ពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះខាតនោះទេ ដោយហេតុថា ខ្លួនមានសំណុំរឿងជាច្រើន ទៀតដែលត្រូវធ្វើចំណាត់ការនីតិវិធីបន្តភ្លាមៗ ហើយបានទុករឿងក្តីនោះចោលមួយឡែក ដោយពុំបានធ្វើ សកម្មភាពអ្វីសោះឡើយ ដែលនេះគឺជាហេតុនាំឱ្យមានការកកស្ទះសំណុំរឿងនៅតុលាការ។ ដោយឡែកនៅក្នុង បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៧៨ កថាខណ្ឌទី១ វាក្យខណ្ឌទី១ បាន កំណត់តែអំពី តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹង ដែលផ្ទុយនឹងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៧៥ កថាខណ្ឌទី២ ស្តីអំពី របៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ក្នុងអំឡុងពេលនោះតែប៉ុណ្ណោះ ដោយ មិនបានចែងឱ្យបានច្បាស់លាស់ អំពីរយៈពេលដែលកំណត់អំឡុងពេលឱ្យតុលាការត្រូវធ្វើការកំណត់អំឡុងពេល សមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹងនោះទេ។

**កថាខណ្ឌទី២៖ ការបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ**

ការបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ គឺជាបញ្ហាប្រឈមមួយដែលជារឿយៗ តែងតែជួបប្រទះនៅ ពេលអនុវត្តជាក់ស្តែងចំពោះក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលបញ្ហាប្រឈមនោះ គឺនៅ ពេលដែលតុលាការចេញដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ឱ្យមកអ្នកដាក់ពាក្យបណ្តឹងដើម្បី ចូលខ្លួនទៅបង់ប្រាក់នោះ ហើយនៅពេលដែលអ្នកដាក់ពាក្យបណ្តឹងទៅបង់ប្រាក់ប្រដាប់ក្តីនេះ ជារឿយៗ តុលាការគ្រាន់តែឱ្យមកអ្នកបង់ពន្ធនូវដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ តែប៉ុណ្ណោះ ដោយពុំ សូវចេញនូវវិក័យបត្រទទួលប្រាក់ប្រដាប់ក្តីនេះទេ ដែលវាអាចបង្កជាបញ្ហាថា តើអ្នកដាក់ពាក្យបណ្តឹងមានបាន ចូលខ្លួនទៅបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធនោះហើយ ឬ នៅ? ពីព្រោះថា ការណ៍ដែលត្រឹមតែទទួកយក នូវដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធនេះ ពីតុលាការមក គឺពុំមានលក្ខណៈស្តង់ដាណាមួយ ដែលអាចឱ្យធ្វើការកំណត់បានថា អ្នកបង់ប្រាក់ប្រដាប់ក្តីនោះ បានបង់រួច ឬក៏មិនទាន់បានបង់នោះទេ ប៉ុន្តែក៏ មានតុលាការខ្លះមានចេញនូវវិក័យបត្របញ្ជាក់អំពីការទទួលនូវប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធនេះដែរ។

**កថាខណ្ឌទី៣៖ ពេលវេលាដំណើរការនីតិវិធីនៃការជំនុំជម្រះ**

នៅក្នុងដំណើរការនីតិវិធីនៃការជំនុំជម្រះ ក៏មាននូវបញ្ហាផងដែរ ដែលអ្នកវិជ្ជាជីវៈ ឬ ប្រជាពលរដ្ឋដែលមាន វិវាទនៅតុលាការ តែងតែជួបប្រទះនៅពេលដែលនីតិវិធីនៃការជំនុំជម្រះកំពុងតែដំណើរការទៅតាមការដឹកនាំរបស់

ចៅក្រមទទួលបន្ទុករឿងក្តីនោះ ដែលបញ្ហាប្រឈមទាំងនោះមានដូចជា ៖ នីតិវិធីនៃការជំនុំជម្រះលឿនពេក និង នីតិវិធីនៃការជំនុំជម្រះយូរពេក។

**វាក្យខណ្ឌទី១៖ នីតិវិធីនៃការជំនុំជម្រះលឿនពេក**

នៅពេលដែលតុលាការចាប់ផ្តើមដំណើរការនីតិវិធីនៃការជំនុំជម្រះ មានរឿងក្តីមួយចំនួនដែលតុលាការបានធ្វើការជំនុំជម្រះដោយដឹកនាំនីតិវិធីប្រើពេលលឿនពេក ដែលបានធ្វើឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ភាគីចុងចម្លើយ ឬភាគីណាមួយ ដោយភាគីមិនមានពេលវេលាគ្រប់គ្រាប់ដើម្បីធ្វើការត្រៀមខ្លួននៅក្នុងការតវ៉ា តទល់ ការពារ និងស្វែងរកភស្តុតាងដើម្បីមកធ្វើការអះអាងបានទាន់ពេលវេលា។ ម្យ៉ាងទៀតប្រសិនបើភាគីមានបញ្ហាលើការយល់ដឹកផ្នែកច្បាប់ នឹងនាំឱ្យភាគីពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើការស្វែងរកមេធាវីដើម្បីឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យខ្លួនក្នុងការតវ៉ារឿងក្តី។ ដោយឡែក ការអនុវត្តនីតិវិធីនៃការជំនុំជម្រះដែលប្រើពេលវេលាលឿនពេកបែបនេះ អាចធ្វើឱ្យតុលាការប្រមូលពត៌មានដែលពាក់ព័ន្ធនឹងរឿងក្តីមិនបានគ្រប់ជ្រុងជ្រោយ ដែលអាចធ្វើឱ្យតុលាការសម្រេចសេចក្តីដោយធ្វើការវិនិច្ឆ័យសម្រេចសេចក្តីមិនបានត្រឹមត្រូវ ដែលអាចផ្តល់ភាពយុត្តិធម៌ដល់ភាគីនៃវិវាទ ជាពិសេសគឺអាចនឹងប៉ះពាល់ដល់សិទ្ធិរបស់ភាគីចុងចម្លើយខ្លាំង ពីព្រោះថាមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់ដល់ភាគីចុងចម្លើយ ដែលអាចបង្កើតបានជារូបភាពអយុត្តិធម៌ចំពោះភាគីចុងចម្លើយ។

**វាក្យខណ្ឌទី២៖ នីតិវិធីនៃការជំនុំជម្រះយូរពេក**

នៅក្នុងដំណើរការនីតិវិធីនៃការជំនុំជម្រះក្តី ដែលបានចាត់ការ ឬដោះស្រាយតាមរយៈប្រព័ន្ធតុលាការ គឺមានរឿងក្តីមួយចំនួន ដែលតុលាការបានធ្វើការជំនុំជម្រះដោយដឹកនាំនីតិវិធីប្រើប្រាស់រយៈពេលយូរពេក នាំឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍ និងសិទ្ធិរបស់ភាគីនៃវិវាទជាខ្លាំង។ ជាពិសេសគឺភាគីដើមចោទ ដោយនៅក្នុងករណីរឿងក្តីមួយចំនួន ការទាមទារតម្រូវឱ្យធ្វើការអនុវត្តភ្លាមៗ ឱ្យបានទាន់ពេលវេលានៅលើកម្មវត្ថុនៃបណ្តឹង ដោយមិនអាចបង្អង់បាននោះទេ ហើយប្រសិនបើមិនបានធ្វើការអនុវត្តបានទាន់ពេលវេលានោះទេ កម្មវត្ថុនៃវិវាទអាចនឹងមានស្ថានភាពផ្លាស់ប្តូរតម្លៃ គុណភាព ឬ រូបរាង ទៅតាមស្ថានភាពជាក់ស្តែង ទម្រាំតែតុលាការបានធ្វើការវិនិច្ឆ័យសម្រេចសេចក្តី និង ចេញសាលក្រមនោះ។

ឧទាហរណ៍៖ ដើមចោទ បានប្តឹងសុំទាមទារឱ្យតុលាការចេញសាលក្រម បង្គាប់ឱ្យចុងចម្លើយអនុវត្តតាមកិច្ចសន្យាទិញលក់ ដែលបានចុះហត្ថលេខាព្រមព្រៀងគ្នាក្នុងការទិញលក់ ឱ្យធ្វើការផ្ទេរកម្មសិទ្ធិលើដីដែលបានធ្វើការទិញលក់នោះមកឱ្យដើមចោទតាមកិច្ចសន្យាដែលបានចុះហត្ថលេខានោះ ហើយដើមចោទថែមទាំងបានដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេចរក្សាការពារថែមទៀតផង។ ដោយឡែក តុលាការក៏បានចេញដីកាសម្រេចរក្សាការពារលើដីរបស់ចុងចម្លើយតាមការស្នើសុំរបស់ដើមចោទផងដែរ ប៉ុន្តែខណៈពេលដែលដីរបស់ចុងចម្លើយនោះត្រូវបានតុលាការចេញដីកាសម្រេចរក្សាការពារនេះ ចុងចម្លើយក៏បានប្តឹងសុំតវ៉ាលើដីកាសម្រេចរក្សា

ការពាររបស់តុលាការនោះវិញ រហូតដល់តុលាការបានចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារដែលដើមចោទបានប្តឹងនោះថែមទៀតផង។ ដូចនេះនៅពេលដែលដីរបស់ចុងចម្លើយលែងមានជាប់ពាក់ព័ន្ធនឹងការរក្សាការពាររបស់តុលាការហើយនោះ ចុងចម្លើយក៏បានធ្វើការទិញលក់ថ្មីមួយទៀតជាមួយតតិយជន ដែលទទួលបានតម្លៃខ្ពស់ជាងពេលដែលធ្វើការទិញលក់ជាមួយដើមចោទដល់ទៅ៥ដង ទាំងដែលការប្តឹងទាមទាររបស់ដើមចោទឱ្យតុលាការចេញសាលក្រមខាងលើនោះពុំទាន់បានធ្វើការសម្រេចសេចក្តីនៅឡើយ។ ហេតុនេះហើយ បញ្ហានេះ គឺជាបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និង ផលប្រយោជន៍របស់ភាគីដើមចោទជាខ្លាំង រួមទាំងធ្វើឱ្យរឿងក្តីកាន់តែមានភាពស្មុគស្មាញ និង ពិបាកនៅក្នុងការដោះស្រាយ។

**កថាខណ្ឌទី៤៖ សមត្ថភាពរបស់ចៅក្រម**

សមត្ថភាពរបស់ចៅក្រមទទួលបន្ទុករឿងក្តី គឺជាបញ្ហាសំខាន់មួយ ហើយក៏ជាបញ្ហាចោទមួយផងដែរដែលជាទូទៅ ច្រើនតែកើតមាននូវបញ្ហានេះឡើង ចំពោះចៅក្រមដែលទើបតែចេញធ្វើការអនុវត្តផ្ទាល់ ពុំទាន់មានបទពិសោធន៍ច្រើននៅឡើយ ពោលគឺចៅក្រមដែលទើបតែបញ្ចប់កម្មសិក្សា ហើយក្លាយខ្លួនទៅជាចៅក្រមពេញសិទ្ធិ មានន័យថា ការវិនិច្ឆ័យសម្រេចសេចក្តីរបស់ចៅក្រមទាំងនោះ អាចនឹងមិនត្រឹមត្រូវ ឬ អាចនឹងមានការលម្អៀងទៅភាគីណាម្ខាងនៃភាគីវិវាទ ដោយសារតែស្ថានភាពនៃរឿងក្តីនោះ បានបង្ហាញរូបភាពឱ្យចៅក្រមដែលទទួលបន្ទុកយល់ឃើញបែបនោះ ព្រោះចៅក្រមដែលទទួលបន្ទុកមិនទាន់មានសមត្ថភាពគ្រប់គ្រាន់នៅក្នុងការវិនិច្ឆ័យសម្រេចសេចក្តី ហើយការកាត់ក្តីបែបនេះ អាចនឹងធ្វើឱ្យមិនមានតម្លាភាពចំពោះភាគី មិនផ្តល់ភាពយុត្តិធម៌ដល់ភាគីដែលចាញ់ក្តី និង ប៉ះពាល់យ៉ាងខ្លាំងដល់ផលប្រយោជន៍របស់ភាគីនៃវិវាទ។ ម្យ៉ាងទៀត ការសម្រេចសេចក្តីបែបនេះអាចធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សង្គមយ៉ាងធ្ងន់ធ្ងរ ដែលនាំឱ្យអ្នកវិជ្ជាជីវៈច្បាប់ អ្នកសិក្សាផ្នែកច្បាប់ និង ប្រជាពលរដ្ឋលែងមានទំនុកចិត្តលើការសម្រេចសេចក្តីរបស់តុលាការ ដែលតុលាការនឹងមិនអាចផ្តល់ភាពយុត្តិធម៌ត្រឹមត្រូវតាមច្បាប់ដល់ភាគីនៃវិវាទទៀតឡើយ។ ជាងនេះទៅទៀត អំណាចរបស់ស្ថាប័នតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជានឹងចុះអន់ថយជាលំដាប់ ដោយហេតុថា អ្នកវិជ្ជាជីវៈច្បាប់ អ្នកសិក្សាច្បាប់ និង ប្រជាពលរដ្ឋលែងមានទំនុកចិត្តលើឯករាជ្យភាព និង អព្យាក្រឹត្យភាពរបស់តុលាការលើការផ្តល់យុត្តិធម៌ជូនសង្គមជាតិ។

**កថាខណ្ឌទី៥៖ សកម្មភាពរបស់តុលាការ**

នៅក្នុងដំណើរការនៃរឿងក្តីរដ្ឋប្បវេណី យើងឃើញថាទាំងការអនុវត្តជាក់ស្តែង និង អ្វីដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គឺពុំមានចែងអំពីសកម្មភាពដែលតុលាការជួយជ្រោមជ្រែងដល់ដំណើរការនៃរឿងក្តីរដ្ឋប្បវេណីនោះទេ ពោលគឺយើងអាចសន្និដ្ឋានបានថា តុលាការមានលក្ខណៈអសកម្មចំពោះរឿងក្តីរដ្ឋប្បវេណី។ ជាក់ស្តែងដូចជា ករណីការបញ្ជូនដីកាកោះហៅភាគីឱ្យចូលរួមក្នុងនីតិវិធី ៖ នៅពេលដែលដើមចោទបានបង់

ប្រាក់ប្រដាប់ក្ដីតាមការបង្គាប់របស់តុលាការហើយ តុលាការចាប់ផ្ដើមចេញដីកាកោះហៅគូភាគីនៃរឿងក្ដីឱ្យចូលរួមទៅតាមនីតិវិធីនីមួយៗ ប៉ុន្តែនៅពេលដែលបានចេញដីកាកោះហៅគូភាគីរួចរាល់ហើយ បែរការមានការរអាក់រអួល ឬ មានបញ្ហានៅពេលដែលបញ្ជូនដីកាកោះហៅនោះ ដោយមូលហេតុផ្សេងៗដូចជា ភាគីមិនមែនស្នាក់នៅអាសយដ្ឋានដែលមានសរសេរនៅក្នុងដីកាកោះហៅនោះ ឬ ភាគីគេចវេសមិនព្រមទទួលយកនូវដីកាកោះនោះ ឬ ភាគីទទួលយកដីកោះហៅហើយ តែមិនចូលរួមទៅតាមកាលបរិច្ឆេទកំណត់ជាដើម។ល។ ដោយមូលហេតុទាំងនេះហើយ ដែលធ្វើឱ្យដំណើរការនៃរឿងក្ដីមានភាពយឺតយ៉ាវ និង ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដើមចោទយ៉ាងធ្ងន់ធ្ងរ។ ម៉្យាងទៀត នៅក្នុងដំណើរការនីតិវិធីរឿងក្ដីរដ្ឋប្បវេណីនេះផងដែរ តុលាការហាក់បីដូចជា មិនបានជូនដំណឹងគ្រប់គ្រាន់ដល់ភាគីនៃវិវាទ អំពីដំណើរការនៃលំហូរនីតិវិធីឱ្យបានជាប់លាប់ ឧទាហរណ៍ដូចជា៖ តុលាការមិនបានជូនដំណឹងដល់ភាគីអំពីការបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលជាហេតុនាំឱ្យនៅកាលបរិច្ឆេទដែលត្រូវប្រកាសសាលក្រម ភាគីក៏ពុំបានទទួលដំណឹង ដែលធ្វើឱ្យនីតិវិធីនៃការប្រកាសសាលក្រម គឺជាសាលក្រមកំបាំងមុខ ដែលនាំឱ្យដំណើរការនីតិវិធីអូសបន្លាយពេលវេលា ខូចខាតដល់ផលប្រយោជន៍ភាគីនៃវិវាទ និង ធ្វើឱ្យប្រាសចាកពីគោលការណ៍ចំពោះមុខ ដែលជាគោលការណ៍សំខាន់មួយនៃក្រមនីតិវិធីរដ្ឋប្បវេណី។

**កថាខណ្ឌទី៦៖ ការផ្ដល់សិទ្ធិឱ្យភាគីនៅក្នុងដំណើរការនីតិវិធីជម្រះក្ដី**

នៅក្នុងដំណើរការនីតិវិធីរបស់តុលការ យើងសង្កេតឃើញថា នៅក្នុងរឿងក្ដីមួយចំនួនដែលត្រូវបានដោះស្រាយដោយតុលាការ គឺមានលក្ខណៈបិទសិទ្ធិភាគីមិនឱ្យធ្វើការតទល់ ឬ តតាំងគ្នា ដែលជាហេតុនាំឱ្យតុលាការពុំមានមូលដ្ឋានគ្រប់គ្រាន់នៅក្នុងការសម្រេចសេចក្ដី ពីព្រោះតែភាគីពុំបានអះអាង ថ្លែងការណ៍ ឬ បង្ហាញភស្តុតាងបានគ្រប់គ្រាន់នៅក្នុងដំណើរការនៃនីតិវិធីរដ្ឋប្បវេណី។ ដោយឡែកនៅក្នុងដំណើរការនីតិវិធីរបស់តុលាការនេះទៀតសោធ ចំពោះរឿងក្ដីមួយចំនួនយើងឃើញថា តុលាការ ក៏បានធ្វើការបិទសិទ្ធិមេធាវីតំណាងដោយអាណត្តិឱ្យភាគីនៅក្នុងរឿក្ដី លើការធ្វើសកម្មភាពផ្សេងៗនៅក្នុងនីតិវិធីផងដែរ ដូចជា ការធ្វើសេចក្ដីថ្លែងការណ៍ ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន ក៏ដូចជាការស្នើសុំពន្យារពេលនីតិវិធីជាដើម។ល។ ដោយទង្វើនេះធ្វើឱ្យប៉ះពាល់ដល់តម្លៃវិជ្ជាជីវៈមេធាវី ប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃវិវាទ និងធ្វើឱ្យភាគីដែលបានប្រើប្រាស់សេវាមេធាវីមានអារម្មណ៍ថា មេធាវីពុំបានជួយអ្វីដល់ខ្លួននាពេលដំណើរការនីតិវិធីសោះឡើយ។

**ឃាក្យខណ្ឌទី១៖ ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន**

នៅក្នុងដំណើរការនីតិវិធីរឿងក្ដីរដ្ឋប្បវេណី ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន គឺជាឯកសារសំខាន់មួយសម្រាប់ជាមូលដ្ឋានឱ្យភាគីនៃវិវាទ អាចបង្ហាញនូវរឿងរ៉ាវជាក់លាក់ជូនដល់តុលាការ និង ដើម្បី

អាចឱ្យតុលាការយកមកធ្វើជាមូលដ្ឋាននៅក្នុងការវិនិច្ឆ័យរឿងក្តីផងដែរ។ យ៉ាងណាមិញ នៅក្នុងការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួននេះ យើងសង្កេតឃើញថា នៅក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា ៩៣ ដែលមានចែងអំពីពេលវេលាដែលត្រូវដាក់មធ្យោបាយនេះ និង មាត្រា ៩៤ ដែលមានចែងអំពីការលើកចោលមធ្យោបាយនេះ គឺ មិនមានចែងអំពីពេលវេលាច្បាស់លាស់នោះទេ ពោលគឺគ្រាន់តែចែងថា ពេលវេលាសមរម្យតែប៉ុណ្ណោះ ដែលជាហេតុអាចធ្វើឱ្យមានការបកស្រាយអំពីពេលវេលាណាដែលជាពេលវេលាសមរម្យ និង ពេលវេលាណាដែលជាពេលវេលាមិនសមរម្យ។ ម្យ៉ាងទៀត នៅពេលដែលមិនបានកំណត់អំពីពេលច្បាស់លាស់បែបនេះ នាំឱ្យការសម្រេចចិត្តដោយឆន្ទានុសិទ្ធិរបស់តុលាការអាចនឹងមានបញ្ហា និង អាចប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃវិវាទថែមទៀតផង ឧទាហរណ៍៖ ដើមចោទបានដាក់មធ្យោបាយតទល់ របស់ខ្លួនមុនពេលចូលរួមនីតិវិធីចំនួន៥ថ្ងៃ រីឯចុងចម្លើយបានដាក់មធ្យោបាយការពារខ្លួនរបស់ខ្លួនមុនពេលចូលរួមនីតិវិធីចំនួន៥ថ្ងៃដូចគ្នា ប៉ុន្តែតុលាការសម្រេចលើកចោលការដាក់មធ្យោបាយតទល់របស់ដើមចោទចោល ដោយសំអាងអំពីការដាក់នោះយឺតយ៉ាវមិនត្រូវនឹងពេលវេលាសមរម្យ ហើយបែរជាទទួលយកការដាក់មធ្យោបាយការពារខ្លួនរបស់ចុងចម្លើយទៅវិញ។

**វាក្យខណ្ឌទី២៖ ការធ្វើសេចក្តីថ្លែងការណ៍**

ការធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីជម្រះក្តី គឺជាផ្នែកដ៏សំខាន់មួយ ដែលភាគី ឬ អ្នកតំណាងដោយអាណត្តិឱ្យភាគី ត្រូវធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីនីមួយៗនៃការជំនុំជម្រះក្តី ដើម្បីតុលាការបានយល់អំពីគោលបំណងនៃការអះអាងរបស់ភាគី និង ដើម្បីធ្វើជាមូលដ្ឋាននៅក្នុងការពិចារណាសម្រេចសេចក្តីលើរឿងក្តីនោះផងដែរ។ ដោយឡែកនៅក្នុងការធ្វើសេចក្តីថ្លែងការណ៍ នៅក្នុងរឿងក្តីមួយចំនួនគឺមាននូវបញ្ហាខ្លះបានកើតមានឡើង ដែលជាហេតុនាំឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការធ្វើសេចក្តីថ្លែងការរបស់ភាគី ឬ មេធាវីតំណាងដោយអាណត្តិឱ្យភាគី ដូចជា៖

នៅក្នុងដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីរបស់តុលាការ យើងសង្កេតឃើញថា មានរឿងក្តីមួយចំនួនតុលាការបានធ្វើការរឹតត្បិតលើការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី នៅពេលដែលកំពុងតែអនុវត្តនូវដំណើរការនីតិវិធីនៃការជំនុំជម្រះ ដោយលើកមូលហេតុថាឱ្យភាគីធ្វើសេចក្តីថ្លែងការណ៍ខ្លីៗ ដែលអាចឱ្យតុលាការយល់បានគឺគ្រប់គ្រាន់ហើយ ពីព្រោះនៅមានសំណុំរឿងជាច្រើនទៀតដែលត្រូវធ្វើការជំនុំជម្រះបន្ត។ ការធ្វើបែបនេះ គឺប៉ះពាល់ដល់សិទ្ធិ ផលប្រយោជន៍ និង ស្ថានភាពនៃរឿងក្តីខ្លាំងបំផុត ដោយសារតែ តុលាការពុំបានទទួលពត៌មានពិតបានអស់ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ធ្វើការវិនិច្ឆ័យស្វែងរកយុត្តិធម៌ជូនដល់ភាគីនោះទេ ពោលគឺស្តាប់តែចំណុចមួយចំនួនដែលភាគីបានលើកឡើងខ្លីៗ ហើយធ្វើការវិនិច្ឆ័យសម្រេចសេចក្តីយកតែម្តង ដែល

អាចធ្វើឱ្យប្រាសចាកចេញពីរឿងពិតដែលភាគីបានជួបប្រទះ និង អាចមិនបានផ្តល់នូវតម្លាភាពចំពោះមុខច្បាប់ដល់ភាគីថែមទៀតផង។

ដោយឡែក ករណីផ្សេងពីនេះ ដូចជា នៅក្នុងរឿងក្តីមួយចំនួន ក៏ដូចជាការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា ភាគីទាំងសងខាងរមែងតែងតែមាននូវអ្នកតំណាងដោយអាណត្តិរៀងៗខ្លួន ពោលគឺមេធាវីតំណាងដោយអាណត្តិ ដូចនេះហើយ នៅក្នុងដំណើរការនីតិវិធីនៃការជំនុំជម្រះក្តី ភាគីច្រើនគឺ មេធាវី ជាអ្នកដើរតួតំណាងឱ្យកូនក្តីរបស់ខ្លួនដែលជាភាគីនៃវិវាទ នៅក្នុងដំណើរការនីតិវិធីនីមួយៗយ៉ាងពេញលេញ។ ដោយឡែកនៅក្នុងរឿងក្តីមួយចំនួន យើងឃើញថា តុលាការ បានបិទសិទ្ធិមេធាវីមិនឱ្យធ្វើសេចក្តីថ្លែងការណ៍ ឬ អះអាងនោះទេ ពោលគឺនៅក្នុងដំណើរការនីតិវិធីមេធាវីទាំងសងខាង ឬ មេធាវីម្ខាង មិនបាននិយាយអ្វីសោះឡើយដែលទង្វើនេះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និង ផលប្រយោជន៍របស់ភាគីនៃវិវាទ ដែលមិនបានអះអាងអ្វីសោះឡើយហើយក៏ជាបញ្ហាដែលនាំឱ្យមានការវិនិច្ឆ័យ សម្រេចសេចក្តីលម្អៀងផងដែរ។ ឧទាហរណ៍៖ មេធាវីរបស់ភាគីដើមចោទ បានឡើងធ្វើសេចក្តីថ្លែងការណ៍ ដោយរៀបរាប់អំពីដំណើររឿង ដែលជាអង្គហេតុប្រទាក់ក្រឡាគ្នាតាំងពីពេលចាប់ផ្តើម រហូតដល់ដំណាក់កាលនីមួយៗ ប៉ុន្តែខណៈនោះស្រាប់តែតុលាការ បានបញ្ឈប់ការថ្លែងការណ៍របស់មេធាវីនោះ ដោយហេតុថា មេធាវីម្ខាងទៀត ដែលជាមេធាវីរបស់ភាគីចុងចម្លើយបានស្នើសុំកាត់នូវការធ្វើសេចក្តីថ្លែងការណ៍របស់មេធាវី ដែលជាមេធាវីតំណាងដោយអាណត្តិឱ្យភាគីដើមចោទ ដោយលើកមូលហេតុថាមេធាវីរបស់ភាគីដើមចោទធ្វើការថ្លែងការណ៍ ឬ អះអាងមិនសមស្រប ឬ ត្រឹមត្រូវតាមអង្គហេតុពិត ហើយតុលាការក៏បានឱ្យមេធាវីរបស់ភាគីដើមចោទបន្តធ្វើសេចក្តីថ្លែងការណ៍ទៅទៀត។ លុះដល់ពេលដែលមេធាវីរបស់ដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ចប់ ហើយក៏ជិតដល់ពេលវេលាដែលត្រូវសម្រាកផងនោះ តុលាការក៏បានបង្គាប់ទៅមេធាវីចុងចម្លើយឱ្យធ្វើសេចក្តីថ្លែងការណ៍ខ្លីៗ ដែលខ្លួនបដិសេធ មិនឯកភាពតាមអ្វីដែលមេធាវីរបស់ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍មុននេះទៅគឺបានហើយ ដោយមេធាវីរបស់ចុងចម្លើយ យល់ឃើញថាអង្គហេតុដែលមេធាវីរបស់ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍នោះ គឺមានលក្ខណៈខុសគ្នាច្រើននឹងអង្គហេតុពិត ហើយក៏មាននូវអង្គហេតុប្រយោលច្រើន ក៏មេធាវីរបស់ចុងចម្លើយ ចាប់ផ្តើមធ្វើសេចក្តីថ្លែងការណ៍អំពីដំណើររឿងតាំងពីដំបូងមក រហូតទៅតាមដំណាក់កាលនីមួយៗ ប៉ុន្តែនៅពេលដែលមេធាវីរបស់ចុងចម្លើយកំពុងតែធ្វើសេចក្តីថ្លែងការណ៍ ស្រាប់តែតុលាការធ្វើការបញ្ឈប់ ដោយលើកឡើងថា ឱ្យមេធាវីរបស់ចុងចម្លើយ ធ្វើការបដិសេធចំពោះចំណុចដែលខ្លួនគិតថាមិនត្រឹមត្រូវលើការធ្វើសេចក្តីថ្លែងការណ៍របស់មេធាវីរបស់ដើមចោទទៅបានហើយ ដែលទង្វើបែបហាក់បីដូចជាមិនបានផ្តល់សិទ្ធិឱ្យមេធាវីរបស់ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍របស់ខ្លួននោះទេ ពោលគឺគ្រាន់តែបង្ហាញនូវចំណុចដែលខ្លួនគិតថាមិនត្រឹមត្រូវចំពោះអ្វីដែលមេធាវីរបស់ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍រួចរាល់ហើយនោះ។

**វាក្យខណ្ឌទី៣៖ ការស្នើសុំពន្យារពេលនីតិវិធី**

នៅក្នុងដំណើរការនីតិវិធីរបស់តុលាការ យើងឃើញថា ការអនុវត្តជាក់ស្តែង គឺមានរឿងក្តីជាច្រើនដែលភាគីនៃវិវាទ ឬ មេធាវីតំណាងដោយអាណត្តិឱ្យភាគី តែងតែស្នើសុំធ្វើការពន្យារពេលនីតិវិធី ដោយមូលហេតុមានធុរៈជាប់រវល់រៀងៗខ្លួន ប៉ុន្តែនៅក្នុងស្ថានភាពនៃការស្នើសុំពន្យារពេលនីតិវិធីនេះ មានករណីរឿងក្តីខ្លះ តុលាការបានអនុញ្ញាតឱ្យធ្វើការពន្យាពេលនីតិវិធីច្រើនដងពេក ដែលធ្វើឱ្យប៉ះពាល់ដល់ដំណើរការនីតិវិធី ការកកស្ទះសំណុំរឿងនៅតុលាការ និង ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀតដែលមិនចង់ពន្យារពេលនីតិវិធីថែមទៀតផង។ ម្យ៉ាងទៀត ប្រសិនបើធ្វើការពន្យារពេលនីតិវិធីច្រើនដងពេក អាចនឹងភាគីដែលចង់ដំណើរការនីតិវិធី មានអារម្មណ៍ថា ភាគីម្ខាងទៀតព្យាយាមគេចវេសមិនព្រមចូលខ្លួនដោះស្រាយនៅតុលាការ ដោយការស្នើសុំពន្យារពេលនីតិវិធីរហូត។ ហើយមានករណីរឿងក្តីខ្លះទៀត តុលាការ មិនអនុញ្ញាតឱ្យពន្យារពេលនីតិវិធីទាល់តែសោះ សូម្បីតែម្តង បើទោះជាមានមូលហេតុចាំបាច់យ៉ាងណាក៏ដោយ ក៏តុលាការនៅតែបន្តនីតិវិធីដោយមិនពន្យារពេលដល់ភាគីដែលមានធុរៈបន្ទាន់នោះឡើយ ដែលការមិនពន្យារពេលឱ្យភាគីដែលមានធុរៈបន្ទាន់ និង ជាការស្នើសុំពន្យារពេលនីតិវិធីលើកទី១បែបនេះ ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិភាគីយ៉ាងខ្លាំង ដោយភាគីអវត្តមាននៅក្នុងដំណើរការនីតិវិធី មិនបានធ្វើការអះអាងនូវអង្គហេតុដែលជាផលប្រយោជន៍របស់ខ្លួន និង ផ្ទុយពីគោលការណ៍ចំពោះមុខដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា។

**កថាខណ្ឌទី៧៖ ការអនុវត្តនីតិវិធី**

ចំពោះការអនុវត្តនីតិវិធីរបស់តុលាការ យើងឃើញថា រឿងក្តីមួយចំនួន ការអនុវត្តនីតិវិធីរបស់តុលាការជាក់ស្តែងមានលក្ខណៈផ្ទុយពីអ្វីដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពោលគឺនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល យើងសង្កេតឃើញថា ជាក់ស្តែងនីតិវិធីនេះ ច្រើនតែក្រឡាបញ្ជីគឺជាអ្នកធ្វើការដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ដោយការអនុវត្តបែបនេះគឺផ្ទុយទៅនឹងស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ដែលការដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ត្រូវធ្វើឡើងដោយចៅក្រមទទួលបន្ទុករឿងក្តីផ្ទាល់ គឺមិនមែនឱ្យក្រឡាបញ្ជីធ្វើជាអ្នកដឹកនាំនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ។

**កថាខណ្ឌទី៨៖ ការកំណត់ចំណុចវិវាទ**

នៅក្នុងដំណើរការនីតិវិធីរដ្ឋប្បវេណី ការកំណត់ចំណុចវិវាទគឺសំខាន់បំផុតចំពោះរឿងក្តីរដ្ឋប្បវេណី ពីព្រោះថាកាលណាធ្វើការកំណត់ចំណុចវិវាទខុស នឹងធ្វើឱ្យគោលបំណងនៃរឿងក្តី ឬ កម្មវត្ថុនៃរឿងក្តីប្រែប្រួលទៅតាមការកំណត់ចំណុចវិវាទនោះ ឧទាហរណ៍ដូចជា៖ ដើមចោទប្តឹងទាមទារសុំឱ្យចុងចម្លើយទទួលស្គាល់កម្មសិទ្ធិលើដីមួយកន្លែង ដែលបានធ្វើការទិញលក់ជាមួយគ្នា ប៉ុន្តែ ភាគីចុងចម្លើយបែរជាធ្វើការអះអាងថាដីនោះខ្លួនគ្រាន់

តែធ្វើការជួលឱ្យដើមចោទតែប៉ុណ្ណោះ។ ដោយផ្អែកតាមឧទាហរណ៍នេះ យើងឃើញថាការកំណត់ចំណុចវិវាទពិតជាមានការលំបាកខ្លាំងណាស់ ពីព្រោះទាក់ទងនឹងបញ្ហាពីរផ្សេងពីគ្នា ហេតុនេះប្រសិនបើការកំណត់ចំណុចវិវាទត្រូវបានធ្វើឡើង ប្រាកដជាស្ថានភាពនៃរឿងក្តីប្រែប្រួលទៅតាមការកំណត់ចំណុចវិវាទនោះមិនខាន។

ជាក់ស្តែង ការកំណត់របស់តុលាការ ដែលបានកំណត់ថា ចំណុចវិវាទ គឺវិវាទលើកិច្ចសន្យាទិញលក់ ប៉ុន្តែភាគីដែលបានតវ៉ាគ្នាមិនចុះសម្រុង គឺនៅក្នុងកិច្ចព្រមព្រៀងបន្ថែមដែលបានចុះបន្ទាប់ពីបានចុះកិច្ចសន្យាទិញលក់ ដោយភាគីបានលើកយកកិច្ចសន្យាទិញលក់មកធ្វើជាមូលដ្ឋាន បែរជាតុលាការ កំណត់ចំណុចវិវាទលើកិច្ចសន្យាទិញលក់ទៅវិញ។

### កថាខណ្ឌទី៩៖ ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ

នៅក្នុងវិស័យច្បាប់នៃព្រះរាជាណាចក្រកម្ពុជា គឺមានអ្នកយល់ដឹងផ្នែកច្បាប់មិនច្រើននោះទេ ហើយប្រជាពលរដ្ឋក៏នៅមានបញ្ហាក្នុងការយល់ដឹងលើវិស័យច្បាប់ ដែលត្រូវការជំនួយពីអ្នកច្បាប់ ពោលគឺ មេធាវី ហើយបញ្ហាដែលប្រជាពលរដ្ឋតែងតែជួបប្រទះគឺប្រជាពលរដ្ឋពុំបានយល់ដឹងអំពី ដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីនោះទេ ពោលគឺ នៅក្នុងការយល់ដឹងអំពីដំណើរនីតិវិធីនីមួយៗនៃការជំនុំជម្រះរបស់តុលាការនោះទេ ឧទាហរណ៍ដូចជា៖ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីផ្សះផ្សារ នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់ និង ការប្រកាសសាលក្រមជាដើម។ល។ ដូចនេះ ប្រជាពលរដ្ឋ ពុំបានយល់ដឹងអំពីលំហូរនៃនីតិវិធីទាំងនេះទេ ដែលជាហេតុនាំឱ្យតុលាការពិបាកក្នុងការដឹកនាំនីតិវិធីបានយ៉ាងរលូន ហើយត្រូវធ្វើការពន្យល់អំពីសិទ្ធិដែលភាគីនៃវិវាទនៅក្នុងដំណាក់កាលនៃនីតិវិធីនីមួយៗ ដើម្បីកុំឱ្យមានការបាត់បង់នូវសិទ្ធិណាមួយនាពេលដំណើរការនីតិវិធី។ ការដឹកនាំនីតិវិធីបែបនេះ គឺមិនអាចធ្វើបានទាន់តាមពេលវេលានោះទេ ពោលគឺត្រូវតែមានការយឺតយ៉ាវនៅក្នុងការអនុវត្តនីតិវិធីនៅក្នុងនីតិវិធីនីមួយៗនៃការជម្រះក្តី។

## ផ្នែកទី២៖ ដំណោះស្រាយ

ដើម្បីឱ្យការអនុវត្តនីតិវិធីរដ្ឋប្បវេណីចំពោះនីតិវិធីជម្រះក្តីលើកទី១ ដំណើរការទៅដោយមានប្រសិទ្ធភាព តម្លាភាព មានភាពងាយស្រួល ប្រព្រឹត្តទៅដោយរលូន និង ឆាប់រហ័សនោះ គឺត្រូវមានដំណោះស្រាយចំពោះបញ្ហាប្រឈម ដែលបានរៀបរាប់ខាងលើនេះ ដូចតទៅ៖

### កថាខណ្ឌទី១៖ ការសរសេរ និង ការដាក់ពាក្យបណ្តឹង

ចំណុចនេះ គឺដំណាក់កាលដំបូងនៃដំណើរការនីតិវិធីនៃការជម្រះក្តីលើកទី១ ហើយក៏ជាចំណុចសំខាន់នៃនីតិវិធីផងដែរនោះ ដើម្បីឱ្យការសរសេរ និង ការដាក់ពាក្យបណ្តឹង អាចធ្វើទៅបានដោយត្រឹមត្រូវតាមច្បាប់ និង មានមូលដ្ឋានច្បាស់លាស់ គឺត្រូវមានដំណោះស្រាយដូចខាងក្រោម៖

**វាក្យខណ្ឌទី១៖ ការសរសេរពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ**

ស្ថាប័ន តុលាការ គប្បីមានក្រុមការងារ ឬ អ្នកជំនួយដល់ប្រជាពលរដ្ឋសម្រាប់កែតម្រូវនូវរាល់ពាក្យបណ្តឹង ឬ ចងក្រងជាទម្រង់ពាក្យបណ្តឹងទុកសម្រាប់ប្រជាពលរដ្ឋធ្វើការបំពេញតាមទម្រង់នោះ។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋអាចស្វែងរក មេធាវីដើម្បីឱ្យជួយរៀបចំតាក់តែងពាក្យបណ្តឹងនេះ ដោយខ្លួនឯង ឬ នៅតាមអង្គការនានាក៏បាន។ ដោយឡែក ស្ថាប័នពាក់ព័ន្ធនឹងការផ្សព្វផ្សាយច្បាប់ផ្សេងៗ គប្បីរៀបចំនូវកម្មវិធីផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីមូលដ្ឋានច្បាប់ ឬ របៀបនៃការសរសេរពាក្យបណ្តឹងជាសាធារណៈ ឬ ផលិតជាវីដេអូអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងឱ្យបានច្បាស់អំពីរបៀបនៃការសរសេរពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្តឹង។

**វាក្យខណ្ឌទី២៖ ការយកពាក្យបណ្តឹងទៅដាក់នៅស្ថាប័នតុលាការ**

ដើម្បីដោះស្រាយនូវបញ្ហានេះ ប្រធានតុលាការ ត្រូវធ្វើការណែនាំបុគ្គលិករបស់លេខាធិការដ្ឋានរបស់តុលាការទាំងអស់ឱ្យបានយល់ច្បាស់អំពីសិទ្ធិ និង ដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងលើកយកនូវបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៧៨ មកធ្វើការពន្យល់ ដោយអ្នកដែលមានសមត្ថកិច្ចនៅក្នុងការលើកពាក្យបណ្តឹងចោល គឺមានតែតុលាការប៉ុណ្ណោះ ពោលគឺចៅក្រមទទួលបន្ទុករឿងក្តីនោះ ដោយមិនមែនជាលេខាធិដ្ឋានរបស់តុលាការដែលជាអ្នកមានសមត្ថកិច្ចនៅក្នុងការមិនទទួលយកបណ្តឹង ឬ លើកពាក្យបណ្តឹងចោលនោះទេ ពីព្រោះថាមុននឹងធ្វើការលើកពាក្យបណ្តឹងចោលនេះ តុលាការត្រូវធ្វើការកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹងនោះជាមុនសិន ទើបធ្វើការលើកពាក្យបណ្តឹងចោលបាន ហើយការលើកពាក្យបណ្តឹងចោលនេះ គឺត្រូវធ្វើឡើងដោយដីកាសម្រេចថែមទៀតផង ដោយមិនអាចធ្វើឡើងដោយផ្ទាល់មាត់ ឬ វិធីណាផ្សេងបាននោះទេ។

**វាក្យខណ្ឌទី៣៖ ការគណនាពន្ធដាក់ពាក្យសុំ**

ជាដំណោះស្រាយ គ្រប់ស្ថាប័នដែលមានកាតព្វកិច្ចពាក់ព័ន្ធនឹងការផ្សព្វផ្សាយ និង បណ្តុះបណ្តាលផ្នែកច្បាប់ទាំងអស់ គប្បីរៀបចំធ្វើសិក្ខាសាលាឱ្យបានច្រើនពាក់ព័ន្ធនឹងការគណនាពន្ធនេះ ហើយជាពិសេស គឺស្ថាប័នតុលាការផ្ទាល់តែម្តង គឺត្រូវបង្កើតឱ្យមាននូវការបណ្តុះបណ្តាលវគ្គខ្លីៗ ក៏ដូចជាសិក្ខាសាលាពាក់ព័ន្ធនឹងការពន្យល់អំពីការគណនាពន្ធនេះ ដើម្បីឱ្យចៅក្រម និង បុគ្គលិករដ្ឋបាលទាំងអស់បានសិក្សាស្វែងយល់ឱ្យបានច្បាស់លាស់ដើម្បីធ្វើការអនុវត្តឱ្យបានត្រឹមត្រូវ និង ជួយពន្លឿនដល់នីតិវិធីរបស់តុលាការផងដែរ។ ម៉្យាងទៀតគួរតែចងក្រងជារូបមន្តច្បាស់លាស់មួយដើម្បីធ្វើការគណនាពន្ធដាក់ពាក្យសុំនេះ ដើម្បីឱ្យមាននូវគោលការណ៍ច្បាស់លាស់ណាមួយក្នុងការអនុវត្តតាម និងធានានូវការមិនប្រែប្រួលលើតម្លៃពន្ធដាក់ពាក្យសុំលើរឿងក្តីនីមួយៗ។

**វាក្យខណ្ឌទី៤៖ ការធ្វើចំណាត់ការលើពាក្យបណ្ដឹង**

នៅក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៧៨ គប្បីចែងបន្ថែមអំពីអំឡុងពេលដែលត្រូវកំណត់ឱ្យតុលាការត្រូវធ្វើការកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្ដឹង ដែលផ្ទុយនឹងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា៧៥ កថាខណ្ឌទី២ ស្ដីអំពី របៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង។ ជាងនេះទៅទៀត ប្រធានតុលាការ គួរតែធ្វើការណែនាំដល់ចៅក្រមដែលស្ថិតនៅក្រោមស្ថាប័នរបស់ខ្លួន ដើម្បីឱ្យធ្វើចំណាត់ការចំពោះបញ្ហានៃការកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្ដឹងនោះ ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ដើម្បីកុំឱ្យមានការកកស្ទះសំណុំរឿងនៅតុលាការ និង កុំឱ្យភាគីអ្នកដាក់ពាក្យបណ្ដឹងមានអារម្មណ៍ថា តុលាការមានភាពលម្អៀងទៅភាគីម្ខាងទៀត ដោយការមិនធ្វើសកម្មភាពចំណាត់ការលើពាក្យបណ្ដឹងនោះ របស់ចៅក្រមទទួលបន្ទុករឿងក្ដីនោះ ។

**កថាខណ្ឌទី២៖ ការបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ**

តុលាការគួរតែចេញនូវវិក័យបត្របញ្ជាក់អំពីការទទួលប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ នៅពេលដែលអ្នកបង់ប្រាក់ប្រដាប់ក្ដី បានមកបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធនេះរួចរាល់ហើយ ឧទាហរណ៍ជាក់ស្ដែងដូចជា នៅសាលាឧទ្ធរណ៍ភ្នំពេញ គឺរាល់ពេលដែលអ្នកបង់ប្រាក់ប្រដាប់ក្ដីបានទៅបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធនេះ គឺរដ្ឋបាលរបស់សាលាឧទ្ធរណ៍ភ្នំពេញ តែងតែចេញនូវវិក័យបត្រឱ្យអ្នកបង់ប្រាក់ប្រដាប់ក្ដីនោះ។ ម៉្យាងទៀត ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គប្បីចែងកំណត់ឱ្យបានច្បាស់អំពីការកំណត់យកនូវប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធនេះដូចជា ស្ថានភាពណាខ្លះដែលត្រូវឱ្យភាគីបង់ប្រាក់ប្រដាប់ក្ដីនៅក្នុងចំនួនណាមួយ ដើម្បីជៀសវាងការទាមទារច្រើនហួសហេតុពេកនៃប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធនេះ។

**កថាខណ្ឌទី៣៖ ពេលវេលាដំណើរការនីតិវិធីនៃការជំនុំជម្រះ**

ដើម្បីធ្វើការដោះស្រាយលើបញ្ហាពេលវេលាដំណើរការនីតិវិធីនៃការជំនុំជម្រះ គឺត្រូវអនុវត្តតាមដំណោះស្រាយដូចខាងក្រោម៖

**វាក្យខណ្ឌទី១៖ នីតិវិធីនៃការជំនុំជម្រះលឿនពេក**

នៅក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា គប្បីចែងបន្ថែមអំពីរយៈពេលសម្រាប់ធ្វើការជំនុំជម្រះរឿងក្ដីនីមួយៗ ឱ្យបានសមរម្យ កុំឱ្យមានរឿងក្ដីត្រូវបានជំនុំជម្រះលឿនពេកបែបនេះ ដែលអាចធ្វើឱ្យសង្គមយល់ឃើញថា បុគ្គលគ្រប់រូបពុំមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដែលមានលក្ខណៈផ្ទុយទៅនឹងបញ្ញត្តិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ មាត្រា៣១ កថាខណ្ឌទី២ វាក្យខណ្ឌទី១។ ម៉្យាងទៀត ប្រធានតុលាការ គប្បីត្រួតពិនិត្យលើចៅក្រមដែលនៅក្នុងស្ថាប័នរបស់ខ្លួនទាំងអស់ ឱ្យអនុវត្តតួនាទីឱ្យបានម៉ត់ចត់ស្របតាមក្រមសីល

ធម៌របស់ខ្លួន។ ដោយឡែក ប្រសិនបើមានករណីដែលការជំនុំជម្រះក្តីនេះប្រើពេលលឿនពេកកើតឡើងបន្តទៀត គប្បីកំណត់ឱ្យមាន ឬ បង្កើតនូវបញ្ញត្តិច្បាប់សម្រាប់ធ្វើការដាក់ទណ្ឌកម្មដល់ចៅក្រមណាមួយដែលទទួលបន្ទុករឿងក្តី ហើយដឹកនាំនីតិវិធីនៃការជំនុំជម្រះលឿនពេក ដែលនាំឱ្យខូចខាតដល់ប្រយោជន៍របស់ភាគីនៃវិវាទ។

**វាក្យខណ្ឌទី២៖ នីតិវិធីនៃការជំនុំជម្រះយូរពេក**

ចំពោះរឿងក្តីទាំងឡាយណាដែលចៅក្រមទទួលបន្ទុកមិនព្រមយកមកធ្វើចំណាត់ការដោះស្រាយនោះទេ ឬ រឿងក្តីដែលចៅក្រមទទួលបន្ទុកធ្វើការដោះស្រាយយូរពេកមិនទាន់មានលទ្ធផលទៀតនោះ ប្រធានតុលាការត្រូវតែធ្វើការអន្តរាគមន៍ ដោយផ្តល់អនុសាសន៍ដល់ចៅក្រមទទួលបន្ទុករឿងក្តីនោះ ឬ យករឿងក្តីនោះមកធ្វើចំណាត់ការដោយខ្លួនឯងផ្ទាល់ ដើម្បីកុំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍របស់ភាគីនៃវិវាទ ដែលអាចធ្វើឱ្យអំណាចតុលាការចុះខ្សោយ ប្រជាពលរដ្ឋលែង ហើយនៅពេលធ្វើចំណាត់ការលើរឿងក្តីនោះចប់សព្វគ្រប់ប្រធានតុលាការ គប្បីធ្វើរបាយការណ៍ស្តីអំពីការមិនអើពើលើរឿងក្តី ឬ ការអនុវត្តនីតិវិធីនៃការជំនុំជម្រះប្រើពេលវេលាយូរពេករបស់ចៅក្រមទទួលបន្ទុករឿងក្តីនោះ ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង ក្រសួងយុត្តិធម៌ ដើម្បីឱ្យធ្វើការដាក់វិន័យ ឬ ណែនាំដល់ចៅក្រមរូបនោះ។

ជាពិសេស ស្ថាប័នដែលពាក់ព័ន្ធទាំងឡាយគប្បីធ្វើការត្រួតពិនិត្យលើការជំនុំជម្រះនីមួយៗ ដើម្បីជានាកុំឱ្យមានការរំលោភបំពានលើសិទ្ធិរបស់ភាគី ដែលអាចនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃវិវាទ និង សង្គមជាតិ។

**កថាខណ្ឌទី៤៖ សមត្ថភាពរបស់ចៅក្រម**

ស្ថាប័នគ្រប់គ្រងដែលពាក់ព័ន្ធ គប្បីបង្កើតនូវវគ្គបណ្តុះបណ្តាលបន្ថែមលើសមត្ថភាពរបស់ចៅក្រមដែលទើបនឹងពេញសិទ្ធិ ដើម្បីឱ្យចៅក្រមទាំងនោះយល់ដឹងឱ្យបានច្បាស់អំពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និង ការអនុវត្តជាក់ស្តែង ហើយគួរតែឱ្យចៅក្រមទាំងអស់នោះធ្វើការសាកល្បងវិនិច្ឆ័យ សម្រេចសេចក្តីលើរឿងក្តីនិមិត្តដែលមានលក្ខណៈស្មុគស្មាញខ្លះ និង សាមញ្ញខ្លះ ហើយធ្វើការត្រួតពិនិត្យសមត្ថភាពចៅក្រមទាំងនោះ ទៅតាមលទ្ធផលដែលចៅក្រមទាំងនោះបានធ្វើការវិនិច្ឆ័យសម្រេចសេចក្តី។

ជាពិសេសនោះ នៅក្នុងប្រព័ន្ធនៃការគ្រប់គ្រង គួរតែមាននូវស្ថាប័នមួយដើម្បីធ្វើអធិការកិច្ចលើសមត្ថភាពរបស់ចៅក្រមនីមួយៗ ដោយការប្រឡងសាកល្បងសមត្ថភាព និង ធ្វើការអនុវត្តនីតិវិធីសាកល្បង មុននឹងសម្រេចឱ្យចៅក្រមនោះពេញសិទ្ធិ ឬ អាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនបានដោយឯករាជ្យ ដើម្បីជានាបានថានឹងមិនធ្វើឱ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីនៃវិវាទ សង្គម និង ស្ថាប័នតុលាការនោះឡើយ។

**កថាខណ្ឌទី៥៖ សកម្មភាពរបស់តុលាការ**

តុលាការ គប្បីជួយជ្រោមជ្រែងដល់ភាគីដើមចោទ ឬ ភាគីណាម្ខាងដែលមានបំណងចង់ស្វែងរកនូវអាសយដ្ឋានរបស់ភាគីម្ខាងទៀត ដើម្បីអាចឱ្យការជូនដំណឹងអំពីដីកាកោះហៅ ឬ ដីកាបញ្ជូនផ្សេងៗដែលពាក់ព័ន្ធនឹងរឿងក្ដីធ្វើឡើងដោយងាយស្រួលបាន ដោយតុលាការគប្បីចេញនូវលិខិតអនុញ្ញាតណាមួយដែលអាចឱ្យភាគីដែលត្រូវការនោះ យកទៅប្រើប្រាស់បាននៅតាមស្ថាប័នពាក់ព័ន្ធនឹងការស្វែងរកអាសយដ្ឋានរបស់ភាគីនោះបាន ដើម្បីពន្លឿនដល់នីតិវិធីរបស់តុលាការ និងដើម្បីជៀសវាងការកកស្ទះសំណុំរឿងនៅតុលាការផងដែរ។ ម៉្យាងទៀត នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គួរតែចែងអំពីការចូលរួមអន្តរាគមន៍ ឬ ជ្រោមជ្រែង ដោយចេញលិខិតអនុញ្ញាតឱ្យភាគីបានយកទៅប្រើប្រាស់ដើម្បីស្វែងរកពត៌មានរបស់ភាគីម្ខាងទៀត ឬ ភស្តុតាងជាឯកសារ ឬ ភស្តុតាងជាសាក្សីផ្សេងៗ ដើម្បីបំពេញបន្ថែមលើខ្លឹមសារនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា មាត្រា ៩២ ដែលចែងអំពីករណីកិច្ចស្រាវជ្រាវរបស់ភាគី។

**កថាខណ្ឌទី៦៖ ការផ្ដល់សិទ្ធិឱ្យភាគីនៅក្នុងដំណើរការនីតិវិធីជម្រះក្ដី**

នៅក្នុងការដោះស្រាយនូវបញ្ហាអំពីការផ្ដល់សិទ្ធិឱ្យភាគីនៅក្នុងដំណើរការនីតិវិធីជម្រះក្ដីនេះ មិនគ្រប់គ្រាន់ ឬ មិនពេញលេញណ ដោយមានលក្ខណៈបិទសិទ្ធិភាគីមិនឱ្យធ្វើការតទល់ ឬ តតាំងគ្នា និង ការបិទសិទ្ធិមេធាវីតំណាងដោយអាណត្តិឱ្យភាគីនៅក្នុងរឿក្ដី លើការធ្វើសកម្មភាពផ្សេងៗ នៅក្នុងដំណើរការនៃនីតិវិធីរដ្ឋប្បវេណី គឺត្រូវប្រើប្រាស់នូវដំណោះស្រាយមួយចំនួនដូចខាងក្រោម៖

**វាក្យខណ្ឌទី១៖ ការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួន**

នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គប្បីចែងបំពេញបន្ថែមអំពីពេលវេលាឱ្យបានច្បាស់លាស់ ដើម្បីកុំឱ្យមានការបកស្រាយទូលំទូលាយពេក ដែលអាចធ្វើឱ្យមានលក្ខណៈស្មុគស្មាញ និង មិនយុត្តិធម៌ចំពោះភាគីនៃវិវាទ។ ឧទាហរណ៍ដូចជា៖ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មានចែងបន្ថែមថា ដើមចោទ ឬ ចុងចម្លើយ ត្រូវធ្វើការដាក់មធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួននៅក្នុងរយៈពេល១០ថ្ងៃនៃថ្ងៃធ្វើការ មុនពេលចាប់ផ្ដើមនីតិវិធីនីមួយៗនៃបណ្ដឹង។

**វាក្យខណ្ឌទី២៖ ការធ្វើសេចក្ដីថ្លែងការណ៍**

ដើម្បីឱ្យការធ្វើសេចក្ដីថ្លែងការណ៍របស់ភាគី ឬ មេធាវីតំណាងដោយអាណត្តិឱ្យភាគី ប្រព្រឹត្តទៅស្របតាមស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា និង ដើម្បីជៀសវាងការប៉ះពាល់ដល់សិទ្ធិរបស់ភាគី ឬ មេធាវីតំណាងដោយអាណត្តិឱ្យភាគី ក្នុងការធ្វើសេចក្ដីថ្លែងការណ៍ ដើម្បីការពារផលប្រយោជន៍របស់ខ្លួននោះ ដូចនេះ តុលាការ គប្បីឱ្យភាគីធ្វើសេចក្ដីថ្លែងការណ៍របស់ខ្លួនតាមតែអ្វីដែលភាគីចង់យកមកបង្ហាញ អះអាង និង បញ្ជាក់ជូនដល់តុលាការ ប៉ុន្តែក៏មិនមែនបើកសិទ្ធិជ្រុលហួសហេតុពេកដល់ភាគីដើម្បីឱ្យធ្វើសេចក្ដីថ្លែង

ការណ៍ច្រើនហួសប្រមាណពេកនោះទេ ពោលគឺនៅក្នុងចំណុចដែលតុលាការយល់ឃើញថា ឬ ចំណុចដែលមិនមានពាក់ព័ន្ធនឹងរឿងក្តី តុលាការអាចឱ្យភាគីធ្វើការថ្លែងការណ៍ដោយរំលងនូវចំណុចនោះចោល ហើយចូលទៅចំណុចថ្មីបន្តទៀត។ លើសពីនេះទៅទៀត ភាគីផ្ទាល់គួរយល់ដឹងមួយចំនួនអំពីចំណុចដែលខ្លួនត្រូវថ្លែងការណ៍ ដើម្បីកុំឱ្យប្រើពេលយូរពេក អាចនាំឱ្យដំណើរការនីតិវិធីរបស់តុលាការយឺតយ៉ាវ ខាតពេលវេលា និង ប៉ះពាល់ដល់ការកកស្ទះសំណុំរឿងនៅតុលាការ។ ម៉្យាងទៀត តុលាការគប្បីផ្តល់សិទ្ធិឱ្យមេធាវី ដើម្បីធ្វើសេចក្តីថ្លែងការណ៍ឱ្យបានគ្រប់គ្រាន់ មិនថាមេធាវីតំណាងដោយអាណត្តិឱ្យភាគីណាមួយក៏ដោយ ពីព្រោះថា មេធាវី គឺជាអ្នកវិជ្ជាជីវៈផ្នែកច្បាប់ ដែលមានពុទ្ធិជ្រៅជ្រះលើវិស័យច្បាប់ ដែលអាចធ្វើសេចក្តីថ្លែងការណ៍ជូនតុលាការឱ្យលក្ខណៈងាយស្រួលយល់ជាងភាគីនៃវិវាទផ្ទាល់ ដែលមិនសូវមានចំណេះដឹងផ្នែកច្បាប់ និង មិនមានជំនាញនៅក្នុងការនិយាយពន្យល់អំពីអង្គហេតុ ឬ ដំណើររឿងពិត។ ជាពិសេស នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គប្បីចែងបន្ថែមអំពីលក្ខខណ្ឌមួយចំនួនដែលតុលាការអាចនឹងមិនឱ្យ ឬ ធ្វើការបញ្ឈប់ការធ្វើសេចក្តីថ្លែងការណ៍របស់ ភាគី ឬ មេធាវីតំណាងដោយអាណត្តិរបស់ភាគី។

**ខាត្យខណ្ឌទី៣៖ ការស្នើសុំពន្យារពេលនីតិវិធី**

តុលាការ គប្បីពិចារណាឱ្យបានច្បាស់លាស់មុននឹងធ្វើការសម្រេចចិត្តពន្យារពេលនីតិវិធីនីមួយៗ និង ត្រូវធ្វើការពិនិត្យលើមូលហេតុនៃការស្នើសុំពន្យារពេលឱ្យបានជាក់លាក់ រួមទាំងកំណត់នូវកាលបរិច្ឆេទថ្មីឱ្យបានឆាប់រហ័សបំផុត បន្ទាប់ពីតុលាការបានសម្រេចពន្យារពេលនីតិវិធីនោះ ហើយត្រូវធានាឱ្យបានថាកាលបរិច្ឆេទថ្មីនោះ គឺគូភាគីនៃវិវាទអាចចូលរួមបាន ដើម្បីជៀសវាងការស្នើសុំពន្យារពេលនីតិវិធីបន្តទៅទៀត។ ម៉្យាងទៀត ការកំណត់ចំនួនដែលអាចស្នើសុំពន្យារពេលនីតិវិធីបាន គួរតែកំណត់នៅក្នុងនីតិវិធីនីមួយៗ ភាគីអាចធ្វើការស្នើសុំពន្យារពេលនីតិវិធីយ៉ាងច្រើនបានត្រឹម២ដងនៅក្នុងនីតិវិធីនីមួយៗ ដើម្បីធានាឱ្យបាននូវការមិនមានបំណងទុច្ចរិតនៅក្នុងការស្នើសុំពន្យារពេលនីតិវិធី និងដើម្បីឱ្យដំណើរការនីតិវិធីអនុវត្តទៅដោយរលូន។

សរុបមកវិញ តុលាការគួរតែផ្តល់សិទ្ធិឱ្យភាគីនៃវិវាទឱ្យបានគ្រប់គ្រាន់ នៅក្នុងការអះអាង តវ៉ា ការប្រើប្រាស់មធ្យោបាយតទល់ ឬមធ្យោបាយការពារ ការដាក់ភស្តុតាង និង ការធ្វើសេចក្តីថ្លែងការណ៍ផ្សេងៗ ឱ្យអស់ទៅតាមលទ្ធភាពដែលភាគីមាន និង មានលក្ខណៈសមរម្យដែលអាចទទួលយកបាន ដើម្បីឱ្យដំណើរការនីតិវិធីរវាងភាគីនៃវិវាទប្រព្រឹត្តទៅដោយមានតម្លាភាព និង ត្រឹមត្រូវស្របតាមស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណី។ ម៉្យាងទៀត តុលាការគប្បីបើកសិទ្ធិឱ្យទូលំទូលាយដល់មេធាវីតំណាងដោយអាណត្តិឱ្យភាគីនៃវិវាទ ដើម្បីឱ្យមេធាវីបានប្រើប្រាស់ និង អនុវត្តសិទ្ធិរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ និង អស់ពីលទ្ធភាពនៅក្នុងដំណើរការនីតិវិធី ពីព្រោះថាមេធាវីក៏ជាអ្នកវិជ្ជាជីវៈផ្នែកច្បាប់ឯករាជ្យមួយផងដែរ ដែលមានចំណេះដឹងទូលំទូលាយផ្នែកច្បាប់ អាចជួយសម្រួលដល់ដំណើរការនីតិវិធីរបស់តុលាការបានច្រើន និង អាចធ្វើការពន្យល់ដល់កូនក្តីរបស់ខ្លួនដែលជាភាគី

នៃវិវាទអំពីដំណើរការ ឬ លំហូរនីតិវិធីបាន ដោយពុំមានការរំខានដល់តុលាការនោះឡើយ។ លើសពីនេះទៅទៀត ចំពោះការស្នើសុំពន្យារពេលនីតិវិធី តុលាការ គប្បីពិចារណាលើមូលហេតុនៃការស្នើសុំ និង ភាពចាំបាច់នៃស្ថានភាពដែលមិនអាចចូលរួមនីតិវិធីបាន។

**កថាខណ្ឌទី៧៖ ការអនុវត្តនីតិវិធី**

តុលាការ គប្បីធ្វើការអនុវត្តនីតិវិធីឱ្យបានត្រឹមត្រូវស្របតាមស្មារតីនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីកុំឱ្យមានការជាន់សមត្ថកិច្ចគ្នារវាងចៅក្រម និង ក្រឡាបញ្ជី។ ដោយឡែក តុលាការគប្បីបង្កើតនូវវគ្គបណ្តុះបណ្តាលអំពីនីតិវិធីដល់ចៅក្រម និង ក្រឡាបញ្ជី ដើម្បីឱ្យការអនុវត្តនីតិវិធីមានភាពត្រឹមត្រូវស្របតាមស្មារតីច្បាប់។ ម្យ៉ាងទៀត ប្រធានតុលាការផ្ទាល់ គប្បីផ្តល់អនុសាសន៍មួយដល់ចៅក្រមដែលនៅក្នុងបន្ទុករបស់ខ្លួនឱ្យយល់ដឹងអំពីតួនាទី និង សមត្ថកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និង ណែនាំឱ្យចៅក្រមបំពេញតួនាទីដោយខ្លួនឯង មិនត្រូវឱ្យក្រឡាបញ្ជីដឹកនាំនីតិវិធីជំនួសបានដូចករណីដែលធ្លាប់មានកន្លងមកនោះទេ ហើយចៅក្រមដែលទទួលបន្ទុករឿងក្តីផ្ទាល់ គួរតែធ្វើការណែនាំបន្តដល់ក្រឡាបញ្ជីរបស់ខ្លួន ឱ្យយល់អំពីតួនាទីរវាងចៅក្រម និង ក្រឡាបញ្ជី នៅក្នុងដំណើរការរឿងក្តីរដ្ឋប្បវេណីនៃនីតិវិធីជម្រះក្តីលើកទី១នេះឱ្យបានច្បាស់លាស់ផងដែរ។

**កថាខណ្ឌទី៨៖ ការកំណត់ចំណុចវិវាទ**

តុលាការ ត្រូវតែធ្វើការស្វែងរក និង កំណត់នូវចំណុចវិវាទ ដែលច្បាស់លាស់មួយ ដែលត្រឹមត្រូវតាមគោលបំណងនៃបណ្តឹង ដើម្បីងាយស្រួលដល់ការអនុវត្តនីតិវិធី និង ដើម្បីឱ្យតុលាការយកធ្វើជាមូលដ្ឋាននៅក្នុងការវិនិច្ឆ័យសម្រេចសេចក្តីឱ្យត្រឹមត្រូវតាមគោលបំណងនៃបណ្តឹង។ ម្យ៉ាងទៀត ប្រធានតុលាការ គប្បីណែនាំដល់ចៅក្រមដែលស្ថិតនៅក្រោមស្ថាប័នរបស់ខ្លួនទាំងអស់ អំពីការកំណត់នូវចំណុចវិវាទឱ្យបានត្រឹមត្រូវ ដោយធ្វើការចែករំលែកនូវបទពិសោធន៍របស់ខ្លួនដែលធ្លាប់បានអនុវត្តកន្លងមក។

**កថាខណ្ឌទី៩៖ ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋ**

នៅក្នុងដំណើរការនៃនីតិវិធីជំនុំជម្រះក្តី គូភាគីនៃវិវាទ គប្បីមានអ្នកតំណាងដោយអាណត្តិ ពោលគឺ មេធាវីតំណាងដោយអាណត្តិ ដើម្បីជួយការពារសិទ្ធិ និង ផលប្រយោជន៍ រួមទាំងផ្តល់ជាយោបល់ និងពន្យល់ណែនាំទៅតាមនីតិវិធីនីមួយៗនៃការជំនុំជម្រះ។ ម្យ៉ាងទៀត ស្ថាប័នដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយច្បាប់ទាំងឡាយ គប្បីធ្វើជាវីដេអូអប់រំពន្យល់អំពីដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីលើកទី១ជាសាធារណៈ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងបន្ថែមអំពីដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីលើកទី១ នៅស្ថាប័នតុលាការ។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការអត្ថាធិប្បាយ និង បកស្រាយអំពីនីតិវិធីជម្រះក្តីលើកទី១ខាងលើនេះរួចមក យើងសង្កេតឃើញថា នីតិវិធីជម្រះក្តីលើកទី១នេះ មានភាពស្មុគស្មាញខ្លាំងមែនទែន ដែលធ្វើឱ្យអ្នកវិជ្ជាជីវៈ អ្នកសិក្សា និង ប្រជាពលរដ្ឋពិបាកនៅក្នុងការសិក្សាស្វែងយល់ ដោយនីតិវិធីនីមួយៗត្រូវបត់បែនទៅតាមស្ថានភាពនៃរឿងក្តី ហើយពេលខ្លះ កាលៈទេសៈនៃរឿងក្តីត្រូវបានផ្លាស់ប្តូរទៅតាមសមត្ថភាពរបស់ភាគីដូចជា កាលណាភាគីនៃវិវាទមានចំណេះដឹងផ្នែកច្បាប់គ្រប់គ្រាន់ នោះតុលាការមិនសូវមានការលំបាកនៅក្នុងការដឹកនាំនីតិវិធីជម្រះក្តីនោះទេ ប៉ុន្តែប្រសិនបើសមត្ថភាពរបស់ភាគីក្នុងការយល់ដឹងផ្នែកច្បាប់នៅមានកម្រិត នោះតុលាការនឹងជួបប្រទះនូវបញ្ហាមួយចំនួននៅក្នុងការដឹកនាំនីតិវិធី ដោយត្រូវធ្វើការពន្យល់ដល់ភាគីនូវសិទ្ធិរបស់ភាគីនៅក្នុងដំណាក់កាលនីតិវិធីនីមួយៗ។

ហេតុនេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យមានអ្នកតំណាងដោយអាណត្តិ និង អ្នកជំនួយ ដើម្បីឱ្យភាគីអាចជ្រើសរើសដោយខ្លួនឯង ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យខ្លួននៅក្នុងដំណើរការនីតិវិធីរបស់តុលាការបាន ហើយអ្នកតំណាងដោយអាណត្តិ គឺសម្តៅទៅលើ មេធាវីដែលជាអ្នកវិជ្ជាជីវៈផ្នែកច្បាប់។

ដោយឡែក នៅក្នុងបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា យើងឃើញថា មានចែងនូវចំណុចជាច្រើនដែលអាចយកមកធ្វើការអនុវត្តបានគ្រប់គ្រាន់ហើយ ប៉ុន្តែនៅឡើយតែចំពោះបញ្ហាមួយចំនួនប៉ុណ្ណោះដូចមានសរសេរនៅក្នុងជំពូកទី៣ ដូចជា នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពុំមានចែងអំពីពេលវេលាសម្រាប់ការធ្វើនីតិវិធីជម្រះរឿងក្តីនីមួយៗនៅឡើយទេ ដែលនាំឱ្យរឿងក្តីនៅតុលាការត្រូវបានដោះស្រាយចំណាយពេលវេលាផ្សេងៗពីគ្នាទាំងអស់ ដូចជារឿងក្តីខ្លះត្រូវបានជម្រះតាមនីតិវិធីតុលាការដោយប្រើពេលលឿន និង រឿងក្តីខ្លះទៀតជម្រះតាមនីតិវិធីតុលាការដែរ ប៉ុន្តែប្រើពេលយូរនៅក្នុងការដោះស្រាយបញ្ចប់វិវាទ ដែលបានធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ភាគីនៃវិវាទយ៉ាងខ្លាំង ដោយសារតែនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពុំបានធ្វើការកំណត់អំពីពេលវេលាជាក់លាក់ណាមួយដែលតម្រូវឱ្យតុលាការត្រូវធ្វើការដោះស្រាយរឿងក្តីនីមួយៗទៅតាមពេលវេលានោះឱ្យបានច្បាស់លាស់នៅឡើយ។

ម៉្យាងទៀត ចំពោះដំណើរការនីតិវិធីជម្រះក្តី គឺមានលក្ខណៈស្មុគស្មាញ និង បត់បែនទៅតាមកាលៈទេសៈនៃរឿងក្តីនីមួយៗ ដូច្នេះហើយ ការកត់កំណត់ហេតុ គឺជាចំណុចដ៏សំខាន់មួយនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ ដែលអាចបញ្ជាក់នូវរាល់សកម្មភាពទាំងឡាយដែលបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីនីមួយៗ ដូចជា ការកំណត់ចំណុចវិវាទ, ការអះអាងរបស់ភាគី, ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះការអះអាង, ការតវ៉ាចំពោះការអះអាង, ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគី ឬ ការធ្វើសេចក្តីថ្លែងការណ៍របស់អ្នកតំណាង

ដោយអាណត្តិរបស់ភាគី និង ការសះជាគ្នាតាមផ្លូវបណ្ដឹង ជាដើម។ល។ ជាពិសេស គឺកំណត់ហេតុនៃការសះជាពោលគឺ ការសះជាតាមផ្លូវបណ្ដឹង ដែលកំណត់ហេតុនៃការសះជានេះ មានសារៈសំខាន់ណាស់ ពីព្រោះថាកំណត់ហេតុនេះមានអានុភាពដូចគ្នាទៅនឹងសាលក្រមស្ថាពរដែរ ដោយភាគីនៅក្នុងរឿងក្ដីអាចយកទៅធ្វើការអនុវត្តបាន ប្រសិនបើការសះជាគ្នានោះ ជាករណីដែលមានការផ្ដល់នូវតាវកាលិកណាមួយដោយភាគីម្ខាង ទៅឱ្យភាគីម្ខាងទៀត។

ជាងនេះទៅទៀត ការសះជាតាមផ្លូវបណ្ដឹងនេះ បានផ្ដល់នូវសារៈប្រយោជន៍ជាច្រើនដល់ភាគី និង តុលាការក្នុងការដោះស្រាយវិវាទកន្លងមកដោយការប្រើនីតិវិធីផ្សះផ្សា ដើម្បីបញ្ចប់វិវាទនៅតុលាការ។ ជាទូទៅ ចំពោះជម្លោះទាំងអស់ដែលឈានទៅដល់ការដោះស្រាយតាមប្រព័ន្ធតុលាការនេះ គឺតុលាការតែងតែចង់ឱ្យភាគីធ្វើការដោះស្រាយវិវាទនោះ ដោយការផ្សះផ្សាគ្នា ដើម្បីបញ្ចប់វិវាទដោយការសះជាតាមផ្លូវបណ្ដឹង ដែលវាផ្ដល់នូវផលប្រយោជន៍ជាច្រើនដូចជា អាចឱ្យតុលាការបញ្ចប់រឿងក្ដីបានដោយឆាប់រហ័ស ជៀសវាងការកកស្ទះសំណុំរឿងក្ដីនៅតុលាការ និង អាចឱ្យភាគីត្រូវរ៉ូវគ្នាឡើងវិញ ដែលអាចឱ្យភាគីនៅតែអាចថែរក្សានូវទំនាក់ទំនងល្អជាមួយគ្នានាពេលអនាគត។ អ្វីដែលសំខាន់នោះគឺ នីតិវិធីនៃការផ្សះផ្សា ជានីតិវិធីពេញនិយមដែលតុលាការជារឿយៗយកមកអនុវត្តនៅក្នុងការអនុវត្តជាក់ស្ដែង។

លើសពីនេះទៅទៀត ការបញ្ជូនដីកា ពាក្យបណ្ដឹង សាលក្រម ឬ ឯកសារផ្សេងៗទៀតជាដើម តុលាការហាក់បីដូចជាអសកម្មចំពោះចំណុចនេះ ហើយនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និង ការអនុវត្តជាក់ស្ដែង យើងឃើញថា អ្នកដែលទទួលបន្ទុកនេះ គឺជាដើមចោទ ដែលត្រូវបង់ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ និងផ្ដល់អាសយដ្ឋានជាក់លាក់របស់ចុងចម្លើយ ដើម្បីឱ្យតុលាការបញ្ជូនដីកា ពាក្យបណ្ដឹង សាលក្រម ឬ ឯកសារផ្សេងៗទៀតទៅឱ្យចុងចម្លើយ ហើយប្រសិនបើមានការខុសអាសយដ្ឋាន ឬ អាសយដ្ឋានដែលដើមចោទផ្ដល់មក ធ្វើឱ្យតុលាការរកមិនឃើញ នោះដើមចោទជាអ្នកទទួលបន្ទុកនៅក្នុងការស្វែងរកអាសយដ្ឋាននោះ ដោយតុលាការត្រឹមតែធ្វើការបង្គាប់ឱ្យដើមចោទកែតម្រូវនូវអាសយដ្ឋានរបស់ចុងចម្លើយតែប៉ុណ្ណោះ។

ជាពិសេស ចំពោះការវិនិច្ឆ័យសម្រេចសេចក្ដីលើរឿងក្ដីនីមួយៗរបស់តុលាការ ដែលធ្វើឡើងដោយពុំបានធ្វើការវិនិច្ឆ័យគ្រប់ជ្រុងជ្រោយ ឬ អង្គហេតុប្រយោលដែលមានសភាពមិនច្បាស់លាស់ អាចធ្វើឱ្យភាគីគិតថាតុលាការធ្វើការសម្រេចសេចក្ដីមិនត្រឹមត្រូវ និង មានការលម្អៀងទៅរកភាគីណាម្ខាង ដែលនេះជាហេតុនាំឱ្យភាគីជារឿយៗ ធ្វើការប្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដោយកើតទុក្ខមិនសុខចិត្តនឹងការសម្រេចសេចក្ដីរបស់តុលាការដើមនេះ ដែលនាំឱ្យរឿងក្ដីកាន់តែមានភាពស្មុគស្មាញ កាន់តែពិបាកនៅក្នុងដោះស្រាយ និង កាន់តែត្រូវចំណាយពេលវេលាយូរបន្ថែមទៀតនៅក្នុងការដោះស្រាយជម្លោះនោះ ហើយក៏ជាហេតុដែលនាំឱ្យភាគីខាតបង់ផលប្រយោជន៍ និង ធ្វើឱ្យមានការកកស្ទះសំណុំរឿងនៅតុលាការ។

យ៉ាងណាមិញ ចំពោះការដោះស្រាយវិវាទតាមរយៈប្រព័ន្ធតុលាការ តុលាការ គួរតែព្យាយាមនៅក្នុងការប្រើនីតិវិធីផ្សះផ្សា ដើម្បីរកនូវចំណុចត្រូវរ៉ូវគ្នា ដែលអាចឱ្យភាគីយល់ឃើញថាការផ្សះផ្សាបានផ្តល់អត្ថប្រយោជន៍ដល់ខ្លួនច្រើនជាងការដោះស្រាយវិវាទដោយការចេញសាលក្រម ហើយភាគីផ្ទាល់ផងដែរ គប្បីធ្វើការផ្សះផ្សាគ្នាជាជាងជ្រើសរើសយកការដោះស្រាយវិវាទដោយការចេញសាលក្រមនោះ ពីព្រោះថា ការដោះស្រាយវិវាទដោយប្រើការសះជាគ្នាអាចបញ្ចប់វិវាទបានឆាប់រហ័សជាងការដោះស្រាយវិវាទដោយការចេញសាលក្រម ហើយម៉្យាងទៀត ការដោះស្រាយវិវាទតាមរយៈការសះជាគ្នា អាចរក្សាទំនាក់ទំនងល្អរវាងភាគីនាពេលអនាគតថែមទៀតផង ដោយភាគីនៅតែអាចធ្វើការទំនាក់ទំនងល្អជាមួយនឹងគ្នា ភាគីអាចធ្វើអាជីវកម្មជាមួយគ្នា និង ភាគីអាចធ្វើសកម្មភាពគតិយុត្តជាមួយគ្នាដោយទំនុកចិត្តជាដើម។ល។

លើសពីនេះទៅទៀត នៅក្នុងរឿងក្តីរដ្ឋប្បវេណី ភាគី គប្បីមាននូវមេធាវីតំណាងដោយអាណត្តិឱ្យខ្លួន ពីព្រោះថា លំហូរនីតិវិធីនៃការជំនុំជម្រះក្តី គឺមានលក្ខណៈស្មុគស្មាញ ពិបាកនៅក្នុងការយល់ និង ពិបាកនៅក្នុងការអនុវត្តតាមលំហូរនីតិវិធីនីមួយៗ ដែលទាមទារឱ្យមានអ្នកវិជ្ជាជីវៈផ្នែកច្បាប់ដើម្បីធ្វើជាជំនួយនៅក្នុងការផ្តល់យោបល់ ប្រឹក្សា ណែនាំ និងការពារសិទ្ធិ ដើម្បីធានានូវផលប្រយោជន៍ និង ដើម្បីឱ្យដំណើរការនីតិវិធី ប្រព្រឹត្តបានរលូន កាត់បន្ថយនូវឧបសគ្គបានច្រើន និង ចំណេញពេលវេលានៅក្នុងការដោះស្រាយបានឆាប់រហ័ស។

# អនុសាសន៍

ជាចុងក្រោយ បន្ទាប់ពីខ្ញុំបាទបានធ្វើការសិក្សាស្រាវជ្រាវ និង អត្ថាធិប្បាយលើដំណើរការនីតិវិធីជម្រះក្តីលើកទី១នេះរួចហើយ ខ្ញុំបាទសូមផ្តល់នូវអនុសាសន៍មួយចំនួន ដែលអាចធ្វើឱ្យនីតិវិធីជម្រះក្តីលើកទី១នេះដំណើរការទៅដោយមានប្រសិទ្ធភាព គុណភាព ឆាប់រហ័ស និង ធ្វើឱ្យប្រជាពលរដ្ឋមានទំនុកចិត្តលើវិស័យយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជាឡើងវិញ ដូចតទៅៈ

➢ ស្ថាប័នដែលពាក់ព័ន្ធនឹងការផ្សព្វផ្សាយច្បាប់ទាំងអស់ គប្បីធ្វើការផ្សព្វផ្សាយអំពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ពោលគឺ នីតិវិធីជម្រះក្តីលើកទី១ ដើម្បីឱ្យប្រជាពលរដ្ឋ អ្នកវិជ្ជាជីវៈ អ្នកសិក្សា និង និស្សិត អាចបានសិក្សា និង ស្វែងយល់បន្ថែមអំពីគោលបំណងនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និង នីតិវិធីជម្រះក្តីលើកទី១។ ឧទាហរណ៍ៈ បើកវគ្គខ្លីៗសម្រាប់ធ្វើការបណ្តុះបណ្តាល ឬ ការធ្វើសិក្ខាសិលាឱ្យបានច្រើន ឬ ធ្វើជាវីដេអូអប់រំពាក់ព័ន្ធនឹងដំណើរការនៃនីតិវិធីជម្រះក្តីលើកទី១ ជាដើម។ល។

➢ នៅក្នុងដំណើរការនីតិវិធីជម្រះក្តីលើកទី១ ភាគីគួរតែមាននូវអ្នកតំណាងដោយអាណត្តិ ពោលគឺ មេធាវី ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យភាគី ក្នុងការជួយសម្រួលដល់ដំណើរការនីតិវិធីនៅកាលបរិច្ឆេទនីមួយៗប្រព្រឹត្តទៅដោយរលូន និង ធានាឱ្យបាននូវការការពារផលប្រយោជន៍របស់ភាគីនៅក្នុងកម្រិតដែលអាចទទួលយកបានមួយ។ ម៉្យាងទៀត ភាគីអាចឱ្យអ្នកតំណាងដោយអាណត្តិចូលរួមនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីនីមួយៗជំនួសខ្លួនបាន ហើយអាចធ្វើការប្រឹក្សាយោបល់ជាមួយអ្នកតំណាងដោយអាណត្តិបាន នៅក្នុងអំឡុងពេលដែលភាគីកំពុងធ្វើសកម្មភាពនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីនីមួយៗ។

➢ នៅក្នុងដំណើរការនីតិវិធីជម្រះក្តីលើកទី១ នៅពេលដែលភាគីធ្វើសកម្មភាពនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីនីមួយៗ តុលាការត្រូវផ្តល់នូវសិទ្ធិស្មើគ្នាចំពោះភាគី ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដូចជា ផ្តល់សិទ្ធិឱ្យភាគីបានធ្វើការអះអាង, តវ៉ា, ថ្លែងការណ៍, តទល់ និង ការបង្ហាញភស្តុតាងឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យតុលាការទទួលបាននូវគោលគំនិតពីសកម្មភាពរបស់ភាគីដែលបានធ្វើនោះ សម្រាប់យកមកធ្វើជាមូលដ្ឋានក្នុងការពិចារណា និង វិនិច្ឆ័យសម្រេចសេចក្តី ហើយនិង កុំឱ្យភាគីមានអារម្មណ៍ថា តុលាការបានរឹតត្បិតសិទ្ធិភាគីណាម្ខាងមិនឱ្យធ្វើសកម្មភាព។

➢ តុលាការត្រូវផ្តល់សិទ្ធិដល់ភាគីឱ្យបានសមរម្យ ចំពោះការស្នើសុំពន្យារពេលនីតិវិធី ដោយត្រូវបើកសិទ្ធិឱ្យភាគីអាចធ្វើការស្នើសុំពន្យារពេល ដើម្បីឱ្យភាគីអាចមានពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំខ្លួនជាមុន ស្វែងរកមេធាវីដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យខ្លួន និង ស្វែងរកឯកសារពាក់ព័ន្ធនឹងរឿងក្តីផ្សេងៗទៀត មុនពេលដែលភាគីត្រូវចូលរួមនីតិវិធីនីមួយៗរបស់តុលាការ។ ប៉ុន្តែការពន្យារពេលនេះ តុលាការក៏មិនត្រូវបើកសិទ្ធិឱ្យភាគីជ្រុលហួសហេតុពេកដែរ ពោលគឺ កុំឱ្យភាគីស្នើសុំពន្យារពេលនីតិវិធីច្រើនដងពេក ដែលអាចធ្វើឱ្យមានការ

កកស្ទះសំណុំរឿងនៅតុលាការ និង ភាគីអាចនឹងមានបំណងចង់គេចវេសមិនចូលរួមនីតិវិធីរបស់តុលាការ ដោយការស្នើសុំពន្យារពេលនីតិវិធីនេះ។

➢ ស្ថាប័នតុលាការ ត្រូវកំណត់នូវសិទ្ធិអំណាចរបស់លេខាធិការដ្ឋានអមស្ថាប័នរបស់ខ្លួនឱ្យបានច្បាស់លាស់ ដើម្បីឱ្យការអនុវត្តសិទ្ធិអំណាចរបស់លេខាធិការដ្ឋានអមតុលាការនោះ ប្រព្រឹត្តទៅដោយមានប្រសិទ្ធភាព គុណភាព និង គុណតម្លៃ ស្របតាមតួនាទីរបស់ខ្លួន រួមទាំងកុំឱ្យមានការជាន់សមត្ថកិច្ចគ្នាជាមួយតុលាការ។

➢ ចំពោះការគណនាពន្ធលើកម្មវត្ថុនៃបណ្តឹង ស្ថាប័នពាក់ព័ន្ធនឹងការងារវិស័យច្បាប់ទាំងអស់ គប្បីសិក្សាស្រាវជ្រាវបន្ថែមអំពី ការគណនាពន្ធលើកម្មវត្ថុនៃបណ្តឹងនេះ ដើម្បីឱ្យមាននូវការកំណត់ជាក់លាក់ និង ងាយស្រួលនៅក្នុងការគណនា ពីព្រោះថានៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រង់ចំណុចការគណនាពន្ធនេះ ហាក់បីដូចជា មានភាពស្មុគស្មាញសម្រាប់ការសិក្សាស្វែងយល់ និង ពិបាកនៅក្នុងការគណនាចំពោះករណីដែលកម្មវត្ថុនៃបណ្តឹងនោះមានច្រើនចំណុច និង មានចំនួនមិនច្បាស់លាស់ រួមទាំងប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធផងដែរ។ ដូចនេះ គួរតែមាននូវការកំណត់ជាក់លាក់ណាមួយ ដើម្បីឱ្យអ្នកដែលត្រូវបង់ពន្ធអាចយល់ដឹងក្នុងការគណនាពន្ធដោយខ្លួន ដែលបង្កភាពងាយស្រួលដល់អ្នកបង់ពន្ធអាចភ្ជាប់ប្រាក់ដែលត្រូវបង់ពន្ធទៅជាមួយ នៅពេលយកពាក្យបណ្តឹងទៅដាក់នៅតុលាការ។

➢ ភាគីត្រូវធ្វើសកម្មភាពនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីនីមួយៗឱ្យអស់ពីលទ្ធភាព ដោយហេតុថា នៅក្នុងរឿងក្តីរដ្ឋប្បវេណី សកម្មភាពរបស់តុលាការ គឺអសកម្ម ពោលគឺ ភាគីជាអ្នកទទួលបន្ទុកនៅក្នុងការដាក់ភស្តុតាងដើម្បីដាក់បន្ទុក ឬ ដោះបន្ទុកដោយខ្លួនឯង និង ស្នើសុំរុករកភស្តុតាងដោយភាគីផ្ទាល់ តាមរយៈការដាក់ពាក្យស្នើសុំទៅតុលាការ ហើយតុលាការអាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនសម្រេចលើការស្នើសុំរបស់ភាគីបាន។

➢ ភាគី អ្នកតំណាងដោយអាណត្តិរបស់ភាគី និង តុលាការ ត្រូវគោរពនូវក្រមសីលធម៌របស់ខ្លួន នៅក្នុងកាលបរិច្ឆេទនីមួយៗនៃនីតិវិធីជម្រះក្តីលើកទី១ ឱ្យបានល្អប្រសើរ ជៀសវាងការធ្វើនូវសកម្មភាពអវិជ្ជមានផ្សេងៗ ដែលអាចធ្វើឱ្យការវិនិច្ឆ័យសម្រេចសេចក្តីមានការប្រែប្រួល។

➢ មុននឹងធ្វើការសម្រេចសេចក្តីបញ្ចប់រឿងក្តី តុលាការត្រូវធ្វើការពិចារណា និង ពិនិត្យលើភស្តុតាងឱ្យបានល្អិតល្អន់ ដើម្បីផ្តល់នូវភាពយុត្តិធម៌ពិតជូនដល់ភាគីដែលត្រូវបានរំលោភបំពានសិទ្ធិ។

➢ តុលាការ គប្បីចេញនូវដីកាសម្រេចអនុញ្ញាតតាមការស្នើសុំរបស់ភាគី នៅពេលដែលភាគីបានធ្វើការស្នើសុំពាក់ព័ន្ធនឹងការរុករកភស្តុតាងផ្សេងៗដែលអាចមានទំនាក់ទំនងជាមួយរឿងក្តី។

➢ នៅពេលដែលតុលាការធ្វើការសម្រេចសេចក្តីចប់សព្វគ្រប់តាមនីតិវិធីរួចរាល់ហើយ តុលាការត្រូវតែធ្វើការជូនដំណឹង និង បញ្ជូនឯកសារពាក់ព័ន្ធទៅឱ្យភាគីភ្លាមៗ ដើម្បីឱ្យភាគីបានដឹងអំពីលទ្ធផលនៃការជំនុំ

ជម្រះលើរឿងក្តីរបស់ខ្លួន និង ដើម្បីឱ្យភាគីអាចធ្វើការប្តឹងឧបាស្រ័យបានទាន់ពេលវេលា ប្រសិនបើភាគីណាមួយមិនពេញចិត្តនឹងការសម្រេចសេចក្តីរបស់តុលាការ។

➢ ចំពោះជម្លោះដែលត្រូវបានបញ្ជូនមកធ្វើការដោះស្រាយតាមប្រព័ន្ធតុលាការ ដោយអនុលោមស្របតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា តុលាការ និង ភាគី គួរតែជ្រើសរើសយកនីតិវិធីនៃការផ្សះផ្សាមកធ្វើការដោះស្រាយ ជាជាងការដោះស្រាយវិវាទដោយការចេញសាលក្រម ដែលការសះជាតាមផ្លូវបណ្តឹង អាចផ្តល់ផលប្រយោជន៍ជូនភាគីតាមការចរចារ និង អាចធ្វើឱ្យទំនាក់ទំនងរបស់ភាគីនៃវិវាទនៅតែល្អនឹងគ្នានាពេលអនាគត។

➢ តុលាការ គួរតែធ្វើការបញ្ជាក់ឱ្យបានច្បាស់លាស់ ដើម្បីឱ្យភាគីបានយល់ដឹងអំពីសិទ្ធិរបស់ខ្លួនដែលអាចធ្វើការប្តឹងលើ ដីកាសម្រេច ឬ សាលក្រម ដែលតុលាការបានចេញនៅក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ដើម្បីជៀសវាងនូវករណីដែលភាគីថ្លស់សិទ្ធិនៅក្នុងការប្តឹងឧបាស្រ័យ ឬ ប្តឹងទាស់ជាដើម។ល។

## ឯកសារយោង

### ១. លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

### ២. សៀវភៅ និង ស្នាដៃអ្នកនិពន្ធ

- សៀវភៅ ស្តីពី ការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី១ របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បោះពុម្ពលើកទី២ ឆ្នាំ២០០៩
- សៀវភៅមេរៀននីតិវិធីរដ្ឋប្បវេណីរបស់លោកស្រីមេធាវី ងួន មករា។

✍📖✍

## បញ្ជីឧបសម្ព័ន្ធ

**១. លិខិតបញ្ជាក់ ស្តីពីការចុះស្រាវជ្រាវសារណាបញ្ចប់ការសិក្សា**

**២. គំរូពាក្យបណ្តឹង**

- ពាក្យបណ្តឹងធម្មតា
- ពាក្យបណ្តឹងទាមទារប្រាក់
- ពាក្យបណ្តឹងទាមទារដី
- ពាក្យបណ្តឹងលែងលះ

**៣. ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធ**

**៤. គំរូកំណត់ហេតុ**

- កំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល
- កំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់
- កំណត់ហេតុសះជា

**៥. គំរូសាលក្រមរដ្ឋប្បវេណី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


ក្រុមមេធាវី ស៊ី ភី អេច និង សហការី

CPH & ASSOCIATES LAW GROUP

លេខ ១០៥១/២០CPH


# <u>លិខិតបញ្ជាក់</u>

## <u>ស្ដីពីការចុះស្រាវជ្រាវសារណាបញ្ចប់ការសិក្សា</u>

ខ្ញុំបាទមេធាវី **ចេង ប៉េងហាប់** អត្តលេខ៖ ៥៤២ ជាប្រធាននៃ **ក្រុមមេធាវី ស៊ី ភី អេច និង សហការី**(CPH & ASSOCIATES LAW GROUP) មានការិយាល័យនៅអគារ ស៊ីភីអែល លេខ ២៥ និង ៦៣ ជាន់ទី ៦ បន្ទប់ A ផ្លូវលេខ ៣៤៨ កែង ២០៥ សង្កាត់ទួលស្វាយព្រៃ ២ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ។

ទូរស័ព្ទទំនាក់ទំនងលេខ៖ ០១២ ៦៧ ១១១១ / ០៨៧ ៨៣ ៨៣ ៨៣ ។

## <u>សូមបញ្ជាក់ថា</u>

និស្សិតឈ្មោះ ហួត ដាណាថប ភេទប្រុស អត្តលេខ៖ **BL16-0348** ជានិស្សិតឆ្នាំទី៤ ផ្នែកនីតិសាស្ត្រ នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** ឆ្នាំសិក្សា ២០១៦-២០២០ ជំនាន់ទី២០ ពិតជាបានចុះមកធ្វើការស្រាវជ្រាវនូវឯកសារដែលមានខ្លឹមសារពាក់ព័ន្ធនឹងសារណាបញ្ចប់ការសិក្សា លើប្រធានបទ "នីតិវិធីនៃការជម្រះក្ដីលើកទី១" ដែលបានស្រាវជ្រាវអំពី ទ្រឹស្ដីនៃនីតិវិធីនៃការជម្រះក្ដីលើកទី១ និង បញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តនីតិវិធីនៃការជម្រះក្ដីលើកទី១ នៅ **ក្រុមមេធាវី ស៊ី ភី អេច និង សហការី** ចាប់ពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២០ ប្រាកដមែន។

ថ្ងៃច័ន្ទ ១៣កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០

**ហត្ថលេខា និង ត្រា**

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAM…

**មេធាវី.ចេង_ប៉េងហាប់**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្ដឹង(ធម្មតា)

**<u>ដើមចោទ៖</u>** ឈ្មោះ ........................ ភេទ........... កើតឆ្នាំ............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ៖ ........................ ចុះថ្ងៃទី........... ខែ........... ឆ្នាំ............ មានអាសយដ្ឋានបច្ចុប្បន្ន នៅផ្ទះ............ ផ្លូវ........... ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត...........................។

**<u>ចុងចម្លើយ៖</u>** ឈ្មោះ ........................ ភេទ........... កើតឆ្នាំ............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ៖ ........................ ចុះថ្ងៃទី........... ខែ........... ឆ្នាំ............ មានអាសយដ្ឋានបច្ចុប្បន្ន នៅផ្ទះ............ ផ្លូវ........... ភូមិ................ ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត...........................។

## សូមគោរពជូនចំពោះ
## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

